# ប្រស្នាប្រជុំកខធម៌

## ពិស្តារ

ជំនួយដល់ការសិក្សា

ធម្មវិន័យ ថ្នាក់ត្រី

ភាគ ទី ១

ប្រមូលរៀបរៀង . និពន្ធដោយ

សែម - សូរ

ព.ស. ២៥១៦ គ.ស. ១៩៧២

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ប្រស្នាប្រជុំកងធម៌ពិស្តារ

ជំនួយដល់ការសិក្សា

## ធម្មវិន័យថ្នាក់ត្រី

ប្រមូលរៀបរៀង – និពន្ធដោយ

**រំសេម - សួរ**

សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សាបឋមភូមិ

បរិញ្ញាប័ត្រ អក្សរសាស្ត្រ

សាស្ត្រាចារ្យមធ្យមសិក្សា ទុតិយភូមិ

ព.ស ២៥១៦ គ.ស ១៩៧២

## គោលបំណងនៃអ្នកនិពន្ធ

ដើម្បីនឹងសម្រេចគោលបំណងមួយ ដែលខ្ញុំបានផ្គងទុកយូរហើយ នោះបើខ្ញុំព្រះករុណា ខ្ញុំបាទមានការរវល់យ៉ាងណា ក៏ខំប្រឹងរៀបចំគោលវិធីនៃក្បួនច្បាប់ខាងព្រះពុទ្ធសាសនា ទុកជាអនុស្សាវរីយ៍ប្រចាំជីវិតនេះម្យ៉ាង ហើយម្យ៉ាងទៀត ដើម្បីទុកប្រគេន – ជូន លោកប្អូន ៗ ជំនាន់ក្រោយ មានសៀវភៅសិក្សាផ្នែកព្រះពុទ្ធសាសនា នេះគ្រប់គ្រាន់នឹងរៀនសូត្រ – គិតពិចារណាតទៅ នោះបើស្នាដៃរបស់ខ្ញុំព្រះករុណា ខ្ញុំបាទពុំគ្រប់លក្ខណៈ ឬ ពុំល្អផ្ដាច់នោះក៏ដោយ ក៏គ្រាន់បើជាងគ្មាន ដូចកាលខ្ញុំព្រះករុណានៅរៀនសូត្រដែរ ។

សៀវភៅ **ប្រស្នាប្រជុំកងធម៌ពិស្តារ** នេះជាស្នាដៃមួយថ្មីទៀត ដែលជាជំនួយដល់ការសិក្សាធម្មវិន័យថ្នាក់ត្រី នេះឯង ។ សៀវភៅនេះ មានកម្រងនៃធម៌ជាគោល ៗ ដែលគណៈកម្មការធម្មវិន័យបានកំរិតឲ្យភិក្ខុសាមណេរ សិក្សាប្រចាំថ្នាក់ផង មានសំណួរនិងចម្លើយក្រៅផ្សេងទៀត តែមានទំនាក់ទំនងទៅនឹងការសិក្សានៃកងធម៌នីមួយ ៗ ផង ជាឧបករណ៍នៃការចេះដឹងផ្នែកព្រះពុទ្ធសាសនាផង ។ ខ្ញុំព្រះករុណា ខ្ញុំបាទបានយកគោលធម៌ទាំងនោះ មករៀបរៀងពន្យល់ដោយឃ្លាប្រយោគយ៉ាងងាយ ៗ ស្ដាប់ ហើយពាក្យសំដី ឬ ឃ្លាប្រយោគទាំងប៉ុន្មានមានបែបទំនើប ស្របតាមកាលវេលាផង ។

សូមលោកប្អូនៗ អ្នកសិក្សាបានសម្រេចការចេះដឹងយល់និងស្គាល់នូវលក្ខណៈច្បាស់លាស់នៃទ្រឹស្តីព្រះពុទ្ធសាសនាតាមបំណង ។

សូមឧទ្ទិសកុសលប្រគេនជូនគ្រូអាចារ្យ និងម្តាយឪពុកខ្ញុំ ដែលបានបង្រៀនខ្ញុំឲ្យស្គាល់ – យល់និងស្រឡាញ់ទ្រឹស្តីព្រះពុទ្ធជាម្ចាស់ ។

ភ្នំពេញថ្ងៃ ១៣ មីនា ១៩៧២

**សែម ~ ស្វះ**

# ប្រស្នាប្រជុំគខធម៌ពិស្តា

## ទុកៈ ធម៌ពួកពីរ :

### ធម៌មានឧបការៈច្រើន ២ យ៉ាង

**១– សតិ** មានស្មារតី

**២– សម្បជញ្ញៈ** ការដឹងខ្លួនជានិច្ច ។

**ស** – ចូរពន្យល់ពាក្យ **សតិ** និងពាក្យ **សម្បជញ្ញៈ** ឲ្យបានច្បាស់លាស់មកមើល !

**ឆ** – ពាក្យថា **សតិ** សំគាល់ន័យសេចក្តីថា ការរលឹកនឹកឃើញ, ការភ្ញាក់ស្មារតី, មានស្មារតីចងចាំជានិច្ចទៅលើកិច្ចការផ្សេងៗ ដែលខ្លួនកំពុងធ្វើ, មិនភ្លេចស្មារតី ឬ រវល់ចំណែកអារម្មណ៍ទៅក្នុងទីផ្សេងៗ ការងារផ្សេងដែលខ្លួនកំពុងធ្វើ ។

ឯពាក្យថា **សម្បជញ្ញៈ** វិញ មានន័យថា ការដឹងខ្លួន, ការចងចាំនូវកិច្ចការទុកក្នុងខ្លួនជានិច្ច ពោលគឺបើធ្វើការអ្វីត្រូវដឹងខ្លួនជានិច្ចថា អាត្មាអញកំពុងធ្វើនូវការនោះ មិនភ័ន្តភាំងភាំងគំនិតនឹងកិច្ចការផង មិនច្រឡំកិច្ចការដែលខ្លួន កំពុងធ្វើផង ។

**ស** – ធម៌ទាំងពីរនេះ មាននាទីនិងគុណសម្បត្តិចំពោះបុគ្គល ក្នុងលក្ខណៈណាខ្លះ ? ចូរពន្យល់ !

**ឆ** – មាននាទី និង គុណសម្បត្តិដូចនេះគឺ :

**សតិ** ជួយបុគ្គលឲ្យមានស្មារតីតាំងខ្ជាប់ ឬ ចងចាំទុកជានិច្ច នៅក្នុងខ្លួន ក្នុងខួរក្បាលមិនឲ្យភ្លាំងភ្លាត់ច្រឡូកច្រឡំ ។

**សម្បជញ្ញៈ** ជួយបុគ្គលមិនឲ្យភ្លេចខ្លួន , ឲ្យដឹងខ្លួនជានិច្ចក្នុងពេលកំពុងធ្វើការ ឬក្នុងរយៈកាលកំពុងធ្វើការផ្សេង ៗ ។

**ស – សតិ** និង **សម្បជញ្ញៈ** ដែលថាជាធម៌មានឧបការៈច្រើន តើមានលក្ខណៈយ៉ាងណា ? ហេតុអ្វីបានជាលោកចាត់ទុកថា ធម៌ទាំងពីរនេះថាជាធម៌មានឧបការៈច្រើនទៅវិញ ?

**ឆ** – សតិ និង សម្បជញ្ញៈ ដែលលោកអ្នកប្រាជ្ញទាំងឡាយ បានចាត់ទុកថាជាធម៌មានឧបការៈច្រើន ព្រោះធម៌ទាំងពីរនេះ ជាឫសគល់ ឬជាគ្រឹះនៃកុសលធម៌ទាំងអស់ផង ជាកត្តាដ៏សំខាន់ណាស់ទៅទៀតដែលនាំឲ្យកុសលធម៌ទាំងពួងកើតឡើងផង , ចំរើនលូតលាស់ផង មានសកម្មភាព , ចលនារស់តទៅទៀតផង ព្រោះកាលណាមនុស្សមានស្មារតីតាំងនៅមាំមួន និង ដឹងខ្លួនជានិច្ចហើយ កាលធ្វើអ្វី , រៀនសូត្រ ឬ ប្រព្រឹត្តធម៌ក៏តែងមិនភ្លេចស្មារតី និងភ្លេចខ្លួនដែរ ។

យ៉ាងណាមិញ អ្នករៀនសូត្រក្តី អ្នកប្រកបអាជីវកម្មផ្សេងៗ សម្រាប់ចិញ្ចឹមជីវិតក្តី កាលរៀន ឬ ធ្វើការងារនោះ ៗ ដោយមានសតិ និងសម្បជញ្ញៈតាំងជាប់នៅក្នុងខ្លួនហើយ តែងនឹងបានសម្រេចផលប្រយោជន៍មិនខាន ផ្ទុយទៅវិញកាលបើបុគ្គលរៀនសូត្រ ឬ ធ្វើការងារផ្សេងៗ កាល



បើគ្មានសតិសម្បជញ្ញៈ តាំងខ្ជាប់នៅក្នុងខ្លួនទេ បុគ្គលនោះ នឹងមិនសម្រេចផលប្រយោជន៍តាមប្រាថ្នាឡើយ , អ្នកបើកបររថ , អ្នកធ្វើជាមេបាប្រមុខគេ កាលកំពុងប្រកបកិច្ចការនោះ ៗ ហើយបែរជាគ្មានសតិតាំងនៅក្នុងខ្លួនភ្លេចខ្លួន ដោយបណ្តែតអារម្មណ៍ឲ្យអណ្តែតអណ្តូងទៅកាន់ទីផ្សេងៗហើយ រថ ឬ កិច្ចការមុខជាជ្រុលជ្រួសទៅប៉ះទង្គិចអ្វីមួយមិនខាន ឯកិច្ចការដែលខ្លួនជាមេបាជាប្រមុខគេនោះ ក៏ភ្លាំងភ្លាត់ខុសគោលបំណងទៅវិញ ។ យ៉ាងនេះ បានជាលោកចាត់ទុក សតិ និង សម្បជញ្ញៈ នេះថាជាធម៌មានគុណចំណាប់ មានប្រយោជន៍ច្រើន ហើយជាគូអប្បមាទធម៌ ថែមទៀតផង ។ សតិសម្បជញ្ញៈ និងអប្បមាទធម៌គឺជាការមិនធ្វេសប្រហែសដូចគ្នា ។

## លោកបាលធម៌ ២ យ៉ាង

**ស** – ពាក្យថាលោកបាលធម៌ មានន័យយ៉ាងណា? អ្វីខ្លះ? ចូររាប់?

**ឆ** – លោកបាលធម៌ ប្រែថាធម៌រក្សាលោក មាន ២ យ៉ាងគឺ :

**១– ហិរិៈ** ការខ្មាសបាប

**២– ឱត្តប្បៈ** ការខ្លាចបាប ។

**ស**– ចុះពាក្យថាខ្មាសបាប និង ខ្លាចបាបនោះ តើ ខ្មាស – ខ្លាច បែបណា ? ខ្មាសដូចក្រមុំខ្មាសកម្លោះ ហើយខ្លាចដូចក្មេងខ្លាចប្រមាត់ប្រមង់ចាប់ ឬ យ៉ាងណា ?

ឆ– ពាក្យថាខ្មាសបាប ខ្លាចបាបក្នុងទីនេះ មិនមែនខ្មាស–ខ្លាច ដូចសំណួរខាងលើនោះឡើយ ប៉ុន្តែ៖

– ខ្មាសបាប គឺមិនហ៊ានធ្វើបាបផងទាំងពួង ដែលជាអំពើអាក្រក់គ្រប់យ៉ាង ដោយទុកបាបនោះជាដុំលាមក កាលណាប៉ះពាល់ត្រូវ រអឹង ប្រឡាក់ដៃ - ជើងដូច្នោះឯង ។

– ឯខ្លាចបាប គឺខ្លាចរអានឹងបាបមិនហ៊ានធ្វើ មិនហ៊ានប្រព្រឹត្ត ដូចភ្លើងតែកាលណាប៉ះពាល់ត្រូវវេ រអឹងនេះលោក ។ បាបនេះ ជាអកុសលធម៌ កាលណាបុគ្គលមិនចេះខ្លាច មិនចេះខ្មាសអៀនហើយនៅតែធ្វើ អំពើអាក្រក់នោះនឹងនាំឲ្យចុះទៅសោយទុក្ខក្នុងទីថោកទាប មាន នរក ប្រេត តិរច្ឆានជាដើម ។

ស– ចុះធម៌ទាំងពីរនេះ ដែលថារក្សាលោកនោះ តើលោកអ្វីខ្លះ? រក្សាលោកទាំងអស់ ឬមួយរក្សាលោកតែមួយ ១ ទេ? ចូរពន្យល់ឲ្យស្តាប់បាន!

ឆ– លោកសំដៅយកលំនៅនៃសត្វមាន ៣ កន្លែងគឺ :

**សង្ខារលោក** សំដៅយកលោកដែលមានសង្ខារតាក់តែងបាន ។

**សត្តលោក** សំដៅយកលោកដែលជាលំនៅនៃសត្វ មានមនុស្ស, ទេវៈ, ប្រេត, នរក, តិរច្ឆាន និងព្រហ្ម ។

**ឱកាសលោក** លោកដែលមានតែទីវាលអាកាសល្ហល្ហៃ ជាលំនៅ



នៃពពក, អ័ព្ទ ។

**ហិរិ** និង **ឱត្តប្បៈ** ដែលថារក្សាលោកនោះ មិនមែនរក្សាលោកទាំងអស់ទេ គឺរក្សាតែសត្តលោកមួយប៉ុណ្ណោះ ។

ស– ចុះរក្សាតែសត្តលោកដូច្នេះ រក្សាគ្រប់ប្រភេទនៃសត្វទាំងអស់ ឬមួយមានទៅសល់ដែរ? ព្រោះអ្វី?

ឆ– រក្សាសត្វលោក បានតែពួកមនុស្ស និង ទេវៈប៉ុណ្ណោះ ចំណែក ប្រេត, នរក, តិរច្ឆាន លោកបាលធម៌នេះ មិនអាចថែរក្សាបានឡើយ ព្រោះ៖

– ប្រេត, នរក, តិរច្ឆាន ពោរពេញទៅដោយបាបកម្មខ្លាំងពេក។

– ឯព្រហ្ម ក៏ធម៌នេះមិនអាចរក្សាដែរ ព្រោះព្រហ្មសោយតែបីតិ ផុតវិស័យ ដែលធម៌នេះអាចរក្សាបាន ។ ម្យ៉ាងទៀត ប្រេត, នរក, តិរច្ឆាន គ្មានសីល ឯព្រហ្ម ផុតពីការរក្សាសីលទៅហើយ គឺសោយតែផលដែលកើតពីអង្គឈានតែប៉ុណ្ណោះ ។

ស– ហិរិ ដែលជាការខ្មាសអៀនចំពោះបាបនោះ កើតឡើងហេតុណាដែរ? បើមានតើអ្វីខ្លះ? ចូររាប់ និង ពន្យល់!

ឆ– ហិរិ កើតឡើងដោយហេតុនៃការពិចារណាឃើញលក្ខណៈ ៤ យ៉ាង :

**១– ជាតិ បច្ចវេក្ខិតា** .– ដោយការពិចារណាឃើញជាតិកំ

ណើត ពោលគឺនឹកគិតឃើញថា អាត្មាអញកើតមកជាមនុស្ស មានជាតិកំណើតខ្ពស់ជាងសត្វតិរច្ឆាន មិនគួរទៅធ្វើបាបកម្មផ្សេងៗ ដែលជាអំពើថោកទាប ដូចសត្វតិរច្ឆាននោះហើយ ។

**២– វយំ បច្ចវេក្ខិតា**.– ដោយការពិចារណានឹកឃើញថាអាត្មាអញមានវ័យច្រើនហើយ មិនគួរទៅធ្វើបាបកម្មផ្សេងៗ ដូចកូនក្មេងមិនទាន់ដឹងក្តីនោះឡើយ ។

**៣– សូរភាវំ បច្ចវេក្ខិតា** ដោយការពិចារណានឹកគិតឃើញថា អាត្មាអញជាមនុស្សក្លៀវក្លា មានបណ្ដាស័ក្តិ ឬ មានចំណេះចេះដឹងច្រើន មានគោរពកប់អាន ទុកជាមនុស្សគ្រាន់បើ ឬ ខ្ពង់ខ្ពស់ មិនគួរទៅធ្វើបាបកម្មដែលជាអំពើអាក្រក់ដូចមនុស្សតូចទាបល្ងង់ខ្លៅនោះឡើយ ។

**៤– ពាហុស្សច្ចំ បច្ចវេក្ខិតា** ដោយការពិចារណានឹកគិតឃើញថា អាត្មាអញជាមនុស្សមានការរៀនសូត្រចេះដឹងច្រើន មិនគួរទៅធ្វើបាបកម្មផ្សេងៗ ដូចមនុស្សល្ងង់ខ្លៅនោះឡើយ ។ ការគិតឃើញដោយហេតុទាំង ៤ យ៉ាងនេះ ក៏មិនប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ដោយខ្មាសចំពោះអំពើបាបនោះៗ ហៅថា មាន ហិរិ នៅក្នុងខ្លួន ។

**ស**– ចុះ ឱត្តប្បៈ ដែលជាការខ្លាចតក់ស្លុតរន្ធត់ចំពោះបាបនោះ កើតឡើងដោយហេតុយ៉ាងណាខ្លះដែរ? មានប៉ុន្មាន? ចូរកប់ទិនពន្យល់?

**ឆ**– ឱត្តប្បៈ ការខ្លាចរអែងចំពោះបាបកើតឡើងដោយហេតុ ៤



យ៉ាងគឺ ៖

**១– បរានុវាទភ័យ**.– ខ្លាចចំពោះគំរិះគំនៀលពីសំណាក់បុគ្គលដទៃព្រោះថា បើខ្លួនធ្វើបាបកម្មផ្សេងៗទៅ នឹងត្រូវជនដទៃត្មះតិះដៀលដោយពាក្យផ្សេងៗ ។

**២– អត្តានុវាទភ័យ** ដោយខ្លាចចំពោះខ្លួនឯង ព្រោះកាលណាធ្វើបាបកម្មផ្សេងៗ ហើយ ខ្លួនឯងជាអ្នកធ្វើអាក្រក់នោះ ក៏ដឹងខ្លួនច្បាស់ថា អញធ្វើអាក្រក់ ហើយក៏កើតចិត្តអន្ទះអន្ទែងទឹកក្តៅក្រហាយនៅតែក្នុងចិត្ត ស្តាយក្រោយបន្តិច សោប់សល់ចិត្តបន្តិច មិនអស់ហើយក្នុងចិត្ត ។

**៣– ទុគ្គតិភ័យ**.– ដោយខ្លាចធ្លាក់ទៅទទួលទុក្ខទារុណកម្មក្នុងនរក ; ប្រេត , តិរច្ឆាន ឬអសុរកាយ ។

**៤– ទណ្ឌភ័យ** ដោយខ្លាចចំពោះអាជ្ញាផ្សេងៗ ពីអ្នករដ្ឋការ ឬ អ្នកកាន់អំណាចណាមួយ ។

**ស** – ហិរិ និង ឱត្តប្បៈ បើចែកជាសមុដ្ឋាន កើតណាចាត់ចូលក្នុងសមុដ្ឋានណា ? មានន័យយ៉ាងណាដែរ ?

**ឆ**– ហិរិ ៤ ប្រភេទ ឬ ដែលកើតឡើងដោយហេតុ ៤ យ៉ាងនោះ ចាត់ជាសមុដ្ឋានខាងក្នុង ហៅថា អជ្ឈត្តិកដ្ឋានព្រោះកើតចេញពីក្នុងខ្លួនឯង ឱត្តប្បៈ ចាត់ចូលក្នុងសមុដ្ឋានខាងក្រៅ ហៅថា ពាហិរសមុដ្ឋា

ព្រោះកើតចេញមកពីបុគ្គល ឬ ប្រកពខាងក្រៅ ។ ហិរិ យកខ្លួនជាធំ ឯឱត្តប្បៈ យកលោក ឬ មជ្ឈដ្ឋានខាងក្រៅជាធំ ។

## ធម៌ធ្វើឲ្យល្អ ២ យ៉ាង

**ស**– ធម៌ធ្វើឲ្យល្អ ២ យ៉ាងនោះគឺអ្វីខ្លះ ? ចូរកប់និងពន្យល់ !

**ឆ**– ធម៌ធ្វើឲ្យល្អ ២ យ៉ាងនោះគឺ :

១ – ខន្តី ចិត្តអត់ធន់

២ – សោរច្ចៈ ចិត្តស្ងប់ស្ងៀម ។

ខន្តី.. ចិត្តអត់ធន់ គឺអត់ធ្មត់ចំពោះហេតុការណ៍ដែលកើតមកពីខាងក្រៅខ្លួនមកលើខ្លួន ទោះជាការលំបាកវេទនាក្តី ការជេរប្រមាថក្តី ។

សោរច្ចៈ ចិត្តស្ងប់ស្ងៀមមិនបេះប្រពាច់ស្រពោន ចំពោះការប្រមាថមើលងាយពីខាងក្រៅ ឬតាំងចិត្តនិងកាយវិការមាំមួន ទឹងទន ស៊ើក្នុងគ្រាមានទុកលំបាក ។

**ស**– ខន្តី និងសោរច្ចៈនេះ លោកចាត់ជាធម៌មានគុណភាពដូចម្តេចខ្លះ ?

**ឆ**– ខន្តី និងសោរច្ចៈ ជាគុណធម៌ដ៏ល្អមួយ ហើយខន្តីធម៌ លោកចាត់ទុកជាបារមីធម៌មួយរបស់ព្រះពោធិសត្វផងហៅថាខន្តីបារមី ដែលព្រះពោធិសត្វតាមបន្ទុកុមារបានបំពេញ, ជាគ្រឿងអលង្ការ, ជាតបៈធម៌របស់អ្នកប្រាជ្ញផង ។ ចំណែកសោរច្ចៈវិញ បើអ្នកណាប្រកាន់យកដោយខ្ជាប់



ខ្ជួន នឹងបានផលប្រយោជន៍យ៉ាងសំខាន់ គឺមិនបញ្ចេញអាការៈក្រេវក្រោធឲ្យអ្នកផងទាំងពួងឃើញច្បាស់ផង ធ្វើសត្រូវឲ្យបានជាមិត្តផងចងមិត្តឲ្យរឹតតែបានច្រើនថែមទៀតផង ។

## បុគ្គលរកបានដោយកម្រ ២ យ៉ាង

១– **បុព្វការី** អ្នកធ្វើគុណបំណាច់មុន ។

២ **កតញ្ញូ កតវេទី** អ្នកដឹងចំពោះគុណបំណាច់ដែលអ្នកដទៃធ្វើមក ហើយធ្វើតបចំពោះគុណបំណាច់នោះវិញ ។

**ស**– ពាក្យថា បុព្វការី មានន័យដូចម្តេច ? មានប៉ុន្មានយ៉ាងដែរ? ចូរពន្យល់ !

**ឆ**– ពាក្យថា បុព្វការី មានន័យថា អ្នកបានធ្វើគុណូបការៈផ្សេង ៗ ទៅលើអ្នកឯទៀត ទោះអ្នកនោះជាកូនចៅ ញាតិមិត្តឬជាអ្នកដទៃក៏ដោយ ហើយថែមទាំងមិនគិតដល់លាភសក្ការ គុណប្រយោជន៍ពីជនដែលខ្លួនបានធ្វើគុណបំណាច់នោះឡើយ ។ បុព្វការីជននេះ មាន ៤ ពួកគឺ :

១– មាតាបិតា ជាបុព្វការីរបស់កូន

២ គ្រូជាបុព្វការីរបស់សិស្ស

៣– ប្រមុខរដ្ឋ ឬរាជ្យាធរ ជាបុព្វការីរបស់ប្រជារាស្ត្រ ។

៤– ព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធបរិស័ទ ។

ដែលថាមាតាបិតាជាបុព្វការីរបស់កូនប្រុសស្រីនោះ គឺមាតាបិតា មិន

ត្រឹមតែបានបង្កើតកូនប៉ុណ្ណោះឡើយ ប៉ុន្តែបានចិញ្ចឹមថែទាំយ៉ាងហ្មត់ចត់នូវកូន តាំងពីតូចរហូតទល់កូនក្រមុំកម្លោះ ឬមានប្តីប្រពន្ធ ក្រុមគ្រួសារទៀត ។ ទារកតូច បើម្តាយមិនចិញ្ចឹមឲ្យបៅដោះទេ ដូចជាកម្ររស់ណាស់ ។ មិនតែប៉ុណ្ណោះ ម្តាយឪពុកតែងមានព្រហ្មវិហារធម៌ គ្របដណ្តប់ទៅលើកូនប្រុសស្រីជានិច្ច ។

ឯគ្រូឧបជ្ឈាយាចារ្យ, គ្រូបង្រៀនសាស្ត្រាចារ្យជាដើម ដែលជាជាបុព្វការីរបស់សិស្សនោះ បានដល់ជនដែលជាគ្រូទាំងអស់ តែងប្រាប់ចំណេះវិជ្ជាអប់រំសិស្សគណ របស់ខ្លួនឲ្យចេះដឹងឲ្យមានបរិយាមារយាទ ការប្រព្រឹត្តល្អជានិច្ចឥតលាក់លៀមសោះឡើយ ធ្វើយ៉ាងណាឲ្យតែសិស្សបានចេះដឹង និងបានល្អ គ្មានគិតគុណបំណាច់ពីសិស្ស ។

អាជ្ញាធររដ្ឋ ជាបុព្វការីនៃប្រជារាស្ត្រ គឺអ្នកកាន់អំណាចរដ្ឋតែងគិតដល់ប្រយោជន៍ដល់ប្រជារាស្ត្រជានិច្ច ទោះបីរាស្ត្រប្រជាមិនបានគិតគួរធ្វើស្ងួតដោយ ។ មិនតែប៉ុណ្ណោះ តាមធម្មតានៅក្នុងប្រទេសដែលកាន់របបកាន់លទ្ធិប្រជាធិបតេយ្យ អំណាចគ្រប់យ៉ាងតែងបានទៅពីរាស្ត្រទាំងអស់ម្ល៉ោះហើយអាជ្ញាធរតែងគិតប្រយោជន៍រាស្ត្រតេយុត្តិធម៌ និងបំរើប្រជារាស្ត្រជាផលប ។

ឯព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធសាសនិកនោះ មានសេចក្តីបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធ កាលនៅជាពោធិសត្វទ្រង់បានបំពេញបារមី



ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធអស់ច្រើនអសង្ខេយ្យ ច្រើនកប្ប លុះបានត្រាស់ជាព្រះពុទ្ធហើយ ក៏ទ្រង់យាងទៅគ្រប់ទីកន្លែង ដើម្បីប្រោសប្រទានធម៌ចំពោះសព្វសត្វ ដោយឥតរើសមុខ ។

គឺដោយហេតុយ៉ាងនេះហើយ ទើបចាត់ថាព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធបរិស័ទ ។

សួ– ចុះកតញ្ញូកតវេទី ម្តេចក៏ថារកបានដោយកម្រដែរ ?

ឆ– ជនអ្នកដឹងនូវគុណូបការចំពោះជនដទៃដែលធ្វើមកលើខ្លួនហើយ ក៏ធ្វើតបវិញ ក៏កម្ររកបានដែរ ព្រោះក្នុងលោកនេះ មានជនតិចណាស់ដែលដឹងគុណ ហើយអ្នកខ្លះគ្រាន់តែដឹងតែប៉ុណ្ណោះ តែមិនដែលតបគុណចំពោះបុព្វការីជនដល់ម្តងសោះ, អ្នកខ្លះទៀត បានតបស្នងសងគុណម្តងពីរដង អ្នកខ្លះទៀតមិនដែលធ្វើអ្វីតបទាល់តែសោះ ។

បុគ្គលទាំងពីរជំពូកនេះកម្ររកបាន ត្រង់ដែលថាមានតែបុព្វការីជន តែខ្លះកតញ្ញូកតវេទីជន មានតែខ្លះបុព្វការីជនក៏មាន ។

ចប់ពួកធម៌ ២

# តិកៈ ធម៌ពួក ៣

## រតនៈ ៣ យ៉ាង

ស– រតនៈ ៣ យ៉ាងគឺអ្វីខ្លះ ? ចូររាប់និងពន្យល់ !

ឆ– រតនៈ ៣ យ៉ាងនោះគឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃហ្នឹងឯង ។

– ព្រះពុទ្ធ តើជានរណា ? គឺបុគ្គលមួយរូបដែលបានលះកាមកិលេស ហើយចេញបួសជាសមណៈ ស្វែងរកធម៌អស់ពេល ៦ ឆ្នាំ រួចបានត្រាស់ដឹងនូវប្រាជ្ញា ១ ខ្ពស់ផុត គ្មាននរណារកឃើញ ហៅថា «សម្មាសម្ពោធិញ្ញាណ» ហើយព្រះអង្គបានយកញាណដ៏ខ្ពស់នេះ ទៅសំដែងពន្យល់ប្រោសអស់មនុស្សសត្វនិងទេវតាឲ្យប្រព្រឹត្តល្អ ហើយបានសម្រេចធម៌ជាមគ្គផល តាមនិស្ស័យ, វាសនា, តាមបុណ្យព្រេងរបស់ខ្លួន ។

– ព្រះធម៌ សំដៅយកព្រះឱវាទជាពាក្យប្រៀនប្រដៅទាំងអស់របស់ព្រះពុទ្ធ រាប់ជាខន្ធមាន ៨ ម៉ឺន ៤ ពាន់ព្រះធម្មខន្ធ ដែលព្រះពុទ្ធទ្រង់សំដែងពេល ៤៥ ឆ្នាំនោះឯង ។

– ព្រះសង្ឃ សំដៅយកពួកសាវ័ករបស់ព្រះពុទ្ធ ដែលបានប្រតិបត្តិតាមព្រះឱវាទ ហើយបានសម្រេចមគ្គផល និងមិនទាន់សម្រេចមគ្គផលនៅឡើយ តែបានប្រព្រឹត្តល្អដោយកាយវាចាចិត្ត ដើម្បីសម្រេចធម៌ជាន់ខ្ពស់នោះឯង ។

ស– ហេតុអ្វីបានជាហៅព្រះពុទ្ធព្រះធម៌ព្រះសង្ឃថាជាកែវទៅវិញ?



ឆ បានជាហៅថា កែវ ព្រោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទុកដូចជាកែវ ដែលសំរាប់បំភ្លឺផ្លូវល្អសំរាប់មនុស្សសត្វ ជាគ្រឿងនាំឲ្យសត្វលោកកើតចិត្តត្រេកអរផង ។ ជនណាបានគោរពប្រតិបត្តិយ៉ាងត្រឹមត្រូវចំពោះកែវទាំង ៣ យ៉ាងនេះ ជននោះនឹងមានចិត្តរីករាយសប្បាយត្រជាក់ក្នុងដួងហឫទ័យ រកអ្វីប្រៀបដូចគ្មាន ។ ដូច្នេះបានជា លោកហៅថា កែវ នេះឯង ។

## គុណរបស់ព្រះរតនៈ ៣ យ៉ាង

ស– ព្រះរតនៈទាំង ៣ មានគុណយ៉ាងដូចម្ដេចខ្លះ ? ចូរអធិប្បាយពន្យល់ !

ឆ– គុណរបស់ព្រះរតនៈទាំង ៣ នោះមានច្រើនហើយផ្សេងៗគ្នា យ៉ាងនេះគឺ :

១ – ព្រះពុទ្ធដែលទ្រង់រកឃើញនូវប្រាជ្ញា សម្មាសម្ពោធិញ្ញាណ ហើយព្រះអង្គមិនបានលាក់ទុកនូវចំណេះចេះដឹងនោះ តែមួយព្រះអង្គឯងឡើយតែព្រះអង្គទ្រង់យកចំណេះចេះដឹងនោះ ទៅបង្រៀនពន្យល់មនុស្សសត្វឲ្យចេះដឹងយល់ឃើញផ្លូវត្រូវដូចព្រះអង្គដែរ ។ កាលណាយល់ឃើញត្រូវហើយ ជននោះនឹងបានសំរេចធម៌ជាន់ខ្ពស់ – កណ្ដាល – ទាប តាមនិស្ស័យ វាសនារបស់ខ្លួន ដែលបានសន្សំទុក ។

២ – ព្រះធម៌ តែងរក្សាអ្នកប្រព្រឹត្តធម៌ មិនឲ្យធ្លាក់ទៅកាន់

កំណើតអាក្រក់ដូចពុទ្ធភាសិតមួយកន្លែងសំដែងថា :

**ធម្មោ ហវេ រក្ខតិ ធម្មចារិំ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ**
**ន ទុគ្គតិំ គច្ឆតិ ធម្មចារី**

ព្រះធម៌ហ្នឹងឯងតែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ , ធម៌ដែលបុគ្គលបានសន្សំល្អហើយតែងនាំមកនូវក្តីសុខ , បើបុគ្គលសន្សំធម៌ដោយប្រពៃហើយតែងបានអានិសង្សបែបនេះមិនខាន , បុគ្គលអ្នកប្រព្រឹត្តធម៌ មិនទៅកាន់កំណើតអាក្រក់ឡើយ ។

ធម៌នេះឲ្យផលផ្ទុយពីអ្វីដែលជាអធម៌ ដូចពុទ្ធភាសិត ១ ទៀតសំដែងថា

**នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ អធម្មោ និរយំនេតិ ធម្មោ បាបេតិ សុគតិំ**

សភាពពីរគឺធម៌និងអធម៌ ឲ្យផលមិនស្មើគ្នាទេ អធម៌តែងដឹកនាំសត្វទៅកាន់នរក ឯធម៌តែងដឹកនាំសត្វឲ្យទៅកាន់កំណើតល្អ ។

៣ – ឯព្រះសង្ឃវិញ លោកជាអ្នកប្រព្រឹត្តល្អ តាមព្រះពុទ្ធោវាទដោយខ្លួនឯងហើយ បានយកព្រះឱវាទនោះទៅពន្យល់ប្រៀនប្រដៅបរិស័ទបន្តទៅទៀត ។ ព្រះសង្ឃទុកជាស្រែបុណ្យ យ៉ាងសំខាន់ណាស់



ដែលកាលណាគេយកពូជ គឺកុសលទៅផ្សាំបណ្តុះលើស្រែបុណ្យនោះហើយ ពិតជាបានផលមកវិញយ៉ាងច្រើន ព្រោះស្រែបុណ្យនេះមានជីជាតិច្រើន , ព្រះសង្ឃជាអ្នកមានសីលប្រចាំនៅក្នុងខ្លួន. ទុកដូចជាស្រែមានជីជាតិដែរ ។

## អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង

**ស**– ចូរពន្យល់នូវអាការៈមួយ ៗ ដែលព្រះពុទ្ធទ្រង់ប្រដៅនោះឲ្យឆាយស្តាប់មកមើល !

**ឆ**– អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាងនោះមានលក្ខណៈនិងហេតុផលដូចនេះគឺ :

**១– អភិញ្ញាយ** ដើម្បីឲ្យអ្នកស្តាប់ដឹងពិត ឃើញពិត ក្នុងធម៌គួរដឹងគួរឃើញ បានសេចក្តីថា: ព្រះពុទ្ធបានយកការពន្យល់ណែនាំផ្សេងៗ ទៅដឹកនាំសត្វលោក តាមរយៈប្រាជ្ញាសម្មាសម្ពោធិញ្ញាណរបស់ព្រះអង្គ ឲ្យសត្វលោកឃើញពិត ដឹងពិត ព្រោះព្រះអង្គបានចេះដឹងច្បាស់ដឹងពិតៗ ដែរ ។ ក្នុងការប្រៀនប្រដៅដឹកនាំនេះ ព្រះអង្គគ្មានគិតប្រយោជន៍អ្វីឡើយ តែដើម្បីឲ្យមនុស្សសត្វបានយល់ចេះដឹងស្គាល់ពិត ៗ តែប៉ុណ្ណោះ ។ ហេតុដែលធ្វើយ៉ាងនេះគឺគ្មានអ្វី ក្រៅពីព្រះអង្គមានព្រះទ័យពោរពេញទៅដោយព្រហ្មវិហារធម៌ចំពោះសត្វលោកនោះឡើយ ។

**២– សនិទាន** - ទ្រង់ប្រៀនប្រដៅដឹកនាំសត្វលោកប្រកបដោយ

ហេតុពោលគឺ កាលអ្នកស្ដាប់ ៗ បានស្ដាប់ៗហើយត្រិះរិះពិចារណាទៅក៏ឃើញពិតតាមនោះ ដូចជាការពន្យល់ឲ្យមនុស្សធ្វើទាន លះក្ដីកំណាញ់ចេញពីសន្ដានចិត្ត កាលណាមនុស្សបានធ្វើតាមក៏មានចិត្តរីករាយត្រេកអរតាមនោះទៅ ។

**៣– សប្បដិហារ**– ទ្រង់ប្រៀនប្រដៅប្រកបដោយលក្ខណៈអស្ចារ្យ ពោលគឺអ្នកស្ដាប់ អ្នកធ្វើ បានស្ដាប់ បានប្រព្រឹត្តធ្វើតាម នឹងបានសម្រេចប្រយោជន៍សមតាមប្រាថ្នា មិនលើស មិនខ្វះឡើយ ។

បែបនៃការប្រៀនប្រដៅទាំង ៣ នេះ ព្រះពុទ្ធតែងយកទៅអនុវត្ត ហើយតែងឲ្យអ្នកស្ដាប់ អ្នកប្រតិបត្តិតាមសម្រេចផលប្រយោជន៍ជានិច្ច ។

## ឱវាទរបស់ព្រះពុទ្ធ ៣ យ៉ាង

**ស**– ពាក្យថា ឱវាទ មានន័យថាដូចម្ដេច ? ពាក្យទេសនា និងឱវាទដូចគ្នា ឬផ្សេងគ្នា ? ចូរពន្យល់ !

**ឆ**– ពាក្យថា ឱវាទ មានន័យថា ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ, ពាក្យទូន្មាន ការទូន្មាន, សំដៅសេចក្ដីថា ការបញ្ញត្តិហាមប្រាម មិនឲ្យប្រព្រឹត្តខុសល្មើសផ្សេងៗ ។ ឯពាក្យ ទេសនា សំដៅសេចក្ដីថា ការសំដែង គឺ សំដែងធម៌កថា, ពន្យល់ន័យសេចក្ដីចំពោះធម៌កថាណា ដោយទាញយកហេតុផល មកបញ្ជាក់ផង ទាញពាក្យទូន្មានមកធ្វើជាឧទាហរណ៍ផង ទាញចេញបញ្ញត្តិផ្សេងៗ មកជាសំអាងផង ។



**ស**– ចុះឱវាទ ៣ យ៉ាងរបស់ព្រះពុទ្ធនោះ តើដូចម្ដេច ? អ្វីខ្លះ? ចូរពន្យល់

**ឆ**– ឱវាទ គឺការប្រៀនប្រដៅរបស់ព្រះពុទ្ធ ៣ យ៉ាងនោះគឺ ៖

**១– សព្វបាបស្ស អករណំ**– ទ្រង់ហាមមិនឲ្យធ្វើបាបទាំងពួង ពោលគឺកុំឲ្យប្រព្រឹត្តអាក្រក់គ្រប់យ៉ាង មានប្រព្រឹត្តអកុសលកម្មបថ ១០ ជាដើម ។

**២– កុសលស្សូបសម្បទា** ទ្រង់ឲ្យបំពេញកុសលធម៌ទាំងពួង ពោលគឺ ឲ្យប្រព្រឹត្តបំពេញកុសលកម្មបថ ១០ ប្រការជាដើម ។

**៣– សចិត្តបរិយោទបនំ** ទ្រង់ហាមឲ្យជម្រះចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ កុំឲ្យសៅហ្មង ជាប់ជំពាក់នឹងកាមកិលេសគ្រប់យ៉ាង ។

**ស**– ឱវាទទាំង ៣ នេះ បើសង្គ្រោះចូលក្នុងបិដកវិញ តើឱវាទណាសង្គ្រោះ ចូលក្នុងបិដកណា ?

**ឆ**– បើសង្គ្រោះចូលក្នុងបិដកទាំង ៣ វិញ សព្វបាបស្ស អករណំ សង្គ្រោះចូលក្នុងវិន័យបិដក, កុសលស្សូបសម្បទា សង្គ្រោះចូលក្នុងព្រះសុត្តន្តបិដក សចិត្តបរិយោទបនំ សង្គ្រោះចូលក្នុងព្រះអភិធម្មបិដក ។

## ទុច្ចរិត ៣ យ៉ាង

**ស**– ទុច្ចរិត ៣ យ៉ាងគឺអ្វីខ្លះ ? ចូររាប់

**ឆ**– ទុច្ចរិត ៣ យ៉ាងនោះគឺ

**១– កាយទុច្ចរិត.–** ការប្រព្រឹត្តអាក្រក់ដោយកាយ ។

**២– វចីទុច្ចរិត.–** ការប្រព្រឹត្តិអាក្រក់ដោយសំដី ។

**៣– មនោទុច្ចរិត.–** ការប្រព្រឹត្តិអាក្រក់ដោយចិត្ត ។

**ស–** ការប្រព្រឹត្តខុសទាំង ៣ យ៉ាងនេះ តើប្រព្រឹត្តខុសដូចម្ដេចខ្លះ ចូរពន្យល់ !

**ឆ–** ការប្រព្រឹត្តខុសទាំង ៣ យ៉ាងនោះគឺ :

**១– កាយទុច្ចរិត** បានការសម្លាប់សត្វ ១, លួចទ្រព្យគេ ១, លួចប្រព្រឹត្តខុសជាមួយប្រពន្ធកូនអ្នកដទៃ ១ ។

**២– វចីទុច្ចរិត** ការប្រព្រឹត្តិខុសដោយសំដី បានដល់ការនិយាយកុហក ១ និយាយញុះញង់ ១ និយាយពាក់ដោត ១ និយាយពាក្យពេលឥតប្រយោជន៍ ១ ។

**៣– មនោទុច្ចរិត** បានដល់ការចង់បានរបស់គេក្នុងហេតុដែលមិនគួរចង់ ឬដោយខុសច្បាប់ ១ ប្រទូស្តបៀតបៀនគេដោយចិត្តអាក្រក់ ១ និងការយល់ឃើញខុសផ្ទុយពីហេតុពិត ១

**ស–** ផលអាក្រក់ ដែលកើតចេញពីទុច្ចរិតទាំង ៣ នេះដូចគ្នា ឬផ្សេងគ្នា ? បើផ្សេង តើដូចម្ដេចខ្លះ ?

**ឆ–** ផ្សេងគ្នា ពោលគឺអ្នកប្រព្រឹត្តខុសក្នុងកាយទុច្ចរិត នឹងមានអាយុខ្លី, ក្រទ្រព្យសម្បត្តិ, អ្នកប្រព្រឹត្តខុសក្នុងវចីទុច្ចរិត នឹងជាមនុស្សមានរូបអាក្រក់មាត់ស្អុយ, ឯអ្នកប្រព្រឹត្តខុសក្នុងមនោទុច្ចរិត នឹងបានជាមនុស្សអាប់ប្រាជ្ញា ។



## សុចរិត ៣ យ៉ាង

**ស–** សុចរិត ផ្ទុយពីទុច្ចរិតយ៉ាងណា ?

**ឆ** សុចរិត គឺជាការប្រព្រឹត្តល្អ, ការកាន់ឬប្រព្រឹត្តល្អ ដោយកាយវាចាចិត្តនេះឯង ។

**ស–** ពាក្យថា សុចរិត, កុសលបុណ្យ ដូចគ្នាឬផ្សេងគ្នា ? ចូរពន្យល់ !

**ឆ–** ពាក្យទាំង ៣ មានន័យផ្សេងគ្នា ពោលគឺ ៖

– សុចរិត បានដល់ការប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ឬប្រព្រឹត្តកុសលកម្មបថទាំង១០ ។ ឯពាក្យថា កុសលគឺអំពើនៃការប្រព្រឹត្តល្អនោះឯង ចំណែកខាងបុណ្យវិញគឺជាផលនៃអំពើល្អ ដែលជាកុសលនោះឯង ។

## អកុសលមូល ៣ យ៉ាង

**១– លោភៈ** ចង់បានរបស់គេ ។

**២– ទោសៈ** គំនិតគិតបៀតបៀនគេ ។

**៣– មោហៈ** វង្វេងមិនដឹងជាក់ពិត ។

**ស–** ពាក្យថាអកុសលមូល មានន័យដូចម្ដេច ? ចូរពន្យល់ !

**ឆ–** អកុសលមូល មានន័យថាឫសគល់នៃអំពើអាក្រក់ ពោលគឺអំ

ពើអាក្រក់គ្រប់យ៉ាងទាំងអស់ សុទ្ធតែមានប្រភព មានដើមចមចេញមកពីលោភៈ ទោសៈ មោហៈ នេះទាំងអស់ ឬមូល លោភៈ ទោសៈ មោហៈ នេះ ជាមូលដ្ឋានទ្រទ្រង់អកុសលធម៌ទាំងអស់ ឲ្យមានសកម្មភាពទៅកើត ។

**ស**– អកុសលមូលទាំង៣មានន័យផ្សេងគ្នាយ៉ាងណា? ចូរអធិប្បាយ

**ឆ**– មានន័យផ្សេងគ្នាយ៉ាងនេះគឺ ៖

– **លោភៈ** ចំណង់បានទ្រព្យរបស់អ្នកដទៃក្នុងហេតុដែលមិនគួរចង់ ឬ ចង់បានអ្វី ៗ របស់គេដោយចិត្តឈ្លានពាន ។ កាលមានចំណង់ចង់បានហើយ តែមិនបានដូចបំណងក៏មានចិត្ត ទោមនស្សអន្ទះអន្ទែងគិតរិះរកមធ្យោបាយយ៉ាងណាឲ្យបានរបស់នោះមកធ្វើជារបស់ខ្លួន ។

– **ទោសៈ** បានដល់កំហឹងខឹងប្រឡោតតោតតូង ហើយ គិតរកមធ្យោបាយបៀតបៀនគេ ដើម្បីឲ្យគេវិនាសអន្តរាយ ស្របតាមកំហឹងរបស់ខ្លួន ។

– **មោហៈ** បានដល់ការវង្វេងភ័ន្តច្រឡំយល់ល្អថាអាក្រក់ យល់អាក្រក់ថាល្អ មិនដឹងហេតុផលដែលនាំឲ្យចំរើនវិនាសយ៉ាងណា ៗ សោះឡើយ ។

អកុសលមូលទាំង ៣ នេះជាតួអកុសលធម៌ នាំឲ្យមនុស្សសត្វប្រព្រឹត្តធ្វើអំពើបាបអាក្រក់គ្រប់យ៉ាងបានយ៉ាងងាយ ។



## កុសលមូល ៣ យ៉ាង

**១– អលោភ** មិនចង់បានរបស់អ្នកដទៃ ដោយខុសច្បាប់ ។

**២– អទោសៈ** មិនក្រោធខឹង ឬប្រទូសរាយគេ ។

**៣– អមោហៈ** មិនវង្វេងភ័ន្តច្រឡំ

កុសលមូលទាំង ៣ នេះជាឫសគល់នៃសេចក្ដីល្អ ផ្ទុយនឹងអកុសលមូលទាំង ៣ ខាងដើម ។

## សប្បុរិសបញ្ញត្តិ ៣ យ៉ាង

**១– ទាន**៖ ការឲ្យទ្រព្យរបស់ខ្លួនទៅជាអំណោយចំពោះអ្នកដទៃ ។

**២– បព្វជ្ជា** ការចេញបួស ។

**៣– មាតាបិតុឧបដ្ឋាន** ការទំនុកបំរុងម្ដាយឪពុក ។

**ស** ពាក្យថា សប្បុរិសបញ្ញត្តិប្រែថាដូចម្ដេច ? ចូរពន្យល់ !

**ឆ**– ប្រែថា បម្រាមរបស់សប្បុរស ច្បាប់សម្រាប់សប្បុរស ឬក៏គោលការណ៍ ដែលសម្រាប់ធ្វើខ្លួនឲ្យទៅជាជនល្អ មានធម៌នៅក្នុងខ្លួន ។

សប្បុរិសបញ្ញតិមាន ៣ យ៉ាងគឺ ៖

**១ – ទាន ៖** ការចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅអ្នកដទៃ ដែលគ្មានទ្រព្យដូចខ្លួនដើម្បីឲ្យអ្នកនោះដែលជាជនកំព្រា ឬក្រីក្រល្ហេមល្ហាម បានទទួលយកទៅស៊ីចុកប្រើប្រាស់បានស្រួលខ្លួន ស្រួលចិត្ត ធូរកម្លាំងបន្តិចផង ។ ទាននេះជាការរំលែកសុខ ឲ្យអ្នកក្រីក្រគោកយ៉ាកនេះឯង ។

ហើយចំពោះអ្នកមានសីល ទោះគ្រហស្ថ ឬ បព្វជិត សុទ្ធតែមានផលប្រសើរណាស់ ។

**២– បព្វជ្ជា.-** ការចេញបួសចាកកាមកិលេសពីគ្រហស្ថ ទៅជាបព្វជិត ដើម្បីលះបង់កិច្ចកង្វល់គ្រប់យ៉ាង ហើយសម្ងំក្នុងទីស្ងប់ស្ងាត់ ប្រព្រឹត្តធម៌ កាន់វិន័យ ក្រិត្យក្រម ឲ្យបានត្រឹមត្រូវ ។

**៣– មាតាបិតុបដ្ឋាន.-** ការទំនុកបំរុងមាតាបិតាដែលជាបុព្វការីជន ឲ្យលោកបានធូរស្រាលកម្លាំង ដកកិច្ចរវល់ចេញពីការងារផ្សេងៗ ដែលលោកធ្លាប់ធ្វើ ឲ្យត្រឡប់មកនៅសំងំកាយ ឬ រក្សាសីល កាន់វិន័យ ដើម្បីសាងផ្លូវទៅកាន់សុគតិភពទៀត ។

**សួ -** បញ្ញត្តិទាំង ៣ យ៉ាងនេះ តើត្រូវធ្វើទាំង ៣ ទើបគ្រប់អង្គជាសប្បុរស ឬធ្វើតែមួយ ពីរបានដែរ ? បើបានព្រោះហេតុអ្វី ?

**ឆ -** ធ្វើតែមួយក៏បាន ពីរក៏បាន ឬធ្វើទាំង ៣ ក៏បាន ។ ប៉ុន្តែទីង ខានធ្វើមិនបានទេ ឧទាហរណ៍អ្នកខ្លះមានទ្រព្យច្រើន, ជាប់កង្វល់ក្នុងគ្រួសារខ្លាំងពេក មិនអាចចេញទៅបួសបាន ហើយមាតាបិតាក៏ស្លាប់ទៅ គ្រាន់តែឲ្យទានរួចឧទ្ទិសផលទៅមាតាបិតាក៏បាន ។ ខ្លះទៀតគ្មានទ្រព្យ មាតាបិតាស្លាប់អស់តែអាចចេញបួសបានក៏ត្រូវចេញបួសទៅ ។

## អបណ្ណកប្បដិបទា ៣ យ៉ាង

**១– ឥន្ទ្រិយសំវរៈ** ការសង្រួមឥន្ទ្រិយ



**២- ភោជនេ មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជនាហារ ។

**៣– ជាគរិយានុយោគ** ភ្ញាក់រលឹកជានិច្ច ។

**សួ –** ចូរពន្យល់ពាក្យថា អបណ្ណកប្បដិបទា ឲ្យស្ដាប់បានព្រមទាំងធ្វើអត្ថាធិប្បាយឲ្យល្អមស្ដាប់ផង !

**ឆ–** អបណ្ណកប្បដិបទា មានន័យថាការប្រព្រឹត្តិប្រតិបត្តិមិនខុស ពោលគឺ ៖

– ឥន្ទ្រិយសំវរ ការសង្រួមឥន្ទ្រិយទាំង ៦ មានភ្នែក ត្រចៀក ច្រមុះ ជាដើម ដើម្បីកុំឲ្យគ្រឿងអាយតនៈ ទាំងនេះ ទៅប៉ះនឹងអារម្មណ៍ខាងក្រៅមានរូបសម្លេង ជាដើម ដែលជាហេតុនាំឲ្យមានការសៅហ្មងដល់ចិត្ត កើតទោមនស្ស ឬសោមនស្ស ។

– ភោជនេ មត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណក្នុងអាហារភោជន ពោលគឺកាលបរិភោគអាហារ ត្រូវដឹងប្រមាណក្នុងអាហារ កុំបរិភោគច្រើនហួសប្រមាណ ឬបរិភោគដោយស្មោគគ្រោគពេក ជាហេតុនាំឲ្យកើតជម្ងឺឈឺថ្កាត់ផ្សេងៗ ក៏មាន នាំឲ្យសុខភាពចុះអន់ថយព្រោះពោះធ្វើទុក្ខក៏មាន ។

– ជាគរិយានុយោគ ការភ្ញាក់រលឹកជានិច្ច ពោលគឺមិនដេកច្រើន ឬដេកទ្រមក់ហួសប្រមាណ ដែលជាហេតុនាំឲ្យខាតប្រយោជន៍ ។

ការប្រតិបត្តិតាមគោលការដូចពោលនេះ ហៅថាប្រតិបត្តិមិនខុស ហើយជាបុព្វហេតុនាំឲ្យកិច្ចការ សេចក្តីព្យាយាមបានសម្រេចប្រយោជន៍ផង ។

## បុញ្ញកិរិយាវត្ថុ ៣ យ៉ាង

**១– ទានមយ** : បុណ្យកើតដោយសារធ្វើទាន ។

**២– សីលមយ** : បុណ្យកើតដោយសារការរក្សាសីល ។

**៣– ភាវនាមយ** : បុណ្យកើតដោយសារការចំរើនធម៌ ។

**ស**– បុណ្យកើតដោយហេតុ ៣ យ៉ាងនេះមែនហើយ ប៉ុន្តែបើបុគ្គលធ្វើតែមួយៗ បានទេ ? ព្រោះអ្វី ?

**ឆ** – បើបុគ្គលធ្វើតែមួយៗ ក៏បានបុណ្យដូចគ្នា គ្រាន់តែឲ្យផលផ្សេងគ្នាប៉ុណ្ណោះ បានសេចក្តីថា បើធ្វើទានក៏បានបុណ្យតាមរយៈទាន ៗ នោះទៅ បើរក្សាសីល ក៏បានបុណ្យតាមរយៈសីលនោះដែរ ។

**ស**– បើដូច្នោះ តើកត្តាទាំង ៣ នេះឲ្យផលផ្សេងគ្នា ឬដូចគ្នា ? បើផ្សេងតើកត្តាមួយ ៗ ឲ្យផលដូចម្តេច ? ចូរបង្ហាញ !

**ឆ** – ឲ្យផលជាបុណ្យកុសលមិនដូចគ្នាទេ ពោលគឺ ៖

– អ្នកធ្វើទាន នឹងបានភោគសម្ប័ទ បរិវារសម្ប័ទច្រើនទៅអនាគតកាល ។

– អ្នករក្សាសីល នឹងមានអាយុវែង មានរូបល្អទៅអនាគតកាល ។



– ឯអ្នកចំរើន ភាវនា នឹងមានប្រាជ្ញាច្រើន ក្នុងអនាគតជាតិ ៗ មិនតែប៉ុណ្ណោះ ទាន និង សីលអាចនាំឲ្យសម្រេចមគ្គ ៣ ខាងដើម ឯភាវនាអាចឲ្យសម្រេច ១ ខាងចុង គឺ អរហត្តមគ្គថែមទៀត ។ ដូច្នេះ ភាវនា ជាមេបុណ្យដែលមានកម្លាំងជាងទាន និង សីល ។ ប៉ុន្តែនឹងអាចសំរេចមគ្គជាន់លើនេះបាន តោងអាស្រ័យ ទាន សីលផងដែរ ៗ ដូច្នេះមេបុណ្យទាំង ៣ នេះ មានការទាក់ទងគ្នាយ៉ាងជិតជិត ។

## សាមញ្ញលក្ខណៈ ៣ យ៉ាង

**១– អនិច្ចតា** ភាពមិនទៀងទាត់

**២– ទុក្ខតា** ភាពជាទុក្ខ ។

**៣– អនត្តតា** ភាពមិនមែនជាខ្លួនប្រាណ ។

**ស** – អ្វីខ្លះដែលស្ថិតនៅក្រោមអំណាចនៃលក្ខណៈទាំង ៣ នេះ ។

**ឆ** – អ្វីទាំងអស់ ដែលសង្ខារតាក់តែងបានទាំង ឧបាទិន្នកសង្ខារ ដូចរូបមនុស្ស សត្វ ដែលមានវិញ្ញាណគ្រប់គ្រង ទាំងអនុបាទិន្នកសង្ខារ ដូចរថយន្ត, ផ្ទះជាដើម ដែលគ្មានវិញ្ញាណគ្រប់គ្រង សុទ្ធតែស្ថិតនៅក្រោមអំណាចនៃសាមញ្ញលក្ខណៈទាំង ៣ នេះ ជាដរាប ៗ ភាពមិនទៀង, ជាទុក្ខ, និងមិនមែនខ្លួនប្រាណនេះតែងមានទូទៅចំពោះមនុស្ស, សត្វ រុក្ខជាតិទាំង គឺជាធម៌ទូទៅមិនមែនជារបស់ជនណាម្នាក់, សត្វ ឬវត្ថុណាមួយ ឬ ក៏របស់អ្នកស្រុកតែមួយៗ ត្រកូលតែមួយៗឡើយ ។

ចប់តិកៈពួកធម៌ ៣

# ចតុក្កៈ ពួកធម៌ ៤

## វុឌ្ឍិធម៌ ៤ យ៉ាង

**ស** – វុឌ្ឍិធម៌ មានន័យយ៉ាងម៉េច ? អ្វីខ្លះ ?

**ឆ** – វុឌ្ឍិធម៌ មានន័យថា ធម៌ដែលនាំឲ្យចំរើន , ធម៌ជាគ្រឿងដែលនាំឲ្យបុគ្គលបានចំរើន កាលណាបុគ្គលបានប្រព្រឹត្តហើយ ។ វុឌ្ឍិធម៌ទាំង ៤ យ៉ាងនោះគឺ :

១ – **សប្បុរិសូបសំសេវៈ** សេពគប់ជាមួយជនជាសប្បុរស ។

២ – **ធម្មស្សវនៈ** ស្តាប់ពាក្យប្រៀនប្រដៅរបស់សប្បុរសដោយយកចិត្តទុកដាក់ ។

៣ – **យោនិសោមនសិការៈ** យកចិត្តទុកដាក់ ដើម្បីស្គាល់បញ្ហាអាក្រក់ផ្សេងៗ ហើយដើរទៅរកផ្លូវត្រូវ ។

៤ – **ធម្មានុធម្មប្បដិបត្តិ** ប្រព្រឹត្តប្រតិបត្តតាមសមគួរដល់ធម៌ដែលខ្លួនបានត្រិះរិះពិចារណាឃើញ ។

**ស** – ពាក្យថាសប្បុរស បានដល់ជនប្រភេទណា ?

**ឆ** – សប្បុរស គឺជនដែលមានសន្តានចិត្តល្អជានិច្ច , ធ្វើការអ្វីដោយវាចាចិត្ត ល្អជានិច្ច មិនប្រព្រឹត្តអកុសលកម្មចបជាដើម ។

**ស** – សប្បុរស និងបណ្ឌិត ដូចគ្នា ឬ ផ្សេងគ្នា ?

**ឆ** – ដូចគ្នាក៏បាន ផ្សេងគ្នាក៏បាន ។ ដែលថាដូចគ្នា ព្រោះសប្បុ-



រស និងបណ្ឌិត ជាអ្នកមានសន្តានចិត្តស្អាតស្អំដូចគ្នា ។ ថាផ្សេងគ្នា ព្រោះបណ្ឌិតស្អាតស្អំផង មានចំណេះវិជ្ជាច្រើន អាចដឹកនាំអ្នកផងឲ្យចេះដឹង និងឲ្យប្រព្រឹត្តល្អផង ។

**ស** – សប្បុរស និង បណ្ឌិត មានលក្ខណៈ ដូចម្តេច ដែលគួរឲ្យស្គាល់បាន ?

**ឆ** – មានលក្ខណៈ ៣ យ៉ាង ដែលអាចឲ្យសំគាល់បានគឺ :

១ – **សុចិន្តិតចិន្តី** .– គិតការអ្វីៗ គិតតែការងារណាដែលល្អ

២ – **សុភាសិតភាសី** .– និយាយសំដីអ្វីៗ សុទ្ធតែសំដីល្អ ។

៣ – **សុកដកម្មការី** បើធ្វើការអ្វីៗ ធ្វើតែការងារណាដែលល្អ ។

**ស** – ធម៌ទាំង ៤ យ៉ាងនេះ បុគ្គលត្រូវប្រព្រឹត្តគ្រប់ទាំង ៤ ទើបបានចំរើន ឬ ក៏ប្រព្រឹត្តតែមួយក៏បានចំរើនដែរ ? ព្រោះអ្វី ?

**ឆ** – ទាល់តែប្រព្រឹត្តគ្រប់ទាំង ៤ ទើបបានទទួលសេចក្តីចំរើន ព្រោះបើគ្រាន់តែសេពគប់នឹងសប្បុរសតែមិនបានស្តាប់ធម៌ជាពាក្យ ប្រៀនប្រដៅរបស់លោកទេ ឬ ក៏ស្តាប់ដែរ តែមិនចេះត្រិះរិះពិចារណា , មិនប្រព្រឹត្តតាម ក៏មិនទទួលការចំរើនដែរ ។

**ស** – ចំរើនបែបណា ចំរើនដោយទ្រព្យសម្បត្តិ ឬ ចំរើនដោយអ្វី?

**ឆ** – ទ្រព្យសម្បត្តិក៏ចំរើន សេចក្តីសុខក៏ចំរើន , ប្រាជ្ញាស្មារតីក៏ចំរើន ។

## ចក្កធម៌ ៤ យ៉ាង

ស — ចក្កធម៌ គឺធម៌ដូចម្ដេច ? អ្វីខ្លះ ?

ឆ — ចក្កធម៌ គឺធម៌ដែលនាំបុគ្គលឲ្យវិលទៅរកសេចក្ដីចំរើន ដូចកង់រថដែលវិលនាំតួរថ និងអ្នកជិះឲ្យដល់ទីសុខសាន្តដូច្នេះឯង ។ ចក្កធម៌ ៤ យ៉ាងនោះគឺ:

១ — **បដិរូបទេសវាសៈ** ស្ថិតនៅក្នុងទីដ៏សមគួរ ។

២ — **សប្បុរិសូបសំសេវៈ** សេពគប់នឹងសប្បុរស ។

៣ — **អត្តសម្មាបណិធិ** តាំងខ្លួនដោយប្រពៃ ។

៤ — **បុព្វេកតបុញ្ញតា** ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងពេលមុន ។

ស — ការនៅក្នុងប្រទេសដ៏សមគួរ និងការតាំងខ្លួនដោយប្រពៃនោះ តើមានលក្ខណៈយ៉ាងណា ?

ឆ — ការនៅក្នុងទីស្ថាន ឬស្រុកទេសដែលសមគួរនោះ គឺបុគ្គលត្រូវបេះរើសរកស្រុកទេស ភូមិស្ថានណាដែលងាយរកស៊ីចុកប្រកបការងាររបស់ខ្លួនផង ជាទីដែលនាំឲ្យសប្បាយផង ជាពិសេសគឺ ទីកន្លែងណាដែលមានជនជាសប្បុរសរស់នៅច្រើន ។ ឯការតាំងខ្លួនដោយប្រពៃនោះ គឺការតាំងខ្លួននៅក្នុងកុសលធម៌ ក្នុងសុចរិតធម៌គ្រប់យ៉ាងដែលជាអំពើល្អនោះឯង ។

ស — ធម៌ទាំង ៤ យ៉ាងនេះ ត្រូវមានទាំង ៤ ឬមានតែមួយ ៗ ក៏បានដែរ ? ព្រោះអ្វី ?



ឆ — ត្រូវតែមានទាំង ៤ ទើបអាចវិលនាំទៅកាន់សេចក្ដីចំរើនបាន ដូចកង់នៃរថយន្តមួយទាល់តែមានគ្រប់ទាំង ៤ ទើបអាចបើកបរទៅបាន ។

## អគតិ ៤ យ៉ាង

ពាក្យថា អគតិ មានន័យថាម៉េច ? អ្វីខ្លះ ?

ឆ — ពាក្យថា អគតិ មានន័យថាដំណើរលំអៀង, ចិត្តលំអៀងឬចិត្តទោរទន់ទៅលើអ្វីមួយដោយហេតុផ្សេងៗ ។ អគតិ ៤ យ៉ាងនោះគឺ:

១ — **ឆន្ទាគតិ** លំអៀងព្រោះការស្រឡាញ់ពេញចិត្ត ។

២ — **ទោសាគតិ** លំអៀងព្រោះកំហឹង ។

៣ — **មោហាគតិ** លំអៀងព្រោះល្ងង់ ។

៤ — **ភយាគតិ** លំអៀងព្រោះខ្លាច ។

ស — លំអៀងទាំង ៤ យ៉ាងនេះ ច្រើនស្ថិតនៅលើបុគ្គលណា ? ហើយក្នុងករណីណា ?

ឆ — ច្រើននៅលើអ្នកអាណាព្យាបាល, អ្នកដែលជាមេបាគេ, អ្នកកាត់សេចក្ដី ក្នុងករណីដែលចែកទ្រព្យសម្បត្តិ, ចែកមុខងារឲ្យធ្វើ និងកាត់សេចក្ដីក្នុងរឿងរ៉ាវណា ១ ។ បុគ្គលប៉ុន្មានពួកនេះ កាលចែកទ្រព្យ, កាលចែកមុខងារឲ្យធ្វើឬកាលកាត់សេចក្ដីច្រើនតែស្ថិតនៅលើការស្រឡាញ់, ការស្អប់ឬខឹង ព្រោះមានគំនុំគុំគួនចងព្យាបាទព្រោះល្ងង់

វង្វេងមិនយល់ច្បាប់ , ព្រោះភ័យខ្លាចចំពោះបុណ្យស័ក្តិឬទ្រព្យសម្បត្តិ ។ ដោយមានកត្តាទាំង ៤ នេះហើយទើបមេធា ឬ ចៅក្រមអ្នកកាត់សេចក្តីច្រើនធ្វើកិច្ចការរបស់ខ្លួនឲ្យខុសឆ្គងហាកគន្លងធម៌ និងការពិតប្រាកដ ។

## អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី ៤ យ៉ាង

១ – អត់ធន់ចំពោះពាក្យទូន្មានមិនបាន ខ្ជិលធ្វើតាម ។

២ . ឃើញតែការបរិភោគជាប្រមាណ អត់ធន់នឹងសេចក្តីស្រេកឃ្លានមិនបាន ។

៣ ត្រេកអរក្នុងកាមគុណ ដោយការចង់បានសេចក្តីសុខយ៉ាងលើសលុប ។

៤ – ស្រឡាញ់ស្ត្រីភេទ ។

**ស** – អន្តរាយទាំង ៤ នេះទាល់តែកើតឡើងគ្រប់ទាំង ៤ ទើបអ្នកបួសថ្មីទទួលក្តីអន្តរាយឬកើតតែមួយណាក៏ទទួលក្តីអន្តរាយដែរ ? ព្រោះអ្វី?

**ឆ** – កើតតែមួយ ក៏អាចទទួលក្តីអន្តរាយបានដែរ ព្រោះអ្នកបួសថ្មីដែលធ្លាប់នៅជាគ្រហស្ថអាចធ្វើអ្វី ៗ បានតាមចិត្ត លុះចូលមកបួសក្នុងព្រះពុទ្ធសាសនាដែលមានច្បាប់មានវិន័យហាមប្រាមតឹងរ៉ឹង ក៏អត់ធន់នឹងពាក្យទូន្មានប្រៀនប្រដៅនោះមិនបាន រួចលាសិក្ខាបទទៅ ឬមួយអ្នកខ្លះធ្លាប់នៅជាគ្រហស្ថ ធ្លាប់ដេកធ្លាប់បរិភោគ តាមចិត្តចង់គ្រប់ពេលវេលាបាន លុះបួសជាសមណៈ ក៏មានច្បាប់វិន័យ កំណត់ឲ្យដេកបរិភោគមាន



ពេលវេលា ក៏អត់ទ្រាំមិនបាន ឬមួយអ្នកបួសខ្លះដែលបួសហើយតែ នៅជាប់ចិត្តស្រឡាញ់ស្ត្រីភេទខ្លាំងពេក ឃើញគេមានរូបល្អ ក៏ស្រឡាញ់ចង់បានយកមកជាគូស្នេហ៍ស្និទ្ធរួបរ័ក្សមេត្រី ហើយអត់ទ្រាំមិនបាន ក៏លាចាកផ្នួសទៅ ។ បែបនេះហើយដែលនាំឲ្យអ្នកបួសទទួលក្តីអន្តរាយ ទោះកត្តាណា ១ កើតឡើងក៏ដោយ ។

## បធាន ៤ យ៉ាង

**ស** – បធានៈ គឺអ្វី ? ចូរពន្យល់

**ឆ** – បធាន គឺ សេចក្តីព្យាយាមរក្សាបុណ្យ និង ព្យាយាមលះបាប ឲ្យជ្រះពីសន្តានចិត្តនេះឯង ។ បធាននេះគឺ :

១ – **សំវរប្បធាន** . – ព្យាយាមមិនឲ្យបាបកើតឡើងក្នុងសន្តានចិត្ត ។

២ – **បហានប្បធាន** . – ព្យាយាមលះបាបដែលកើតឡើងក្នុងចិត្តរួចហើយឲ្យជ្រះស្រឡះទៅវិញ ។

៣ – **ភាវនាបធាន**. – ព្យាយាមធ្វើសន្សំបុណ្យឲ្យកើតឡើងក្នុងសន្តានចិត្ត ។

៤ – **អនុរក្ខនាបធាន**. – ព្យាយាមរក្សាបុណ្យកុសលដែលកើតឡើងរួចហើយឲ្យនៅគង់វង់ក្នុងសន្តានចិត្ត ។

**ស** – ពាក្យព្យាយាម ក្នុងបាលីមានច្រើន ចុះពាក្យថា បធានៈ

នេះដូចព្យាយាមឯទៀត ៗ ដែរ ឬ ផ្សេងគ្នា ? បើផ្សេងតើផ្សេងយ៉ាងណា? ចូរលើកឧទាហរណ៍មកពន្យល់ !

**ឆ** — មានច្រើនមែនប៉ុន្តែពាក្យថា បធាន: និងពាក្យឯទៀតដែលប្រែថា ព្យាយាមដូចគ្នានោះ មានន័យផ្សេងគ្នាបន្តិច ៗ គឺ:

**បធាន:** ព្យាយាមលះបាប និង ព្យាយាមសន្សំបុណ្យ ដែលជាគុណសម្បត្តិ និង ជាគុណវិបត្តិនៅក្នុងខ្លួនមនុស្សម្នាក់ ៗ ។

**វីរិយ:** ព្យាយាមខាងផ្លូវ កាយ និង វាចា ដូចជាព្យាយាមរៀនសូត្រ គិតគូរពិចារណារកអ្វីមួយ ។

**ជាគរិយានុយោគ:** ព្យាយាមដោយការភ្ញាក់រលឹកដឹងខ្លួនជានិច្ច មិនដេកលក់ ឬ ទ្រមក់ងោកងុយ ។

**ឧដ្ឋាន:** ព្យាយាមធ្វើការងារដើម្បីផលប្រយោជន៍ដ៏សំខាន់សម្រាប់ជីវភាពខ្លួន ។

**ស** — ព្យាយាមមានអ្វីជាគូគ្នាដែរ ឬ ទេ ? ព្រោះអ្វី ?

**ឆ** — មានសតិសម្បជញ្ញៈជាគូ ព្រោះសតិសម្បជញ្ញៈ អាចធ្វើឲ្យព្យាយាមបានសម្រេចផលប្រយោជន៍គ្រប់យ៉ាង បើអ្នកណាមានស្មារតីដឹងខ្លួនចំពោះកិច្ចការហើយ សេចក្ដីព្យាយាមនោះ នឹងហុចផលឲ្យនៅទីបំផុតមិនខាន ដូចព្រះសិទ្ធត្ថពោធិសត្វ ដែលមានព្យាយាម ហើយទ្រង់មានស្មារតីជានិច្ច អស់ពេល ៦ ឆ្នាំ នៅទីបំផុតក៏ទ្រង់បានត្រាស់



ដឹងនូវប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ដូចព្រះបំណង ។

## អធិដ្ឋានធម៌ ៤ យ៉ាង

**ស** — ពាក្យថា អធិដ្ឋានធម៌ បានន័យថាម៉េច ? ចូរពន្យល់ និងរាប់ !

**ឆ** — អធិដ្ឋានធម៌ គឺធម៌ដែលបុគ្គលគួរតាំងទុកក្នុងចិត្តឲ្យបានមាំ ។ អធិដ្ឋាននេះទាក់ទងនឹងផ្លូវចិត្ត ជាងផ្លូវកាយឬវាចា ។ អធិដ្ឋានធម៌មាន ៤ យ៉ាងគឺ:

**១— បញ្ញា** ដឹងយល់ស្គាល់របស់ដែលគួរដឹងយល់និងស្គាល់ ។

**២— សច្ចៈ** តាំងនឹងធ្វើអ្វីក៏ធ្វើពិត ។

**៣— ចាគៈ** លះបោលនូវអ្វីដែលជាសត្រូវនឹងសេចក្ដីពិតក្នុងចិត្ត ។

**៤— ឧបសមៈ** ស្ងប់ចិត្តចាកអ្វីៗ ដែលជាសត្រូវចំពោះចិត្ត ។

**ស** - ចូរពន្យល់នូវអត្ថនៃអធិដ្ឋានធម៌មួយ ៗ ឲ្យស្ដាប់បានមកមើល !

**ឆ** - បញ្ញាសំដៅយកគុណជាតិដែលមាននៅក្នុងចិត្ត របស់មនុស្សម្នាក់ ៗ អ្នកមានបញ្ញាដែលជាសម្មាទិដ្ឋិ តែងដឹងយល់និងស្គាល់នូវហេតុផលចំរើនវិនាសគ្រប់យ៉ាងទាំងអស់ ។ តាមផ្លូវធម៌បញ្ញានេះមាន ២ យ៉ាងទៅទៀតគឺ :

**ក — លោកិយបញ្ញា** ការដឹងយល់នឹងស្គាល់នូវរបស់ ឬ ហេតុផលអ្វីដែលជាលោកិយ ឬដែលជាវិស័យរបស់លោកិយ ជាបច្ចុប្បន្នហេតុ

ផលនេះឯង ។

**ខ – លោកុត្តរបញ្ញា** ការដឹងយល់ស្គាល់របស់ព្រះអរហន្ត ឬការដឹងយល់ស្គាល់ដែលស្ថិតនៅក្នុងវិស័យលោកុត្តរ ដែលជាវិស័យផុតលោកនេះឯង ។

**សច្ចៈ** សំដៅយកភាពពិតដែលខ្លួនបានយកប្រាជ្ញាទៅត្រិះរិះពិចារណា ដឹងស្គាល់ហើយក៏តាំងចិត្តថានឹងធ្វើនឹងប្រព្រឹត្តអនុវត្ត លុះត្រាតែបានសម្រេចផលប្រយោជន៍មិនលះបង់ចោល ឬមិនខ្វាចរអែងធុញទ្រាន់ក្នុងចិត្ត ។

**ចាគៈ** សំដៅយកការលះអកុសលធម៌ផ្សេង ៗ ដែលជាគ្រឿងកាំងចិត្ត ឬជាហេតុនាំឲ្យសៅហ្មងដល់ចិត្តនេះឯង ។ កាលបានលះបង់ភាពកាំងកសៅហ្មងចិត្តហើយ ចិត្តនឹងជ្រះស្រឡះហើយអាចធ្វើអ្វី ៗ ទៅទៀតកើត ។

**ឧបសម** សំដៅយកការស្ងប់ចិត្ត មិនខ្វល់ខ្វាយអំពល់តែនឹងគ្រឿងកាមកិលេស បេះធ្វើចិត្ត លើកចិត្តឲ្យផុតស្រឡះចាកកិលេស ។

## ឥទ្ធិបាទធម៌ ៤ យ៉ាង

**ស** – ឥទ្ធិបាទធម៌ ប្រែថាដូចម្តេច ? ចូរកប់និងពន្យល់ !

**ឆ** – ឥទ្ធិបាទធម៌ ប្រែថា ធម៌ជាជំហរដែលនាំឲ្យសម្រេចអំណាចជាផលប្រយោជន៍ដ៏សំខាន់សម្រាប់ខ្លួន ។ ឥទ្ធិបាទ ៤ យ៉ាងនោះគឺ:



១ – **ឆន្ទៈ** ចំណង់ចំណូលចិត្តក្នុងកិច្ចការណា ១ ។

២ – **វីរិយៈ** មានព្យាយាមធ្វើកិច្ចការនោះ ៗ ។

៣ – **ចិត្ត** មានចិត្តមាំក្នុងកិច្ចការនោះ ៗ លុះត្រាបានសម្រេច ។

៤ – **វីមំសា.** សាកល្បងពិសោធន៍នូវកិច្ចការដែលខ្លួនបានធ្វើរួចហើយនោះ ។

ធម៌ទាំង ៤ យ៉ាងនេះ មានទំនាក់ទាក់ទងគ្នាយ៉ាងល្អណាស់ ពោលគឺ

– អ្នកមានចំណង់ក្នុងកិច្ចការណា ១ ដែលខ្លួនពេញចិត្ត ដូចការធ្វើរថ ឬរកឃើញគ្រឿងម៉ាស៊ីនណា ១ ដោយខ្លួន ក៏មានចំណង់ចង់ធ្វើរថ ឬម៉ាស៊ីននោះឲ្យទាល់តែកើត ។

– កាលមានចិត្តចង់យ៉ាងនេះ ហើយមានព្យាយាមធ្វើ ឬប្រឹងធ្វើតាមមធ្យោបាយ និងតាមបច្ចេករបស់ខ្លួន មិនបោះបង់ការធ្វើរថ ឬ ម៉ាស៊ីនចោលដោយមិនទាន់បានសម្រេចនោះឡើយ គឺព្យាយាមធ្វើទៅតាមចំណង់នោះឯង ។

– កាលមានព្យាយាមធ្វើយ៉ាងនេះហើយ ក៏មានចិត្តមាំមួនក្នុងកិច្ចការនោះ ៗ ហើយប្រឹងត្រិះរិះពិចារណារកមធ្យោបាយគិតនឹកធ្វើតទៅទៀតលុះបានសម្រេច ។

– កាលបានសម្រេចហើយក៏ធ្វើការសាកល្បងនូវរថ ឬម៉ាស៊ីននោះឲ្យដើរវិលស្រួលបេ ។

កាលបើមិនទាន់បានជាទីពេញចិត្តទេ ត្រូវផ្លាស់ប្តូរថែមឬបន្ថយទៀត ដើម្បីឲ្យបានស្រួល ប្រើប្រាស់បាន ទើបឈប់ធ្វើ ។

**ស**— ឥទ្ធិបាទធម៌នេះ មានតែចំពោះកិច្ចការម្យ៉ាងទេ ឬមានទូទៅគ្រប់កិច្ចការទាំងអស់ ? ព្រោះអ្វី ?

**ឆ**— មានគ្រប់កិច្ចការទាំងអស់ ពោះការរៀនសូត្រ, ការសិក្សា,ការប្រព្រឹត្តធម៌, ការធ្វើហត្ថកម្ម, ឬការណាផ្សេងទៀត ដែលខ្លួនយល់ថាមានប្រយោជន៍ចំពោះខ្លួន ។ ត្រង់នេះហើយបានជាលោកកំណត់ឲ្យឈ្មោះថា ឥទ្ធិបាទធម៌ព្រោះជាធម៌នាំឲ្យបានសម្រេចផលប្រយោជន៍គ្រប់យ៉ាង ។

## ការធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ យ៉ាង

១– **កាយទុច្ចរិតប្បហាន** : ត្រូវលះបង់កាយទុច្ចរិត ។

២– **វចីទុច្ចរិតប្បហាន** : គួរលះបង់វចីទុច្ចរិត ។

៣– **មនោទុច្ចរិតប្បហាន** : គួរលះបង់មនោទុច្ចរិត ។

៤– **មិច្ឆាទិដ្ឋិប្បហាន** : គួរលះបង់យោបល់យល់ខុស ។

**ស**— ពាក្យ ទុច្ចរិត, អកុសល, បាបទាំង ៣ នេះ មានន័យដូចគ្នាឬផ្សេងគ្នា ? តើសំដៅលើអ្វីខ្លះ ?

**ឆ**— ពាក្យទាំង ៣ ម៉ាត់នេះមានន័យថា អាក្រក់ដូចគ្នា ប៉ុន្តែមានហេតុ និងឈ្មោះផ្សេងគ្នាបន្តិចគឺ :



— ទុច្ចរិត បានដល់ការប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ។

— អកុសល គឺជាឈ្មោះនៃអំពើអាក្រក់ ដែលបុគ្គលម្នាក់ ៗ បានប្រព្រឹត្តធ្វើនេះឯង ទោះធ្វើដោយកាយក្តី វាចាក្តី ចិត្តក្តី ។

— ឯបាប ជាផលនៃអំពើអាក្រក់ ដែលចេញជាផ្លែផ្កា រួចហើយនេះឯង ។

**ស**— បើបុគ្គល មិនប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តទេ តែជាអ្នកមានមិច្ឆាទិដ្ឋិទៅវិញ តើនាំឲ្យវង្វេង នាំឲ្យអាក្រក់បានទេ ? ព្រោះអ្វី ?

**ឆ**— នាំឲ្យអាក្រក់វង្វេងបានព្រោះមិច្ឆាទិដ្ឋិនេះ ជាតួអកុសលធំជាងគេបង្អស់, បុគ្គលណាមានការយល់ឃើញខុសហើយ ក៏បែរជានាំកាយវាចាចិត្តឲ្យប្រព្រឹត្តពានពារទៅលើអំពើអាក្រក់ ដោយការយល់ថាអាក្រក់ជាល្អ ល្អជាអាក្រក់ ។

**ស**— កាយ សំដី និងចិត្តទាំង ៣ នេះ តើណាមានកម្លាំងជាង ? ព្រោះអ្វី ?

**ឆ**— ចិត្តមានកម្លាំងជាង ព្រោះចិត្តទុកដូចអ្នកបើកបរឯកាយនិងសំដីទុកដូចជាតួរថបើអ្នកបររថ ពុំមានលក្ខណៈពេញលេញ, វិកលចរិតឬស្រវឹងស្រា វង្វេងស្មារតីហើយរថដែលអ្នកនោះបរ ពិតជាក្អូក, ឬរត់ទៅប៉ះទង្គិច បុកទីងអ្វីផ្សេង ៗ មិនខាន ។ ក្នុងធម្មបទដ្ឋកថាក៏មានសំដែងដែរថា :

**មនោបុព្វង្គមា ធម្មា មនោ មយា មនោ សេដ្ឋា** ដូច្នោះ ជាដើមដែលមានន័យថា ធម៌ទាំងឡាយមានចិត្តដល់មុន, សម្រេចពីចិត្ត មានចិត្តជាធាតុប្រសើរលើសអ្វីៗ ទាំងអស់ ។ ក្នុងពុទ្ធដីកានេះមានបញ្ជាក់ថា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា បើគេធ្វើការអ្វីៗ ( ដែលអាក្រក់ ) ក៏ដោយសារមានចិត្តប្រទូស្ត ។

ដូច្នេះ បានជាថា ចិត្តមានកម្លាំងខ្លាំងជាងអ្វីៗ ទាំងអស់ ។

## គួរប្រយ័ត្នចិត្តកុំឱ្យវង្វេងក្នុងហេតុ ៤ យ៉ាង

**១– រជនីយៈ** មិនគួរត្រេកត្រអាលក្នុងអារម្មណ៍ ដែលនាំឲ្យមានតម្រេក ។

**២– ទោសនីយៈ** មិនគួរខឹងក្នុងអារម្មណ៍ដែលនាំឲ្យខឹង ។

**៣– មោហនីយៈ** មិនគួរវង្វេងក្នុងអារម្មណ៍ដែលនាំឲ្យវង្វេង ។

**៤– មទនីយៈ** មិនគួរស្រវឹងក្នុងអារម្មណ៍ដែលនាំឲ្យស្រវឹង ។

**ស–** ពាក្យថាអារម្មណ៍ នេះតែងឮជាញឹកញាប់នៅក្នុងធម៌ អាថ៌ដែលទាក់ទងនឹងផ្លូវចិត្ត ។ តើអារម្មណ៍នេះគឺអ្វី ? នៅក្នុងចិត្តឬក្រៅចិត្ត ឬនៅឯណា ?

**ឆ–** ពាក្យថាអារម្មណ៍នេះមានន័យថា ទំនាក់ទំនាញចិត្ត, គ្រឿងដែលនាំចិត្តឲ្យកញ្ជ្រោលញាប់ញ័រ អារម្មណ៍ ស្ថិតនៅក្នុងចិត្តក៏បាន, ក្រៅចិត្តក៏បាន ។



ដែលថាស្ថិតក្នុងចិត្ត គឺអារម្មណ៍ជាតួចិត្ត ឬជាមែកធាងរបស់ចិត្តហ្នឹងឯង ។

ដែលថា ស្ថិតនៅក្រៅចិត្តបានដល់ គ្រឿងប្រដាប់ខាងក្រៅដែលសម្រាប់ប៉ះពាក់ទាញចិត្តឲ្យទៅជួបប្រទះ ទៅប៉ះទង្គិចគ្នាឡើងមានរូប, ក្លិន រស សម្លេងជាដើម ។ តួចិត្តដែលទៅប៉ះនឹងគ្រឿងប្រដាប់ចិត្តហើយក៏បង្កើតជាមែកធាងចិត្តនេះឡើងហៅថាអារម្មណ៍ ។

**ស–** ក្នុងធម៌ដែលជាអកុសលតែងមាន ទោសៈ និង មោហៈ នេះដោយច្រើន ។ បើដូច្នេះតើ ទោសៈ និង មោហៈ ជាតួបាបដែលមានគុណភាពយ៉ាងណា ?

**ឆ–** ច្រើនមែន ព្រោះទោសៈ និង មោហៈ ជាប្រភពដើម ជាកត្តា ឬជាមូលដ្ឋាននៃអកុសលធម៌, នៃអំពើបាប ។ កាលណាបុគ្គលមាន ទោសៈ មោហៈ នេះហើយ តែងតែប្រព្រឹត្តអំពើបាបផ្សេងៗជាដរាប ។ មិនតែប៉ុណ្ណោះ ទោសៈ តែកើតឡើងហើយតែងមានមោហៈ គឺការវង្វេងភ័ន្ត ហើយបើមានមោហៈ ក៏តែងមានទោសៈ ជាកំហឹងក្រេវក្រោធផ្សេងៗ ។ កត្តាទាំងពីរនេះអាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដូចបបូរមាត់លើក្រោមហើយនៅជិតស្និទ្ធគ្នាដូចធ្មេញនិងបបូរមាត់ ។

## បារិសុទ្ធិសីល ៤ យ៉ាង

**ស–** ពាក្យបារិសុទ្ធិសីលគឺអ្វី ? ចូរពប់នឹងពន្យល់ !

**ឆ**- បារិសុទ្ធិសីល គឺសណ្ដាប់ធ្នាប់ចរិយាដែលមានភាពបរិសុទ្ធស្អាត, មិនសៅហ្មង, មិនគ្រោតគ្រាត ។ បារិសុទ្ធិសីល ៤ គឺ:

**១- បាតិមោក្ខសំវរសីល**.- សណ្ដាប់ធ្នាប់ដែលជាការបង្រួមក្នុងបាតិមោក្ខ ។

**២- ឥន្ទ្រិយសំវរសីល**.- សណ្ដាប់ធ្នាប់ដែលជាការសង្រួមឥន្ទ្រិយទាំង ៦ ។

**៣- អាជីវបារិសុទ្ធសីល**.- សណ្ដាប់ធ្នាប់ដែលបរិសុទ្ធដោយការចិញ្ចឹមជីវិត ។

**៤- បច្ចយសន្និស្សិតសីល**.- សណ្ដាប់ធ្នាប់ដែលអាស្រ័យនឹងបច្ច័យ ។

**ស**- សីលទាំង ៤ នេះ មានសេចក្ដីពន្យល់យ៉ាងណា ? សីលនិមួយ ៗ បរិសុទ្ធ ដោយហេតុដូចគ្នា ឬ ផ្សេងគ្នា ?

**ឆ**- បាតិមោក្ខសំវរសីល បានដល់ការសង្រួមក្នុងបាតិមោក្ខ ជាសិក្ខាបទដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្ត និង អនុញ្ញាត ។ សីលនេះបរិសុទ្ធល្អស្អាត ដោយជំនឿដែលមានកំរិតបន្តិចម្ដង ៗ ជ្រៅឡើយ ហៅថា សទ្ធាចេតសិក ។

- ឥន្ទ្រិយសំវរសីល.- បានដល់ការសង្រួមឥន្ទ្រិយទាំង ៦ : ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត កាយ, ចិត្ត មិនឲ្យឃ្លេងឃ្លោងញាប់



ញ័រ កាលណាប៉ះនឹងអារម្មណ៍ដែលជាគ្រឿងទំនាញចិត្តខាងក្រៅ ។ សីលនេះបរិសុទ្ធស្អាតដោយសតិចេតសិក ។

- អាជីវបារិសុទ្ធិសីល.- បានដល់ភាពបរិសុទ្ធដោយការចិញ្ចឹមជីវិតត្រូវ វៀរចាកបាបធម៌ ៥ និង អនេសនៈ គឺការស្វែងរកខុស ២១ ជាដើម ។ សីលនេះ បរិសុទ្ធស្អាតដោយព្យាយាមរកតាមមាន តាមបាន ដែលហៅថា វីរិយចេតសិក ។

- បច្ចយសន្និស្សិតសីល.- បានដល់សណ្ដាប់ធ្នាប់ដ៏ល្អ ដោយអាស្រ័យនឹងបច្ច័យ ៤ គឺ ចីវរ, បិណ្ឌបាត, សេនាសនៈ និង គិលានភេសជ្ជៈ វៀរចាកការបរិភោគខុស មានថេយ្យបរិភោគជាដើម ។ សីលនេះ បរិសុទ្ធស្អាតដោយការពិចារណា ហៅថា បញ្ញាចេតសិក ។

**ស**- សីលទាំង ៤ នេះ សម្រាប់អនុវត្តចំពោះជនទូទៅ ឬចំពោះជនណាទៅវិញ ?

**ឆ**- សម្រាប់តែពួកភិក្ខុក្នុងព្រះពុទ្ធសាសនាតែម្យ៉ាងប៉ុណ្ណោះ ។

## អារក្ខកម្មដ្ឋាន ៤ យ៉ាង

**១- ពុទ្ធានុស្សតិ** រលឹកដល់គុណព្រះពុទ្ធ ។

**២- មេត្តា** ផ្សាយមេត្តាចិត្ត ។

**៣- អសុភៈ** ពិចារណាកាយថាជារបស់មិនល្អ ។

**៤- មរណស្សតិ** រលឹកដល់ក្ដីស្លាប់ ។

**ស** – ព្រះពុទ្ធមានគុណដូចម្ដេច បានជាយើងត្រូវរំលឹក ?

**ឆ** – ព្រះពុទ្ធមានគុណច្រើនប្រការណាស់ តែបើនិយាយដោយខ្លី មានតែ ៣ យ៉ាងប៉ុណ្ណោះគឺ :

**ក – បញ្ញាគុណ** ព្រះអង្គជាមនុស្សដែលមានបញ្ញាលើសលុប ហើយទ្រង់ពន្យល់បង្ហាញ និងណែនាំមនុស្សសត្វទេវតា ឲ្យយល់ស្គាល់ និងចេះរកមធ្យោបាយដើម្បីបានប្រាជ្ញានេះថែមទៀត ។

**ខ – ករុណាគុណ** ព្រះអង្គមានព្រះទ័យករុណា ដែលហៅថាសហម្បតីព្រហ្ម ដែលទ្រង់តែងផ្សាយចំពោះសព្វសត្វ ហើយព្រះអង្គពន្យល់ដឹកនាំមនុស្សសត្វ ឲ្យផ្សាយករុណានេះចំពោះគ្នានិងគ្នាថែមទៀត ។

**គ – វិសុទ្ធិគុណ** ព្រះអង្គជាអ្នកប្រាជ្ញដែលពោរពេញទៅដោយសេចក្ដីស្អាតស្អំ ហើយព្រះអង្គពន្យល់ណែនាំមនុស្សសត្វឲ្យបំពេញសេចក្ដីស្អាតនេះថែមទៀត ។

ប៉ុណ្ណោះហើយ ដែលជាហេតុនាំឲ្យយើងយល់ថាព្រះពុទ្ធជាបុគ្គល ដែលមានគុណច្រើនណាស់លើពុទ្ធបរិស័ទទូទៅ ។

**ស** – ចុះចំពោះសេចក្ដីស្លាប់វិញជាភ័យ ១ ដែលនាំឲ្យមនុស្សសត្វតក់ស្លុតណាស់ តែហេតុម្ដេចបានជាក៏ត្រូវឲ្យនឹកដែរ ?

**ឆ** បានជាត្រូវឲ្យនឹក ព្រោះក្ដីស្លាប់ជាភ័យមែន កាលណាយើងមិនដែលនឹកសោះ ឈ្មោះថាយើងមានចិត្តប្រមាទ ហើយកាលណា



យើងមិនដែលនឹកសោះ ដល់ស្លាប់មកលុកលុយរុករានបៀតបៀនជីវិតយើងរឹតតែភ័យណាស់ទៅទៀត ។ កាលណាយើងនឹកញឹកញាប់ លុះស្លាប់ធ្លាក់មកដល់ យើងមិនភ័យពេកទេ ដូចយើងបានចាក់ថ្នាំការពារជម្ងឺអាសន្នហើយជាស្រេច កាលណាមានជម្ងឺនេះចូលមកដល់ យើងមានថ្នាំអាសន្នកើតស្រេចក្នុងខ្លួនស្រេចទៅហើយ ទោះជម្ងឺថ្មីចូលមកយាយី ក៏មិនសូវជាខ្លាំងប៉ុន្មានដែរ ។

ការនឹកដល់កម្មដ្ឋានទាំង ៤ ឲ្យបានរឿយៗ ឈ្មោះថាយើងបានដប់លៀងនាវាជីវិតរបស់យើងឲ្យស្រេចតាមវ័យ និងតាមពេលវេលានេះឯង ព្រោះជីវិតគ្រាន់ជាទីស្នាក់អាស្រ័យនៃមនុស្សសត្វ មួយគ្រា ៗ ប៉ុណ្ណោះ មិនស្ថិតស្ថេរចីរកាលឡើយ ។

## ព្រហ្មវិហារ ៤ យ៉ាង

**១ – មេត្តា.** សេចក្ដីប្រាថ្នាចង់ឲ្យគេបានសុខចំរើន ។

**២ – ករុណា.** មានចិត្តអាណិតចង់ឲ្យគេរួចចាកទុក្ខទោស ។

**៣ – មុទិតា.** មានចិត្តទន់ភ្លន់ត្រេកអរតាមក្នុងពេលដែលគេបានល្អចំរើន ។

**៤ – ឧបេក្ខា.** មានចិត្តជាកណ្ដាលមិនទោមនស្ស ឬសោមនស្សក្នុងវេលាដែលគេមានគ្រោះថ្នាក់បែបណាមួយ ។

**ស** – ពាក្យថា ព្រហ្មវិហារធម៌នេះមានសេចក្ដីពន្យល់យ៉ាងណា ?

ឆ– ពាក្យព្រហ្មវិហារធម៌ មានន័យថា ធម៌របស់ព្រហ្ម ។ ពាក្យថាព្រហ្មនេះ មិនចំពោះតែព្រហ្មនៅព្រហ្មលោកនោះឡើយ មាតាបិតា គ្រូបាអាចារ្យ, ព្រះសម្មាសម្ពុទ្ធ ឬ ជនណាម្នាក់ដែលមានធម៌ទាំង ៤ នេះកាន់ខ្ជាប់ ក៏ហៅថាព្រហ្មបានដែរ ។

– **មេត្តា**.– បានដល់ចិត្តប្រាថ្នាចង់ឲ្យគេបានសុខចំរើន កុំឲ្យជួបនឹងក្តីវិនាសអន្តរាយណា ។ មេត្តាគឺចិត្តប្រាសចាកការប្រណែនឈ្នានីស ដែលជាព្យាបាទ, ជាអាឃាត បង់គំនុំគុំគួននេះឯង ។

– **ករុណា**.– បានដល់ចិត្តដែលអាណិត មិនចង់ឲ្យគេមានទុក្ខទោសកាលបើគេមានទុក្ខទោសក៏ចង់ឲ្យគេរួចពីទុក្ខទោសនោះវិញ ។

– **មុទិតា**.– បានដល់ចិត្តដែលត្រេកអររីករាយតាមនៅពេលដែលគេមានសុខចំរើនហើយ គឺជាចិត្តទន់ភ្លន់ចំពោះអំពើ និង ផលនៃអំពើល្អរបស់ជនដទៃ ហើយកាលណាគេបានទទួលក៏ត្រេកអររីករាយ មិនប្រណែន ឬ ចង់ឲ្យគេទទួលផលអាក្រក់វិញ ។

– **ឧបេក្ខា**.– បានដល់ចិត្តព្រងើយកន្តើយ ឬ ចិត្តជាកណ្តាលបើគេមានទុក្ខ ឬ សុខក៏មិនកើតទោមនស្ស សោមនស្សឡើយ ។

ស– ពាក្យ ឧបេក្ខា និង អព្យាក្រឹត តើដូចគ្នា ឬ ផ្សេងគ្នា ? ចូរបង្ហាញ ?

ឆ– ពាក្យឧបេក្ខា និង អព្យាក្រឹត មានន័យថា នៅជាកណ្តាដូច



គ្នា ប៉ុន្តែអព្យាក្រឹត បានដល់កាយ និង វាចា ឬ ចិត្តដែលនៅជាកណ្តាល ឯពាក្យ ឧបេក្ខា សំដៅយកតែទឹកចិត្តដែលនៅជាកណ្តាល មិនផ្អៀងឃ្វេងឃ្វាងទៅតាមលោកធម៌ ឬ តាមសន្ទុះនៃសុខទុក្ខ ចំរើនវិនាសដែលកើតឡើងចំពោះក្រុមគ្រួសារបក្សពួកខ្លួន ឬចំពោះមនុស្សទូទៅដោយមិនរើសមុខ ។

## សតិប្បដ្ឋាន ៤ យ៉ាង

ស– សតិបដ្ឋាន មានន័យសំគាល់យ៉ាងណាក្នុងភាសាខ្មែរ ? ចូរពន្យល់ និង បង្ហាញពីសតិប្បដ្ឋានទាំង ៤ នោះផង ។

ឆ– ពាក្យសតិប្បដ្ឋាន ក្នុងភាសាខ្មែរសំគាល់ន័យថា ការតាំងស្មារតីមានបួន, ការចងចាំនូវធម៌ទុកក្នុងស្មារតី ។ សតិបដ្ឋាន ៤ នោះគឺ:

១– **កាយានុបស្សនា** ត្រិះរិះពិចារណា ដោយយកកាយជាអារម្មណ៍ថា កាយនេះ មិនមែនរបស់ស្ថិតស្ថេរ ជានិច្ច: ជាបរមសុខ, ជាមនុស្ស, សត្វ បុគ្គល ដែលទៀងទាត់ ឬ ជាយើងជាគេឡើយ ឬ មានន័យម៉្យាងទៀតថា កាយនេះគ្រាន់តែជាកត្តាមួយ ដែលធម្មជាតិ ឬ សង្ខារតាក់តែងឡើងដោយប្រមូលផ្តុំធាតុ ៤ ឲ្យមូលចូលគ្នាមានការពាក់ទងគ្នា តែមួយរយៈពេល សំរាប់ផ្ទុកផ្តាក់វត្ថុផ្សេង ៗ មានចិត្តជាដើមប៉ុណ្ណោះ ។

២– **វេទនានុបស្សនា** ត្រិះរិះពិចារណា ដោយយកវេទនា

ជាអារម្មណ៍ ពោលគឺត្រូវពិចារណារំពឹងគិតថា វេទនានេះគ្រាន់តែជាគ្រឿងទទួលនូវអារម្មណ៍ និងប្រសស្រូបចូមយកអារម្មណ៍ផ្សេង ៗ តែប៉ុណ្ណោះ មិនស្ថិតស្ថេរទៀងទាត់ ក៏មិនមែន, មិនជាជាមនុស្សសត្វ, បុគ្គល ឬ យើងគេក៏មិនមែនដែរ ។

**៣– ចិត្តានុបស្សនា** ត្រិះរិះពិចារណាដោយយកចិត្តជាអារម្មណ៍ គឺត្រូវពិចារណាថាចិត្តគ្រាន់តែជាគ្រឿងត្រិះរិះពិចារណា, ជាការសន្សំអារម្មណ៍ល្អអាក្រក់តែប៉ុណ្ណោះ មិនជារបស់យើងគេ ឬ ជាមនុស្សសត្វបុគ្គលឡើយ ។

**៤– ធម្មានុបស្សនា** ត្រិះរិះពិចារណាយកធម៌ដែលប្រព្រឹត្តទៅជាមួយចិត្ត ជាកុសលទុកជាអារម្មណ៍ថា ធម៌នេះគ្រាន់ជាគ្រឿងទ្រទ្រង់សត្វលោក, ជាគុណជាតល្អបរិសុទ្ធ, ជាច្បាប់ក្បួន ជាគ្រឿងនាំសត្វឲ្យបានល្អធ្វើដំណើរទៅកាន់សុគតិភពតែប៉ុណ្ណោះ មិនជាមនុស្សសត្វបុគ្គល ឬ ជាយើងគេឡើយ ។

**ស** – សតិបដ្ឋាន ៣ ខាងដើមជាធម្មជាតិជាធាតុដែលកើតឡើងប្រកបដោយលក្ខណៈល្អអាក្រក់ទៅហើយ ៗ ដែលយើងត្រូវពិចារណាចុះចំណែកព្រះធម៌ដែលជាកុសលជាគុណជាតល្អ ជាទុកទទៅហើយ ម្ដេចក៏យើងត្រូវពិចារណាដែរ ?

**ឆ** – បានជាត្រូវយកធម៌ជាទីតាំង ឬ ជាគ្រឿងពិចារណាដែរ ព្រោះ



ធម៌ទាក់ទងទៅនឹងចិត្ត ហើយគុណជាតដែលល្អបែបនេះ ត្រូវទុកជាគោលជាទីតាំង ទើបមានគោលគំនិតនឹងស្វែងរកសេចក្ដីល្អបាន ។

**ស** – ចុះអ្នកពិចារណាត្រិះរិះសតិប្បដ្ឋានត្រូវប្រកបអង្គ ប៉ុន្មានយ៉ាងដែរអ្វីខ្លះ ?

**ឆ** – ត្រូវប្រកបដោយអង្គ ៣ គឺ :

**ក– សតិ** មានស្មារតីចងចាំជានិច្ច ។

**ខ – សម្បជញ្ញៈ** មានការដឹងខ្លួនជានិច្ច ។

**គ – វីរិយៈ** មានព្យាយាមគិតគូរពិចារណាជានិច្ច ។

**ស** – ចុះបើគេចំរើនពិចារណាតែមួយ ៗ បានដែរឬទេ ?

**ឆ** – បើពិចារណាតែមួយ ៗ ក៏បាន ពិចារណាគ្រប់ទាំង ៤ ក៏បាន គឺសុទ្ធតែបានផលប្រយោជន៍ដូចគ្នា ។

## ធាតុកម្មដ្ឋាន ៤ យ៉ាង

**១– បឋវីធាតុ** ធាតុដី

**២– អាបោធាតុ** ធាតុទឹក

**៣ តេជោធាតុ** ធាតុភ្លើង

**៤– វាយោធាតុ** ធាតុខ្យល់

**ស** – ធាតុទាំង ៤ នេះកាលផ្សំគ្នាទៅ នឹងកើតជាអ្វី ?

**ឆ** – ធាតុទាំង ៤ នេះ កាលផ្សំគ្នាទៅ នឹងកើតជារូបឡើង ។

ច – ចុះធាតុមួយ ៗ បានដល់អ្វីខ្លះ? ដូចគ្នា ឬផ្សេងគ្នា ចូររាប់ឲ្យអស់ ។

ឆ – ធាតុមួយ ៗ មានចែកផ្សេង ៗ ទៅទៀត មិនដូចគ្នាឡើយ ពោលគឺធាតុ ១ មានមុខធាតុច្រើនយ៉ាង :

– បឋវីធាតុ ដែលជាធាតុដីនោះមានចែកដល់ទៅ ១៩ មុខគឺ :

១ – កេសា សក់

២ – លោមា រោម

៣ – នខា ក្រចក

៤ – ទន្តា ធ្មេញ

៥ – តចោ ស្បែក

៦ – មំសំ សាច់

៧ – នហារូ សរសៃ

៨ – អដ្ឋិ ឆ្អឹង

៩ – អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង

១០ – វក្កំ ពប

១១ – ហទយំ បេះដូង

១២ – យកនំ ថ្លើម

១៣ – កិលោមកំ ភរ



១៤ – បិហកំ ក្រពះ

១៥ – បប្ផាសំ សួត

១៦ – អន្តំ ពោះវៀនធំ

១៧ – អន្តគុណំ ពោះវៀនតូច

១៨ – ឧទរិយំ អាហារថ្មី

១៩ – ករីសំ អាហារចាស់

– អាបោធាតុ មាន ១២ យ៉ាងគឺ

១ – បិត្តំ ប្រមាត់

២ – សេម្ហំ ស្លេស្ម

៣ – បុព្វោ ខ្ទុះ

៤ – លោហិតំ ឈាម

៥ – សេទោ ញើស

៦ – មេទោ ខ្លាញ់ខាប់

៧ – អស្សុ ទឹកភ្នែក

៨ – វសា ខ្លាញ់រាវ

៩ – ខេឡោ ទឹកមាត់

១០ – សិង្ឃាណិកា : ទឹកសំបោរ

១១ – លសិកា រំអិល

១២– មុត្តំ ទឹកមូត្រ ។

### – តេជោធាតុមាន ៤ យ៉ាង

១– សន្តប្បគ្គិ ភ្លើងដែលធ្វើកាយឲ្យក្តៅសព្វ ។

២– ជីរណគ្គិ ភ្លើងដែលធ្វើកាយឲ្យទ្រុឌទ្រោម ។

៣– បរិណាមគិ ភ្លើងដែលធ្វើកាយឲ្យក្តៅក្រហាយ ។

៤– បរិទយ្ហគ្គិ ភ្លើងរំលាយអាហារ ។

### – វាយោធាតុមាន ៦ យ៉ាងគឺ

១– ឧទ្ធង្គមវាត ខ្យល់បក់ឡើងលើ ។

២– អធោគមវាត ខ្យល់បក់ចុះក្រោម ។

៣– កុច្ឆិសយវាត ខ្យល់បក់ក្នុងពោះវៀន ។

៤– កោដ្ឋាសយវាត ខ្យល់បក់ក្នុងពោះវៀន ។

៥– អង្គអង្គានុសារិតវាត ខ្យល់ក្នុងពង់កាយ ។

៦– អស្សាសបស្សាសវាតៈ ខ្យល់សំរាប់ដកដង្ហើមចេញចូល។

ស– ហេតុដូចម្តេច. បានជាលោកឲ្យទុកធាតុទាំង ៤ ជាកម្មដ្ឋាន ?

ឆ– បានជាលោកឲ្យ ទុកធាតុទាំង ៤ ជាកម្មដ្ឋាន ព្រោះធាតុទាំង ៤ ក៏គ្រាន់តែជាធាតុប៉ុណ្ណោះ តែមិនមែនជាសត្វ, មនុស្ស ខ្លួនប្រាណយើងគេឡើយ ។



## អរិយសច្ច ៤ យ៉ាង

១– ទុក្ខសច្ចៈ សភាពពិតក្នុងកងទុក្ខ ។

២– សមុទសច្ចៈ សភាពពិតក្នុងហេតុដែលនាំឲ្យកើតទុក្ខ ។

៣– និរោធសច្ចៈ សភាពពិតក្នុងហេតុរលត់ទុក្ខ

៤– មគ្គសច្ចៈ សភាពពិតក្នុងឧបាយជាគ្រឿងរំលត់ទុក្ខ ។

ស– ពាក្យអរិយសច្ច ប្រែថា ដូចម្តេច ? ចូរពន្យល់អំពីសច្ចនីមួយៗទៅមើល !

ឆ– ពាក្យអរិយសច្ច ប្រែថា សភាពពិតដ៏ប្រសើរដែលព្រះសម្មាសម្ពុទ្ធទ្រង់បានគិតពិចារណារិះរកឃើញ ។ សច្ចធម៌នីមួយៗ មានចែកទៅទៀតតាមពួកក្រុមគឺ:

– ទុក្ខសច្ច សភាពក្នុងកងទុក្ខទាំង ១២ កង:

១– ជាតិទុក្ខ ទុក្ខកើតមកពីការកើតជាកំណើតមនុស្ស សត្វ

២ ជរាទុក្ខ ទុក្ខកើតមកពីការចាស់ទ្រុឌទ្រោមពងកាយ

៣– ព្យាធិទុក្ខ ទុក្ខព្រោះជម្ងឺ

៤– មរណទុក្ខ ទុក្ខព្រោះសេចក្តីស្លាប់ ។

៥– សោកទុក្ខ ទុក្ខព្រោះសោកស្តាយ

៦– បរិទេវទុក្ខ ទុក្ខព្រោះការខ្សឹកខ្សួល

៧– ទុក្ខទុក្ខ ទុក្ខព្រោះកើតទុក្ខ

៨– ទោមនស្សទុក្ខ ទុក្ខព្រោះតូចចិត្ត ។

៩– ឧបាយាសទុក្ខ ទុក្ខព្រោះខ្សឹកខ្សួល

១០– យម្បិច្ឆំ នលភតិ តម្បិទុក្ខ ចំណង់ចង់បានរបស់តែមិនបាន ក៏មានទុក្ខ ។

១១– បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះបានរបស់ជាទីស្រឡាញ់ ។

១២– បិយេហិ វិប្បយោគទុក្ខ ព្រោះព្រាត់ប្រាស់របស់ជាទីស្រឡាញ់ ។

ហមុទយសច្ច សភាពពិតក្នុងហេតុដែលនាំឱ្យកើតទុក្ខ ដោយតណ្ហា ៣ គឺៈ

១– កាមតណ្ហា ចំណង់ក្នុងកាម

២– ភវតណ្ហា ចំណង់ក្នុងភព

៣– វិភវតណ្ហា ចំណង់ក្នុងការចេញចាកភព

– និរោធសច្ចៈ សភាពពិតក្នុងហេតុរលត់ទុក្ខ គឺព្រះនិព្វាន ។

– មគ្គសច្ចៈ សភាពពិតក្នុងឧបាយដែលនាំឲ្យរលត់ទុក្ខទាំង ១២ កង ដោយមគ្គមានអង្គ ៨ គឺៈ

១– សម្មាទិដ្ឋិ មានសេចក្ដីយល់ឃើញត្រូវ

២– សម្មាសង្កប្បៈ មានការត្រិះរិះត្រូវ



៣– សម្មាវាចា មានសំដីពោលត្រូវ

៤– សម្មាកម្មន្តៈ ការងារត្រូវ

៥– សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ

៦– សម្មាវាយាម ព្យាយាមត្រូវ

៧– សម្មាសតិ តាំងស្មារតីត្រូវ

៨– សម្មាសមាធិ តំកល់ចិត្តត្រូវ

ស– អរិយសច្ចទាំង ៤ នេះ ព្រះពុទ្ធទ្រង់សំដែងប្រោសអ្នកណាមុនគេ ? នៅទីណា ?

ឆ– ព្រះអង្គទ្រង់សំដែងជាបឋមទេសនា ដើម្បីប្រោសបញ្ចវគ្គិយភិក្ខុទាំង ៥ អង្គនៅព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ក្នុងដែនកាសី ។

# បញ្ចកៈ ពួកធម៌ ៥

## អនន្តរិយកម្ម ៥ យ៉ាង

**ស** – អនន្តរិយកម្ម ប្រែដូចម្តេច ? មានប៉ុន្មាន ? អ្វីខ្លះ ?

**ឆ** – អនន្តរិយកម្ម ប្រែថា អំពើមានទម្ងន់ប្រមាណមិនបាន ឬថា អំពើដែលឲ្យផលតាមលំដាប់គ្មានទីបំផុត បន្ទាប់ពីជាតិនេះទៅ ។ មាន ៥ យ៉ាងគឺ :

**១– មាតុឃាត** ការសម្លាប់មាតា

**២– បិតុឃាត** ការសម្លាប់បិតា

**៣– អរហន្តឃាត** ការសម្លាប់ព្រះអរហន្ត

**៤– លោហិតុប្បាទ** ប្រទូសរ៉ាយចំពោះព្រះពុទ្ធរហូតដល់ញុំាងព្រះលោហិតឲ្យហូរចេញ ។

**៥ សង្ឃភេទ** ការបំបែកបំបាក់សង្ឃ

**ស** – តើអនន្តរិយកម្មទាំង ៥ នេះមានន័យយ៉ាងណាខ្លះ ? ចូរពន្យល់

**ឆ** – អនន្តរិយកម្មទាំង ៥ នេះមានន័យដូច្នេះ :

ការសម្លាប់មាតាបិតាជាអ្នកឧបការគុណចំពោះខ្លួនជាអំពើមួយអាក្រក់បំផុត, មនុស្សណាដែលហ៊ានសម្លាប់មាតាបិតា មនុស្សនោះគង់ហ៊ានប្រហារជីវិតអ្នកដទៃ ដែលខ្លួនទាស់ចិត្តដោយចេញ មិនខ្លាច ឬមិនកោតញញើតអ្វីឡើយ, ការធ្វើដូច្នេះឈ្មោះ ថាអ្នកបំផ្លាញរំលាយនូវវង្សត្រកូល



សាច់សាលោហិតរបស់ខ្លួនឲ្យវិនាសសាបសូន្យ ។

ព្រះអរហន្តជាអ្នកមានអាសវកិលេសបន្សាត់ចោលអស់ហើយ មានកគ ឆ្អាក់ចោលហើយ, មានចិត្តបរិសុទ្ធ មិនបានគិត ប្រទូសរ៉ាយចំពោះអ្នកណាមួយឡើយ , លោកជាទីគោរពកោតក្រែងរបស់មហាជនពុទ្ធសាសនិក , កាលបើមនុស្សណាមកសម្លាប់អរហន្តទីណាស្របែបនេះ មនុស្សនោះឈ្មោះថាជាអ្នកបំផ្លាញទីគោរពកោតក្រែងរបស់មហាជន ។

ព្រះសាស្តាជាកំពូលបុគ្គល ជាទីធ្វើសក្ការបូជារបស់មហាជន, ជាអ្នកប្រដៅមនុស្ស សត្វឲ្យកែខ្លួនត្រូវ ផ្លូវល្អ ឲ្យបានសុខក្នុងការចិញ្ចឹមជីវិតបច្ចុប្បន្នក៏ដូចបរលោក, ជាគ្រូបាអាចារ្យគិតតែពីសេចក្តីសុខជាប្រ-យោជន៍នៃសត្វលោក ។ បើបុគ្គលសម្លាប់មនុស្សបែបនេះ ឈ្មោះថាជាអ្នកបំផ្លាញសេចក្តីសុខរបស់ខ្លួនឲ្យវិនាស ។

ការសាមគ្គីរួមរស់ព្រមព្រៀងគ្នា មូលមតិគ្នា ដោយកាយវាចាចិត្ត ឈ្មោះថាសង្ឃឬ ពួក , ការបំបែកសង្ឃឲ្យឃ្លាតឆ្ងាយបែកបាក់ឬឈ្មោះទាស់ទែងគ្នាក្នុងសង្គមមួយ ។ ឈ្មោះថាបំបែកសេចក្តីសុខនៃសង្ឃនោះ ឬសង្គមនោះ , ការធ្វើដូចនេះលោកចាត់ថាជាអ្នកបំបែកឬបំផ្លាញសាមគ្គីធម៌ · សេចក្តីសុខរបស់ខ្លួនឯង ។

អនន្តរិយកម្មទាំង ៥ នេះ ជាបាបធ្ងន់ ឃាត់សួគ៌ ឃាត់ព្រះនិព្វានតាំងនៅក្នុងស្ថានបាដិករបស់ព្រះពុទ្ធសាសនា ដែលព្រះពុទ្ធអង្គទ្រង់ពោល

ហាមឃាត់មិនឲ្យប្រព្រឹត្តជាដាច់ខាត ។

## អភិណ្ហប្បច្ចវេក្ខណៈ ៥ យ៉ាង

**ស** – អភិណ្ហប្បច្ចវេក្ខណៈប្រែដូចម្ដេច ?

**ឆ** – អភិណ្ហប្បច្ចវេក្ខណៈ ប្រែថាធម៌ដែលបព្វជិតឬគ្រហស្ថគួរពិចារណារឿយៗ ។

**ស** – អភិណ្ហប្បច្ចវេក្ខណៈនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ** – អភិណ្ហប្បច្ចវេក្ខណៈ មាន ៥ យ៉ាងគឺ :

**១ – ជរាធម្មោម្ហិ** អាត្មាអញមានការចាស់ជរាជាធម្មតា មិនកន្លងការចាស់ជរាបានឡើយ ;

**២ – ព្យាធិធម្មោម្ហិ** អាត្មាអញមានសេចក្ដីឈឺចាប់ជាធម្មតា មិនកន្លងការឈឺចាប់បានឡើយ ;

**៣ – មរណធម្មោម្ហិ** អាត្មាអញមានសេចក្ដីស្លាប់ជាធម្មតាមិនកន្លងសេចក្ដីស្លាប់បានឡើយ ;

**៤ – សព្វេហិ មេ បិយេហិ** អាត្មាអញមានសេចក្ដីព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងអស់ ;

**៥ – កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួន គឺ ធ្វើល្អនឹងបានល្អ ធ្វើអាក្រក់នឹងបានអាក្រក់ជាប្រាកដ ;

**ស** – តើអភិណ្ហប្បច្ចវេក្ខណៈ ទាំង ៥ នោះមានន័យយ៉ាងណាខ្លះ ?



ចូរពន្យល់ ?

**ឆ** – អភិណ្ហប្បច្ចវេក្ខណៈ ទាំង ៥ នោះមានន័យយ៉ាងនេះ :

ការពិចារណាដល់ការចាស់ជរា គឺពិចារណាថាអញមានខ្លួនចាស់ទ្រុឌទ្រោម ស្បែកជ្រីវជ្រួញ សក់ស្កូវហើយមិនមែនកម្លោះឬក្រមុំ ដែលពោរពេញដោយកម្លាំងពលំឡើយ, ដូចនេះមិនត្រូវប្រព្រឹត្តអំពើបាបផ្សេងៗ មានបាណាតិបាតជាដើមទៀតទេ ត្រូវស្វះស្វែងរកកុសលធម៌ផ្សេងៗ ដើម្បីជាផ្លូវសុខសួគ៌និព្វាន ។ ការពិចារណានេះសំខាន់គឺការលះបង់សេចក្ដីស្រវឹងក្នុងវ័យ ។

ការពិចារណាដល់ការឈឺចាប់ គឺត្រូវដឹងថា រូបកាយត្រូវកើតរោគបៀតបៀនរៀងរាល់ថ្ងៃ, ត្រូវប្រយ័ត្ន, បរិភោគចំណីឲ្យប្រកបដោយអនាម័យ, កាលបើមានរោគាពាធត្រូវសំគាល់ថាមានរោគ មិនត្រូវព្រងើយកន្តើយ ឬ សំគាល់ថាមិនមានរោគឡើយ ។

ការពិចារណាដល់សេចក្ដីស្លាប់ គឺពិចារណាថាអញនឹងមានទីបំផុតគឺការស្លាប់, ដូចនេះត្រូវប្រព្រឹត្តកុសលធម៌ដើម្បីបរលោក ។ ការពិចារណានេះជាហេតុឲ្យលះបង់សេចក្ដីស្រវឹងក្នុងជីវិត ។

សរុបសេចក្ដីទៅការពិចារណាក្នុងធម៌ទាំង ៥ មានប្រយោជន៍មិនឲ្យវង្វេងភ្លេចស្មារតីក្នុងការលះបង់សេចក្ដីអាក្រក់, អកុសលធម៌ទៅស្វះស្វែងប្រព្រឹត្តអំពើល្អ, កុសលធម៌គ្រប់យ៉ាង ។

## ធម៌ជាកម្លាំង ៥ យ៉ាង

ស — ពលធម៌ ប្រែដូចម្ដេច ?

ឆ — ពលធម៌ ប្រែថាធម៌ជាកម្លាំង គឺកម្លាំងក្នុងកិច្ចការរបស់ខ្លួន ។

ស — ពលធម៌នេះ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ — ពលធម៌នេះ មាន ៥ យ៉ាងគឺ :

១ — **សទ្ធា** ជំនឿ

២ — **វីរិយ** សេចក្ដីព្យាយាម

៣ — **សតិ** ការភ្ញាក់រលឹក

៤ — **សមាធិ** តំកល់ចិត្តឲ្យមាំមួន

៥ — **បញ្ញា** ដំណឹងការខុសត្រូវ

ស — តើពលធម៌ទាំង ៥ នេះមានន័យដូចម្ដេចខ្លះ ? ចូរពន្យល់ !

ឆ — ពលធម៌ទាំង៥ នេះមានន័យដូចតទៅនេះ :

ជំនឿជាកម្លាំង ព្រោះកិច្ចការណាមួយដែលខ្លួនបានប្រកបហើយត្រូវមានជំនឿក្នុងចិត្តថាមានប្រយោជន៍ ឬ បានផលផ្ដល់សេចក្ដីសុខដល់ខ្លួន ។

ប៉ុន្តែការធ្វើឲ្យសម្រេចទៅបានតាមជំនឿដែលខ្លួនចុះស៊ប់ហើយនោះ លុះត្រាតែមានព្យាយាម ទើបបានដូចប្រាថ្នា ។

រីឯការព្យាយាមនេះយូរទៅអាចឃ្លាតចាកបានដែរ ពោលគឺឃ្លាត



ចាកជំនឿរបស់ខ្លួនពីមុនមក ដើម្បីឲ្យតាំងនៅបានដូចបំណងត្រូវមានការភ្ញាក់រឭក គឺរឭកឃើញគោលបំណងរបស់ខ្លួនដែលបានប៉ងពីមុន ។

បញ្ញា ការស្គាល់ខុសត្រូវ កម្លាំងទាំង ៤ ខាងលើបើបេះតែធ្វើទៅមិនពិចារណាក៏មិនកើតដែរ , ត្រូវយកបញ្ញាមកប្រើដើម្បីឲ្យដឹងថាល្អឬអាក្រក់ ខ្ពស់ឬទាបសមឬមិនសម ។

សរុបមកធម៌ទាំង៥នេះ ត្រូវមានការប្រាស្រ័យទាក់ទងគ្នា ទៅវិញទៅមក ទើបជាកម្លាំងក្នុងកិច្ចការផ្សេង ៗ ។

ម្យ៉ាងទៀតធម៌នេះមានជាប់ទាក់ទងទៅនឹងពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលជាកម្លាំងជំរុញអ្នកបំពេញកុសលបានសំរេចសម្បត្តិជាន់ខ្ពស់គឺលោកុត្តរធម៌តាមបំណង ។

## នីវរណធម៌ ៥ យ៉ាង

ស — នីវរណធម៌ ប្រែដូចម្ដេច ។

ឆ — នីវរណធម៌ ប្រែថាធម៌ជាគ្រឿងរាំងរា, ឃាំងចិត្តមិនឲ្យបានកុសលផ្សេង ៗ ។

ស — នីវរណធម៌ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ — នីវរណធម៌នេះ មាន ៥ យ៉ាងគឺ :

១ — **កាមច្ឆន្ទៈ** : ការស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍មានរូបជាដើម

២ — **ព្យាបាទ** : ចងចិត្តគំនុំគុំគួន

**៣ – ថីនមិទ្ធៈ** ការងោកងុយក្នុងអារម្មណ៍

**៤ – ឧទ្ធច្ចកុក្កុច្ចៈ** ការរាយមាយចិត្ត . សោចសេរស្តាយ

**៥ – វិចិកិច្ឆា** ការសង្ស័យមិនដាច់ស្រេច

**ស** – តើនីវរណធម៌ទាំងអស់នេះមានន័យដូចម្ដេចខ្លះ ? ចូរពន្យល់

**ឆ** – នីវរណធម៌ទាំង ៥ នេះ មានន័យដូចនេះ :

ធម៌ជានីវរណៈ នេះជាធម៌ដែលពោរពេញ ដោយអកុសលផ្សេង ៗ សម្រាប់រាំងរាំងបាំងចិត្តដែលល្អបរិសុទ្ធ មិនឲ្យឃើញពន្លឺ គឺឲ្យប្រព្រឹត្តតែអបាយមុខ , ធ្វើចិត្តឲ្យកករល្អក់ ប្រើការមិនកើត , ជាគ្រឿងធ្វើចិត្តឲ្យប្រកបដោយមិច្ឆាទិដ្ឋិជានិច្ច ។

ម្យ៉ាងទៀតកាមច្ឆន្ទៈ លោកប្រៀបដូចជាទឹកថ្លាមានកក់ជ្រាំប្លុមខ្ចិល នៅពីលើ , ព្យាបាទដូចជាទឹកកំពុងពុះ , ថីនមិទ្ធៈ ដូចជាទឹកមានចកបុស្សកាយ, ឧទ្ធច្ចកុក្កុច្ចៈ ដូចជាទឹករលក , វិចិកិច្ឆាដូចជាទឹកដែលគេយកដីទៅដាក់ឲ្យកករល្អក់ , ទឹកដែលថ្លាធម្មតាគេអាចមើលឃើញអ្វី ៗ នៅក្នុងនោះឬក៏អាចឆ្លុះបាន , កាលបើមានមន្ទិលអ្វីមួយហើយ គេពុំអាចមើលឃើញឬឆ្លុះបានឡើយ , យ៉ាងណាមិញ នីវរណធម៌ក៏ធ្វើចិត្តឲ្យអ័ព្ទអួរយ៉ាងនោះដែរ ។

**ស** – ចុះនីវរណធម៌ទាំង ៥ នេះ មានចែកដូចម្ដេចទៀតដែរឬទេ ? ចែកអង្គណាខ្លះ ? មានប៉ុន្មាន ? គឺអ្វីខ្លះ ?



**ឆ** – នីវរណធម៌ទាំង ៥ នេះ លោកចែកតែកាមច្ឆន្ទៈមួយទេដែលមាន ៥ យ៉ាងគឺ :

**១ – បរិយេសនច្ឆន្ទៈ** ការប្រាថ្នាស្វែងរកកាមគុណ ;

**២ – បដិលាភច្ឆន្ទៈ** ការប្រាថ្នាចង់បាននូវកាមគុណ ;

**៣ – បរិភោគច្ឆន្ទៈ** ការប្រាថ្នាប្រើប្រាស់កាមគុណ ;

**៤ – សន្និធិច្ឆន្ទៈ** ការប្រាថ្នាសន្សំនូវកាមគុណ ;

**៥ – វិស្សជ្ជនច្ឆន្ទៈ** ការប្រាថ្នាលះបង់នូវវត្ថុផ្សេង ៗ ដើម្បីកាមគុណ,

**ស** – តើ នីវរណធម៌ទាំង ៥ នេះ គេត្រូវរម្ងាប់ដោយធម៌អ្វីខ្លះ ?

**ឆ** – នីវរណធម៌ទាំង ៥ នេះគេត្រូវរម្ងាប់ដោយធម៌ផ្សេង ៗ ដូច្នេះ

**១ – កាមច្ឆន្ទៈ** ត្រូវរម្ងាប់ដោយកាយគតានុស្សតិកម្មដ្ឋាន និងអសុភកម្មដ្ឋាន ,

**២ – ព្យាបាទ** ត្រូវរម្ងាប់ដោយការចំរើនគឺទន្ទេញ រឿយ ៗ នូវមេត្តា ,

**៣ – ថីនមិទ្ធៈ** ត្រូវរម្ងាប់ដោយការចំរើននូវពុទ្ធគុណ គឺកុសលដែលខ្លួនបានបំពេញរួចមកហើយ ,

**៤ – ឧទ្ធច្ចកុក្កុច្ចៈ** ត្រូវរម្ងាប់ដោយការសម្លឹងមើលកសិណរឿយៗ ដើម្បីឲ្យចិត្តតាំងនៅនឹងនឹង ,

**៥ – វិចិកិច្ឆា** ត្រូវរម្ងាប់ដោយការចំរើននូវកម្មដ្ឋាន ។

## វេសារជ្ជករណធម៌ ៥

**ស** – វេសារជ្ជករណធម៌ ប្រែថាដូចម្តេច ?

**ឆ** – វេសារជ្ជករណធម៌ ប្រែថាធម៌ធ្វើឲ្យក្លាហាន ។

**ស** – វេសារជ្ជករណធម៌នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** – មាន ៥ គឺ :

១– **សទ្ធា** ជឿរបស់ដែលគួរជឿ

២– **សីល** តម្រឹមកាយវាចាឲ្យរៀបរយ

៣– **ពាហុសច្ចៈ** ចេះចាំច្រើន

៤– **វិរិយារម្ភៈ** ប្រកាន់ខ្ជាប់នូវសេចក្តីព្យាយាម

៥– **បញ្ញា** ដឹងខុសត្រូវ

**ស** – តើធម៌ទាំង ៥ នេះមានន័យយ៉ាងណាខ្លះ ? ចូរបំភ្លឺ !

**ឆ** – មានន័យដូច្នេះ :

ជំនឿក្នុងទីនេះសំដៅយកជំនឿ ដែលបានត្រិះរិះពិចារណារកហេតុផលដោយសព្វគ្រប់ ដែលហៅថាសទ្ធាញាណសម្បយុត្ត ។

ការរក្សាសីលតាមភូមិរបស់ខ្លួន គឺសីល ៥, សីល ៨, សីល ១០ សិក្ខាបទ ២២៧ ប្រភេទណាទីមួយក៏ដោយចុះ ហ្វឹកហ្វឺនហាត់ពត់កាយវាចាឲ្យរៀបរយល្អ មិនឲ្យមានទោសទោមនស្ស ។

ភាពជាអ្នកសិក្សាច្រើន គឺអ្នកបានរៀនសូត្រចេះចាំនូវសិល្បសាស្ត្រ



ទាំងផ្លូវលោកផ្លូវធម៌ មិនរើសចាល់ អាចដោះស្រាយបញ្ហាស្មុគស្មាញដែលកើតមានចំពោះខ្លួននិងអ្នកដទៃ ។

ការបំពេញសេចក្តីព្យាយាមគឺការតាំងព្យាយាមក្នុងកិច្ចការ មិនធ្វេសប្រហែស, មិនឈប់ឈរ, មានសេចក្តីក្លាហានមោះមុតមិនខ្លាចឧបសគ្គណាមួយដែលមាននៅជាចន្លោះ ។ បំណងផលគឺការបានសម្រេចជាទីបំផុត ។ តែគប្បីជឿស៊ប់ថាព្យាយាមក្នុងទីនេះសំដៅយកព្យាយាមដែលមិនមានទោសប្រាសចាកទោស ។

ការចេះដឹងស្គាល់ខុសត្រូវទាំងផ្លូវធម៌ឈ្មោះថាបញ្ញា ។

កាលបើបានបំពេញវេសារជ្ជករណធម៌ នេះហើយរមែងមានសេចក្តីក្លាហានអង់អាច មានសមត្ថភាពចេះដោះស្រាយឧបសគ្គផ្សេង ៗ បានដោយឆាប់រហ័ស, បើចូលទៅក្នុងទីប្រជុំណាមួយទោះបីក្នុងសង្គមធំក្តីតូចក្តី ក៏មានវោហារ, និយាយគេយកចិត្តទុកដាក់ស្តាប់ព្រោះថាសំដីមានខ្លឹមសារគួរគេយកតម្រាប់តាមបាន ។

## ខន្ធ ៥

**ស** – ខន្ធ ប្រែដូចម្តេច ?

**ឆ** – ខន្ធ ប្រែថាគង, គំនរ

**ស** – ខន្ធ នេះមានប៉ុន្មានពួក ? គឺអ្វីខ្លះ ?

**ឆ** – ខន្ធ នេះចែកជា ៥ ពួកគឺ :

១ – **រូប** រូប

២ – **វេទនា** ការសោយអារម្មណ៍

៣ – **សញ្ញា** ការសំគាល់អារម្មណ៍

៤ – **សង្ខារ** ការតាក់តែងអារម្មណ៍

៥ – **វិញ្ញាណ** ការដឹងច្បាស់នូវអារម្មណ៍

**ស** – តើខន្ធទាំង ៥ នេះប្រែដូចម្តេចខ្លះ ? មានន័យយ៉ាងណាខ្លះ ? ចូរពន្យល់ !

**ឆ** – ខន្ធទាំង ៥ នេះមានសេចក្តីប្រែនិងន័យដូច្នេះ :

១ – **រូប** ប្រែថាធម្មជាតិវិនាសទៅដោយវិរោធប្បច្ច័យមានក្តៅ ហួសប្រមាណត្រជាក់ហួសប្រមាណជាដើម ។ មានន័យថាធាតុ ៤ គឺទឹកភ្លើងខ្យល់ដីប្រជុំគ្នា មកតាក់តែងឲ្យមានឡើងហៅថារូប ។

២ – **វេទនា** ប្រែថាធម្មជាតិ សោយអារម្មណ៍គឺបើជាសុខ ក៏ សប្បាយកាយសប្បាយចិត្ត, បើជាទុក្ខ មិនសប្បាយកាយ, មិនសប្បាយ ចិត្ត បើជាឧបេក្ខា ក៏ព្រងើយកន្តើយ មិនសុខមិនទុក្ខលំបាក ។

៣ – **សញ្ញា** ការសំគាល់រូបសំឡេង , មានន័យថាការកត់សំ គាល់ចាំបាននូវរូបសម្លេងជាដើម ដែលកើតឡើងចំពោះចិត្ត ។

៤ – **សង្ខារ** ធម្មជាតិតាក់តែងអារម្មណ៍ បានដល់ការគិត ដែលកើតឡើងជាមួយនឹងចិត្ត សង្ខារក្នុងទីនេះមានសេចក្តីផ្សេងគ្នាពី



សង្ខារធម៌ក្នុងសាមញ្ញលក្ខណៈ ប៉ុន្តែមានលក្ខណៈដូចគ្នាគឺមិនទៀង ជាទុក្ខជាអនត្តា ។

៥ – **វិញ្ញាណ** ការដឹង បានដល់ការដឹងជាក់ច្បាស់នូវអារម្មណ៍ក្នុងកាលដែលរូបមកប៉ះពាល់នឹងអាយតនៈ ឧទាហរណ៍ដូចជាក្លិនមកប៉ះពាល់និងសោតៈ, វិញ្ញាណក៏សម្គាល់បានថាក្លិននោះស្អុយ ឬក្រអូបបាន ភ្លាមមួយរំពេច ។

## អង្គនៃភិក្ខុ ៥ យ៉ាង

**ស** – ដូចម្តេចហៅថាអង្គនៃភិក្ខុ ? មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ** – កិច្ចដែលភិក្ខុត្រូវប្រតិបត្តរៀងរាល់ថ្ងៃ ហៅថាអង្គរបស់ភិក្ខុ អង្គរបស់ភិក្ខុនេះមាន ៥ យ៉ាងគឺ :

១ – សង្រួមក្នុងបាតិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាមធ្វើ តាមច្បាប់ដែលទ្រង់បានអនុញ្ញាត ,

២ – សង្រួមឥន្ទ្រិយ ប្រយ័ត្នភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឲ្យទោមនស្សពេក ឬសោមនស្សពេក សង្កត់ក្នុងវេលាដែលជួបប្រទះអារម្មណ៍ផ្សេងៗ ។

៣ – ជាអ្នកមិននិយាយសប្បាយហួសហេតុ

៤ – នៅក្នុង សេនាសនៈស្ងាត់

៥ – ឃើញតែការត្រូវ គឺមានសេចក្តីឃើញត្រូវ

**ស** – អង្គនៃកិច្ចទាំង ៥ នេះមានសេចក្តីអធិប្បាយដូចម្តេចដែរ ?

**ឆ** – មានសេចក្តីអធិប្បាយដូចនេះ :

កុលបុត្រដែលមានភ័ពវាសនា មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសន បានលះបង់ គេហដ្ឋានចូលមកបួសរៀនកាន់ធម៌វិន័យនៃព្រះពុទ្ធជាម្ចាស់ គប្បីប្រព្រឹត្តប្រតិបត្តិធម៌ ៥ យ៉ាងនេះ ឲ្យបានតឹងរ៉ឹងកុំឲ្យល្អៀងឃ្លៀ ឃ្លាត, ព្រោះថា :

– ការសង្រួមក្នុងបាតិមោក្ខ ជាហេតុឲ្យសីលបរិសុទ្ធ

– ការសង្រួមក្នុងឥន្ទ្រិយជាហេតុឲ្យចិត្តស្ងប់ មិនរវើរវាយ ជា មនុស្សស្ងប់ស្ងៀម សមរម្យជាសមណៈ,

– ការនៅក្នុងសេនាសនៈដ៏ស្ងាត់ ជាហេតុឲ្យបានកាយវិវេកសមគួ ដល់ការបំពេញសមណធម៌,

– មានសេក្តីឃើញត្រូវ ជាហេតុឲ្យប្រតិបត្តតាមគន្លងធម៌ ។

កាលបើបព្វជិតបានប្រតិបត្តធម៌ ៥ នេះដូចពោលមកហើយ រមែង បានសេចក្តីសុខចំរើនល្អតលាស់ ក្នុងព្រះពុទ្ធសាសនាជាកិរិយាភាព ត រៀងទៅ ។

## អង្គនៃធម្មកថិក ៥

**ស** – ដូចម្តេចហៅថា អង្គនៃធម្មកថិក ? មានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** – កិច្ចដែលបព្វជិត ឬ គ្រហស្ថដែលជាអ្នកបកស្រាយនូវធម៌ហៅ



ថា អង្គនៃធម្មកថិក ។ អង្គនៃធម្មកថិកនេះមាន ៥ យ៉ាងគឺ :

**១ – អនុបុព្វិកថំ កថេស្សាមិ** អាត្មានឹងសំដែងតាមលំដាប់ មិនកាត់ប្រួត ឬ វែងពេក ខូចសេចក្តីនៃធម៌,

**២ បរិយាយទស្សាវីកថំ កថេស្សាមិ** អាត្មាអញនឹងសំដែង ដោយលើកយកហេតុផលមកសំអាង ណែនាំឲ្យអ្នកស្តាប់ចូលចិត្ត,

**៣ – អនុទ្ទយតំ កថំ កថេស្សាមិ** អាត្មាអញនឹងសំដែង តាំងចិត្តមេត្តា ឲ្យជាប្រយោជន៍ដល់អ្នកស្តាប់,

**៤ – ន អាមិសន្តរោ កថំ កថេស្សាមិ** អាត្មាអញនឹងមិនសំដែងធម៌ ព្រោះឃើញអាមិសៈ

**៥ – អត្តានញ្ច អនុបហច្ច កថំ កថេស្សាមិ** អាត្មាអញនឹងសំដែងធម៌ មិនលើកខ្លួនហើយបន្តុះបង្អាប់អ្នកដទៃ ។

**ស** – តើអង្គទាំង ៥ នេះមានន័យយ៉ាងណាខ្លះ ? ចូរពន្យល់ !

**ឆ** – អង្គទាំង ៥ នេះមានន័យដូចតទៅនេះ :

១ – ការសំដែងធម៌តាមលំដាប់ តាំងពីជាន់ទាបរហូតដល់ជាន់ខ្ពស់ មិនចាប់ចុងព្រយុងដើម មិនកាត់ឲ្យខូចន័យ ទោះបីសំដែងដោយសង្ខេបឬពិស្តារក៏ដោយ, ស្រេចហើយតែឱកាសឬវេលាហុចមកឲ្យ កុំឲ្យតែខូចសេចក្តីដែលសំខាន់ ៗ ។

២ – ត្រូវសំដែងអាងហេតុផល ដឹកនាំបន្តុលបង្ហាញព្រមដោយឧប

មេធ្យ ឲ្យអ្នកស្ដាប់ចូលចិត្តច្បាស់ជាក់ មិនឲ្យមានសន្ទឹសសង្ស័យពាក្យ ឧទាហរណ៍ អំពីកម្មផលឲ្យច្បាស់លាស់ដូចជាសម្លឹងមើលវត្ថុផ្សេងៗ ឃើញប្រត្យក្សនឹងភ្នែក ។

៣ — ត្រូវតាំងចិត្តមេត្តា ប្រាថ្នាឲ្យអ្នកស្ដាប់ទទួលប្រយោជន៍ពិតៗ មិនសំដែងឲ្យតែរួចខ្លួនឡើយ ដោយវិធីធ្វើទុកក្នុងចិត្តថាធ្វើវិធីណាទើបពួកអ្នកស្ដាប់នេះយល់ច្បាស់នូវធម៌ រួចហើយគេនឹងបានសេចក្ដីសុខព្រោះធម៌ជាដើម ។

៤ — គួរជាអ្នកអត់ធន់ក្នុងធម៌ គោរពធម៌ បំណងប្រកាសសាសនធម៌ជាទីតាំង ដើម្បីឲ្យព្រះសទ្ធម្មផ្សាយទៅក្នុងសាវកមណ្ឌល ប្រយោជន៍អនុគ្រោះ និងសេចក្ដីសុខដល់ជនច្រើនគ្នា , មិនធ្ងន់ក្នុងលាភនិងសក្ការ: គឺមើលឃើញគ្រឿងអាមិស: , បើបំណងលាភជាធំ កាលឃើញអាមិសច្រើន ក៏នឹងសំដែងដោយពេញចិត្ត បើឃើញគ្រឿងអាមិសតិច ក៏នឹងសំដែងដោយមិនពេញចិត្ត , ការធ្វើដូចនេះ មិនមែនជាធម្មកថិកដែលពេញចិត្តចំពោះព្រះពុទ្ធសាសនាឡើយផ្ទុយទៅវិញ ជាអ្នកបន្ទុះបង្អាប់សាសនាឲ្យលិចលង់ ដោយសារលាភសក្ការ: ។

៥ — មិនគប្បីប្រកាន់យកការសំដែងធម៌ដោយលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃដោយចេតនាអាក្រក់ ហើយមិនគប្បីលើកខ្លួន សង្កត់សង្កិនអ្នកដទៃក្នុងពេលសំដែងធម៌ឡើយ ។



ធម្មកថិកកាលបើប្រកបដោយអង្គទាំង ៥ ដូចពោលមកហើយនេះ បាត់ជាធម្មកថិកដ៏ល្អ ជាទីសរសើរនៃបណ្ឌិតជន ។

## ធម្មស្សវនានិសង្ស ៥ យ៉ាង

ស — ធម្មស្សវនានិសង្ស ប្រែដូចម្ដេច ?

ឆ — ធម្មស្សវនានិសង្ស ប្រែថា អានិសង្សនៃការស្ដាប់ធម៌ឬផល ដែលកើតអំពីការស្ដាប់ធម៌ ។

ស — អានិសង្សស្ដាប់ធម៌នេះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ — អានិសង្សស្ដាប់ធម៌នេះមាន ៥ យ៉ាងគឺ:

១ — អស្សុតំ សុណាតិ ស្ដាប់ធម៌ដែលមិនធ្លាប់ស្ដាប់

២ — សុតំ បរិយោទបេតិ ធ្វើចិត្តឲ្យចូលស៊ប់ចំពោះធម៌ដែលបានស្ដាប់រួចហើយ ,

៣ — កង្ខំ វិហនតិ កំចាត់បោលនូវការសន្ទឹសសង្ស័យ

៤ — ទិដ្ឋឹ ឧជុំ ករោតិ ធ្វើទិដ្ឋិឲ្យត្រង់

៥ — ចិត្តស្ស បសីទតិ អ្នកស្ដាប់នោះរមែងមានចិត្តជ្រះថ្លា ។

ស — ចូរពន្យល់ឲ្យល្អមស្ដាប់នូវអានិសង្សនេះមកមើល ?

ឆ — អានិសង្សទាំង ៥ នេះ កើតមានដល់អ្នកស្ដាប់ដែលជាអ្នកយកចិត្តទុកដាក់ក្នុងការស្ដាប់ បញ្ជូនក្រសែចិត្ត ទៅតាមលំដាប់ធម៌, ពិចារណាហើយយល់នូវធម៌ មិនឲ្យសៅហ្មង , មិនធ្វើចិត្តឲ្យរវើរវាយបាក

ធម៌ សមដូចភាសិតថា : សុស្សូសំ លភតេ បញ្ញំ ប្រែថា ការស្តាប់ដោយល្អ រមែងមានបញ្ញា ការតាំងចិត្តដូច្នេះ រមែងសម្រេចប្រយោជន៍នៃការស្តាប់គឺ អានិសង្សដូចពោលមកហើយ ។

មួយវិញទៀតពាក្យភាសិតរមែងបានផលដល់អ្នកស្តាប់ ហើយគោរពដូចផ្កាឈើដែលមានទ្រង់ទ្រាយសណ្ឋានល្អ ទាំងពណ៌សម្បុរក៏ល្អ ក្លិនក៏ក្រអូបរមែងផ្សាយទៅក្នុងកាយអ្នកអ្នកទ្រទ្រង់ដូច្នោះ ។

ចប់ពួកធម៌ ៥

---

# ឆក្កៈ ពួកធម៌ ៦

## គារវៈ ៦ យ៉ាង

ស — គារវតា មានន័យថាដូចម្តេច ?

ឆ — គារវតា គឺការគោរព, ភាពនៃការគោរពកោតខ្លាច ។

ស — គារវតា មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ — គារវតា មាន ៦ យ៉ាងគឺ:

១ — **ពុទ្ធគារវតា** គោរពព្រះពុទ្ធ

២ — **ធម្មគារវតា** គោរពព្រះធម៌

៣ — **សង្ឃគារវតា** គោរពព្រះសង្ឃ

៤ — **សិក្ខាគារវតា** គោរពការសិក្សារៀនសូត្រ

៥ — **អប្បមាទគារវតា** គោរពការមិនប្រមាទ

៦ — **បដិសណ្ឋារគារវតា** គោរពបដិសណ្ឋារៈ

ស — តើគារវៈទាំង ៦ នេះមានន័យដូចម្តេចខ្លះ ? ចូរពន្យល់ !

ឆ — គារវៈទាំង ៦ នេះមានន័យដូចនេះគឺ

ការគោរពព្រះពុទ្ធ បានដល់ការក្រាបសំពះបូជាគុណរបស់ព្រះអង្គ, សិក្សាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ, យកពាក្យប្រៀនប្រដៅទៅផ្សាយប្រាប់មហាជន, រហូតដល់បូជា បូជនីយវត្ថុ មានព្រះពុទ្ធបដិមាជាដើម ។

ទាំងនេះឈ្មោះថាពុទ្ធគារវតា ។

ការគោរពព្រះធម៌បានដល់ការរៀនព្រះបរិយត្តិធម៌, ប្រតិបត្តិតាមធម៌ន័យមិនឲ្យល្មៀងឃ្លៀងឃ្លាត ឈ្មោះថាធម្មគារវតា ។

ការគោរពព្រះសង្ឃមានពីរគឺ សម្មតិសង្ឃ១, អរិយសង្ឃ ឬវិសុទ្ធិសង្ឃ១ ដោយកិច្ចទាំងឡាយមានការថ្វាយបង្គំ និងការក្រោកទទួលជាដើម, ការស្ដាប់ឱវាទដោយយកចិត្តទុកដាក់ សិក្សាឲ្យបានម៉ត់ចត់នូវពាក្យទូន្មានរបស់លោកឈ្មោះថា សង្ឃគារវតា ។

ការគោរពការសិក្សារៀនសូត្រ បានដល់ការតាំងចិត្តសិក្សា សិល្ប-សាស្ត្រ តាមផ្លូវលោក ផ្លូវធម៌ យកចិត្តទុកដាក់មិនខ្ជិលច្រអូស, បង្ហើយកិច្ចការផ្សេងៗដែលជាកិច្ចរបស់ខ្លួនឈ្មោះថា សិក្ខាគារវតា ។

គោរពការមិនធ្វេសប្រហែស បានដល់ការតាំងសតិឲ្យមាំមួន មិនភ្លេចខ្លួនក្នុងការលះបង់អំពើទុច្ចរិតហើយប្រព្រឹត្តសុចរិត ឬប្រុងប្រយត្នមិនឲ្យក្រោធ មិនឲ្យមោហៈមកគ្របសង្កត់ ឈ្មោះថាអប្បមាទគារវតា ។

ការគោរពបដិសណ្ឋារៈ បានដល់ការទទួលយកដោយសោមនស្សនូវអាមិសទានក្តី, ធម្មទានក្តី មិនសំដែងការអាក់អន់ស្រពន់ចិត្ត ពោះបីបានពោះល្អក្តី អាក្រក់ក្តី ថោកក្តី ថ្លៃក្តី ឈ្មោះថា បដិសណ្ឋារគារវតា ។



## អាយតនៈខាងក្នុង ៦

**ស**– អាយតនៈ មានន័យដូចម្តេច ?

**ឆ** – អាយតនៈ ធម្មជាតជាគ្រឿងតគឺតផលដូចជារូបមកតភ្នែក ហើយកើតផលគឺវិញ្ញាណឡើងជាដើម ។

**ស** – អាយតនៈ បើគេមិនហៅថាអាយតនៈទេ គេហៅដូចម្តេចបានវិញ ? ព្រោះអ្វី ?

**ឆ** – អាយតនៈ បើគេមិនហៅដូចនេះទេ គេហៅថាឥន្ទ្រិយវិញក៏បាន ព្រោះឥន្ទ្រិយប្រែជាធម្មជាតជាធំក្នុងការឃើញរូប ជាធំក្នុងការស្តាប់សម្លេងជាអាទិ៍ ។

**ស** – អាយតនៈ ខាងក្នុងមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ** – អាយតនៈ ខាងក្នុងមាន ៦ គឺ:

១– **ចក្ខុ** ភ្នែក

២– **សោត :** ត្រចៀក

៣– **ឃាន :** ច្រមុះ

៤ – **ជិវ្ហា :** អណ្តាត

៥ – **កាយ :** ខ្លួនប្រាណ

៦ – **មនោ** ចិត្ត

**ស** – អាយតនៈ ទាំង ៦ នោះបើបំប្រួញឲ្យខ្លីមកមានប៉ុន្មាន ?

គឺអ្វីខ្លះ ?

ឆ – អាយតនៈ ទាំង ៦ នោះ បើរួមមកមានតែពីរគឺ កាយ ១ ចិត្ត ១ បើចំប្រួញចូលក្នុងខន្ធ ៥ ក៏បាន ដូចជា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចាត់ជារូប , ចិត្តចាត់ចូលក្នុងវិញ្ញាណ ។

ស – អាយតនៈ ខាងក្នុងមាន ៦ តើអាយតនៈ ខាងក្រៅមានប៉ុន្មានដែរ ? គឺអ្វីខ្លះ ?

ឆ – អាយតនៈ ខាងក្រៅមាន ៦ ដែរគឺ :

| | |
|---|---|
| ១ – រូប | ៤ – រស |
| ២ – សម្លេង | ៥ – ផោដ្ឋព្វ |
| ៣ – ក្លិន | ៦ – ធម្មារម្មណ៍ |

ស – តើអាយតនៈ ខាងក្រៅ ៦ នេះមានន័យដូចម្តេចខ្លះ ? ចូរពន្យល់ !

ឆ – អាយតនៈ ខាងក្រៅ ៦ នេះមានន័យដូចនេះ :

អាយតនៈ ទាំង ៦ នេះត្រាច់ចរមកខាងក្រៅឬហៅថាអារម្មណ៍ក៏បាន ព្រោះជាធម្មជាតិបង្អោនទាញចិត្តឲ្យប្រព្រឹត្តទៅក្នុងទីផ្សេង ៗ តាមវិស័យរបស់ខ្លួន ៗ អារម្មណ៍ទាំងនេះជាគូនឹងអាយតនៈ ខាងក្នុងតែមួយ ៗ ដូចជាវិស័យភ្នែកគឺរូបជាដើម , អារម្មណ៍ទាំងនេះ ជាទីពេញចិត្តក្តី មិនពេញចិត្តក្តី របស់អារម្មណ៍ខាងក្នុង ក៏សម្រេចហើយតែនឹងអារម្មណ៍នោះល្អឬមិនល្អប៉ុណ្ណោះ ។



## វិញ្ញាណ ៦ យ៉ាង

ស – វិញ្ញាណប្រែដូចម្តេច ?

ឆ – វិញ្ញាណ ប្រែថាការដឹងច្បាស់នូវអារម្មណ៍ផ្សេង ៗ ។

ស – វិញ្ញាណ នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ – វិញ្ញាណនេះមាន ៦ យ៉ាងគឺ :

១ – **ចក្ខុវិញ្ញាណ** វិញ្ញាណគឺភ្នែក

២ – **សោតវិញ្ញាណ** វិញ្ញាណគឺត្រចៀក

៣ – **ឃានវិញ្ញាណ** វិញ្ញាណគឺច្រមុះ

៤ – **ជិវ្ហាវិញ្ញាណ** វិញ្ញាណគឺអណ្តាត

៥ – **កាយវិញ្ញាណ** វិញ្ញាណគឺកាយ

៦ – **មនោវិញ្ញាណ** វិញ្ញាណគឺចិត្ត

ស – តើវិញ្ញាណទាំង ៦ នេះមានន័យដូចម្តេច ? ចូរពន្យល់ !

ឆ – មានន័យថា ការដឹងដែលកើតអំពីអាយតនៈ ខាងក្នុង វេលាជួបប្រទះនឹងអាយតនៈ ខាងក្រៅ ដូចជាភ្នែកឃើញរូបត្រចៀកស្តាប់សម្លេងជាដើម ហៅថាវិញ្ញាណ , មានឈ្មោះហៅតាមអាយតនៈ ខាងក្នុងថាចក្ខុវិញ្ញាណជាដើម , វិញ្ញាណនេះជាសេចក្តីដឹងមុនដំបូងថាជាសុខឬជាទុក្ខនៅមិនទាន់បាន ព្រោះគិតត្រឹមតែការដឹងប៉ុណ្ណោះ បើជាសុខឬជាទុក្ខប្រព្រឹត្តទៅយ៉ាងណាត្រូវមានឈ្មោះដូចនោះទៅទៀត ។

**ស** – ផោដ្ឋព្វ ប្រែដូចម្តេចដែរ

**ឆ** – ផោដ្ឋព្វ ប្រែថាការពាល់ត្រូវ

**ស** – សម្ផស្ស ប្រែដូចម្តេចដែរ ?

**ឆ** – សម្ផស្សៈ ក៏ប្រែថាការប៉ះពាល់ដែរ

**ស** – ចុះបើផោដ្ឋព្វ និង សម្ផស្សៈ ប្រែដូចគ្នា ដូច្នេះតើមានន័យដូចគ្នាឬផ្សេងគ្នា ? ចូរពន្យល់ !

**ឆ** – ប្រែដូចគ្នាមែនពិតតែន័យនៃពាក្យទាំងពីរនេះ ផ្សេងគ្នាគឺ : ផោដ្ឋព្វៈ ការពាល់ត្រូវតាមផ្លូវកាយដូចជាប៉ះទង្គិចនឹងឈើ, ដើរប៉ះគ្នាជាដើម ។ ឯសម្ផស្សបានដល់ការប៉ះពាល់អាយតនៈខាងក្នុង ដូចជាអារម្មណ៍គឺរូបមកប៉ះនឹងភ្នែកជាដើម ; ហៅថាចក្ខុសម្ផស្ស , សោតសម្ផស្ស

## សម្ផស្ស ៦ យ៉ាង

**ស** – ដូចម្តេចដែលថាសម្ផស្ស ? មានប៉ុន្មាន ? គឺអ្វីខ្លះ

**ឆ** – អាយតនៈ ខាងក្នុងមានភ្នែកជាដើម អាយតនៈ ខាងក្រៅមានរូបជាដើម វិញ្ញាណមានចក្ខុវិញ្ញាណជាអាទិ៍ ទាំង ៣ នេះឈ្មោះថាសម្ផស្ស ១, មាន ៦ យ៉ាងតាមអាយតនៈ ទាំង ៦ ដូច្នេះ

១ – **ចក្ខុសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមភ្នែក

២ – **សោតសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមត្រចៀក

៣ – **ឃានសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមច្រមុះ



៤ – **ជិវ្ហាសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមអណ្តាត

៥ – **កាយសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមកាយ

៦ – **មនោសម្ផស្ស** ពាល់ត្រូវអារម្មណ៍ តាមចិត្ត

**ស** – សម្ផស្សទាំង ៦ នេះ តើមានន័យដូច[illegible] ចូរពន្យល់ !

**ឆ** – សម្ផស្ស ការប៉ះពាល់ឬការជួបប្រទះគ្នារវាងធម៌ ៣ គឺអាយតនៈ ខាងក្នុង អាយតនៈ ខាងក្រៅនិងវិញ្ញាណ ។ ការជួបគ្នានៃធម៌ ៣ នេះចាត់ជាអង្គសំខាន់ ព្រោះជាបច្ច័យឲ្យកើតសុខទុក្ខបាន ។ លោកទូន្មានឲ្យសង្រួមអាយតនៈខាងក្នុង ដើម្បីឲ្យមានសតិ ប្រុងប្រយ័ត្នមិនបណ្តោយឲ្យចិត្តរវើរវាយទៅតាមអារម្មណ៍ ដែលជាហេតុឲ្យមានក្តីវិនាសបាន ។

## វេទនា ៦ យ៉ាង

**ស** – វេទនា មានន័យយ៉ាងណា ?

**ឆ** – វេទនា ប្រែថា ធម្មជាតិសោយនូវអារម្មណ៍, ការសោយរង

**ស** – អ្វីជាបច្ច័យឲ្យកើតវេទនា ? វេទនាមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** – សម្ផស្សជាបច្ច័យឲ្យកើតវេទនា , វេទនាមាន ៦ យ៉ាងគឺ .

១ – **ចក្ខុសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់ត្រូវតាមភ្នែក ,

២ – **សោតសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់

ត្រូវតាមត្រចៀក ,

**៣ – ឃានសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់ត្រូវតាមច្រមុះ ,

**៤ – ជិវ្ហាសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់ត្រូវតាមអណ្តាត ,

**៥ – កាយសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់ត្រូវតាមកាយ ,

**៦ – មនោសម្ផស្សវេទនា** ការសោយអារម្មណ៍កើតពីការពាល់ត្រូវតាមផ្លូវចិត្ត ,

**ស –** តើវេទនាទាំង ៦ នេះមួយ ៗ មានន័យយ៉ាងណាទៀត ? ចូរពន្យល់ !

**ឆ –** មានន័យដូច្នេះគឺ

អាយតនៈខាងក្នុង ១, អាយតនៈខាងក្រៅ ១ វិញ្ញាណ ១ រួមមកហៅថាផស្សៈ, ជាបច្ច័យឲ្យកើតវេទនា គឺការសោយអារម្មណ៍ជាសុខក៏មានជាទុក្ខក៏មាន មិនមែនសុខមិនមែនទុក្ខ គឺឧបេក្ខាក៏មាន ឧទាហរណ៍ដូចរូបមកប៉ះភ្នែក កើតការដឹងឡើង ហៅថាចក្ខុវិញ្ញាណ ។ ធម៌ ៣ គឺរូប ១, ចក្ខុ ១, ចក្ខុវិញ្ញាណ ១, ហៅថាសម្ផស្ស កើតជាវេទនា ។ បើរូបល្អពេញចិត្ត ការពេញចិត្តចូលចិត្តជាសុខ, បើ រូបអាក្រក់ មិនគាប់ចិត្ត ការទោ



មនស្សនេះជាទុក្ខ, បើជាកណ្តាល មិន ទោមនស្ស ឬមិនសោមនស្ស ឈ្មោះថាឧបេក្ខាវេទនា ។

## ធាតុ ៦ យ៉ាង

**ស –** ធាតុ ប្រែថាដូចម្តេច ?

**ឆ –** ធាតុ ប្រែថាការទ្រទ្រង់ , ការតាំងនៅ ។

**ស –** ធាតុនេះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូររាប់ ?

**ឆ –** ធាតុនេះមាន ៦ យ៉ាងគឺ :

**១ – បឋវីធាតុ** ធាតុដី

**២ – អាបោធាតុ** ធាតុទឹក

**៣ – តេជោធាតុ** ធាតុភ្លើង

**៤ – វាយោធាតុ** ធាតុខ្យល់

**៥ – អាកាសធាតុ** ចន្លោះដែលមានក្នុងកាយ

**៦ – វិញ្ញាណធាតុ** ការដឹងគ្រប់ដំពូក

**ស –** តើធាតុទាំង ៦ នោះដូចម្តេចខ្លះ ? ចូររៀបរាប់ !

**ឆ –** ធាតុទាំង ៦ នោះគឺ :

– បឋវីធាតុ ធាតុដី គឺរបស់អ្វី ដែលមានក្នុងរូបកាយដែលអាចទៅជាដី ដូចជាសាច់, សរសៃ, ឆ្អឹងជាដើម ។

– អាបោធាតុ ធាតុទឹក គឺទឹកដែលមានក្នុងរូបកាយមានញើស ,

ទឹកមូត្រ , ឈាមជាដើម ។

- តេជោធាតុ ធាតុភ្លើង គឺធាតុដែលសំរាប់កំដៅរូបកាយដូចជាកំដៅអាហារឲ្យម៉ត់ , ធ្វើសរីរៈមិនឲ្យត្រជាក់ ។

- វាយោធាតុ ធាតុខ្យល់ គឺធាតុដែលធ្វើឲ្យយើងដកដង្ហើមចេញចូលបាន ដូចជាចក់អាហារឲ្យចុះឡើង, បញ្ចេញខ្យល់ស្រូបយកវិញ ។

- អាកាសធាតុ ធាតុដែលប្រហោង គឺធាតុដែលទំនេរពិបាកកំណត់ ដូចជាប្រហោងត្រចៀក , រន្ធច្រមុះជាដើម ។

- វិញ្ញាណធាតុ ធាតុដែលសំរាប់ធ្វើឲ្យដឹង គឺការដឹងយល់មានស្មារតីរឹងប៉ឹង អាចស្ទាបនាវត្ថុផ្សេងៗ បានដូចវិទ្យុ-អគ្គិសនីជាដើម ។

## សារាណីយធម៌ ៦ យ៉ាង

**ស** — សាកណីយធម៌ ប្រែដូចម្តេច ? មានន័យដូចម្តេច ?

**ឆ** — សាកណីយធម៌ ប្រែថាធម៌ជាគ្រឿងរលឹក ឬធម៌ជាទីតាំងនៃការរលឹក ។ មានន័យថាបុគ្គលដែលប្រតិបត្តិធម៌ រមែងបានទទួលនូវអានិសង្សគឺជាទីស្រឡាញ់របស់បុគ្គលដទៃ , ជាទីគោរពនៃមហាជនប្រព្រឹត្តទៅដើម្បីសង្គ្រោះដល់គ្នានឹងគ្នា រមែងកើតសាមគ្គីធម៌ ។

**ស** — ចុះសាកណីយធម៌នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** — សាកណីយធម៌នេះមាន ៦ យ៉ាងគឺ :

**១ — មេត្តាកាយកម្ម** តាំងកាយកម្ម គឺអំពើប្រព្រឹត្តដោយកាយឲ្យប្រកបដោយមេត្តា ចំពោះភិក្ខុសាមណេរផងគ្នាទាំងចំពោះមុខ និងកំបាំងមុខ, ជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈផ្សេងៗ តាមផ្លូវកាយ មានជួយព្យាយាមក្នុងពេលមានរោគជាដើមដោយមេត្តា ។ បើជាគ្រហស្ថជួយខ្នះខ្នែងតាមផ្លូវកាយក្នុងពេលមានកិច្ចធុរៈដូចជាធ្វើផ្ទះ សែនផ្ទះ ជួយធ្វើបុណ្យជាដើម ។



**២ — មេត្តាវចីកម្ម** តាំងវចីកម្មប្រកបដោយមេត្តា គឺជួយខ្វល់ខ្វាយក្នុង កិច្ចធុរៈ ទាំងចំពោះមុខ និង កំបាំងមុខ មិនពោលកាកែកខាយាំងឡើយ ត្រូវជួយដាស់តឿន ឬ បញ្ចេញយោបល់ប្រកបដោយការសន្តោស ។

**៣ — មេត្តាមនោកម្ម** តាំងមនោកម្មប្រកបដោយមេត្តា ចំពោះគ្នា នឹង គ្នា គឺគិតតែប្រយោជន៍ដល់គ្នា , មិនប្រទូសរ៉ាយគ្នា ។

**៤ — លាភៈ** ចែកលាភ ដែលខ្លួនបានមកដោយធម៌ឲ្យដល់គ្នា មិនហួងហែង ឬ ត្បិតត្បៀតលាក់លៀមគ្នាឡើយ, ត្រូវចេះចែកឲ្យអ្នកដទៃបរិភោគផង ។

**៥ — សីលៈ** រក្សាសីលឲ្យបរិសុទ្ធស្អាតស្អំស្មើគ្នា មិនធ្វើខ្លួនឲ្យជាទីរង្កៀសនៃអ្នកភូមិផងរបងជាមួយ ព្រោះតែសីលរបស់ខ្លួន ។

**៦ — ទិដ្ឋិ** មានសេចក្តីឃើញរួមគ្នា , យល់ស្របគ្នា បើកិច្ចការនោះឃើញថាជាប្រយោជន៍ ជាសុខដល់គ្នា , មិនបែកបាក់គ្នា ឬ ទាល់អធ្យាស្រ័យគ្នាឡើយ ។

រួមមកបើបុគ្គលប្រកបដោយសាកណីធម៌នេះហើយ ឈ្មោះថាអាចមេរស់នៅជាមួយគ្នាបានសុខស្រួល, អាចបង្កជាសង្គមតូចធំ គ្មានសត្រូវបៀតបៀន ។

# សត្តកៈ ពួកធម៌ ៧

## អបរិហានិយធម៌ ៧ យ៉ាង

**ស** — អបរិហានិយធម៌ ប្រែដូចម្ដេច ?

**ឆ** — អបរិហានិយធម៌ ប្រែថា ធម៌មិនជាទីតាំងនៃសេចក្ដីសាបសូន្យ , ប្រព្រឹត្តទៅដើម្បីសេចក្ដីចំរើន ។

**ស** — អបរិហានិយធម៌ នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** — អបរិហានិយធម៌នេះមាន ៧ យ៉ាងគឺ

១— ឧស្សាហ៍ប្រជុំគ្នា

២— កាលប្រជុំក៏ព្រមគ្នា , កាលបើលើកពេលប្រជុំគ្នាក៏ព្រមព្រៀងលើកទាំងព្រមព្រៀងធ្វើករណីយកិច្ចផ្សេងៗ ។

៣— វត្តប្រតិបត្តិណាដែលព្រះពុទ្ធអង្គ មិនទាន់បញ្ញត្តទុក មិនបញ្ញត្តដោយខ្លួនឯងឡើយ ទាំងមិនបានកាត់បោលនូវបញ្ញត្តរបស់ព្រះអង្គដែលមានមកហើយ , សមាទាន សិក្សាតាមសិក្ខាបទ នោះៗ ឲ្យបានម៉ត់ចត់ ។

៤— បុគ្គលណាជាប្រធាន ជាថេរៈ គោរពជឿស្ដាប់បុគ្គលនោះ ។

៥— មិនលុះតាមអំណាចចំណង់

៦— ត្រេកអរចំពោះសេនាសនៈស្ងាត់

៧— តាំងចិត្តគិតថាសព្រហ្មចារី គឺអ្នកមានសីលមិនទាន់មកកាន់



អាវាសនេះសូមឲ្យមក ៗ ដែលមកហើយសូមឲ្យនៅជាសុខសប្បាយតទៅ ។

**ស** — តើអបរិហានិយធម៌នេះមានន័យយ៉ាងណា ? ចូរពន្យល់ !

**ឆ** — មានន័យថា អបរិហានិយធម៌ ព្រះមានព្រះភាគទ្រង់សំដែងដល់ពួកលិច្ឆវី ក្នុងក្រុងវេសាលី និងសំដែងដល់ភិក្ខុជាបរិស័ទ គ្រាដែលព្រះអង្គគង់នៅក្រុងរាជគ្រឹះ ។ ធម៌នេះ សូម្បីគ្រហស្ថ និងបព្វជិត បើប្រព្រឹត្តឲ្យសមគួរដល់ភេទ និងកាលៈទេសៈ ។

ការឧស្សាហ៍ប្រជុំគ្នា ជាការចងមេត្រី ឲ្យស្និទ្ធស្នាល , ជាគ្រឿងតោងចិត្តឲ្យរួបរួមគ្នា ស្រឡាញ់គ្នា ជាឧបាយផ្លាស់ប្ដូរការបេះដឹងរវាងគ្នានិងគ្នា ។

ការប្រជុំ និង ការលើកពេលប្រជុំ ក៏ព្រមគ្នា ដើម្បីកាចឲ្យមានសាមគ្គីគ្នា , បង្ហាញមតិស្របគ្នា ជាហេតុឲ្យសម្រេចតាមលំដាប់ការ ។

មិនបញ្ញត្តខ្លួនឯង និងមិនកាត់ដកសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្ត, សមាទានតាមសិក្ខាបទដែលមាន បង្ហាញការគោរពប្រតិបត្តិ ចំពោះព្រះពុទ្ធោវាទ មិនឲ្យឃ្លៀងឃ្លាត, ជាអ្នកបណ្ដុះបណ្ដាលព្រះពុទ្ធសាសនា ឲ្យចំរុងចំរើន , ជាអ្នកមិនក្លែងដោយមធ្យោបាយផ្សេងៗឲ្យខូចសាសនាឡើយ ។ ការជឿតាមព្រះពុទ្ធោវាទឈ្មោះថាបានសង្កត់សង្កិនតណ្ហា ដែលកើតឡើងដោយទមវិធី និង សញ្ញមវិធី ។

ក្រោកអក្កុងសេនា..នះ  បង្ហាញការមិនចង់ឲ្យប្រឡូកប្រឡល់ដោយពួកគណៈ ។

បុគ្គលណាប្រកបដោយធម៌ទាំង ៧ ប្រការនេះ អ្នកនោះមានតែការចំរើនរុងរឿងតែម៉្យាង, សង្គមតូចធំឈ្មោះថាបានឈមមុខទៅរកសេចក្ដីសុខ ជៀសផុតពីទុក្ខទោមនស្សផ្សេងៗ ។

អាស្រ័យហេតុនេះបុគ្គលគួរតែប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវអបរិហានីយធម៌នេះកុំឲ្យដាច់ពីខន្ធសន្តាន ដើម្បីសេចក្ដីសុខក្នុងសង្គម ឬប្រទេសខ្លួន, ជៀសវាងឲ្យស្រឡះនូវការទាស់ទែងខ្វែងគំនិតគ្នា មើលបំណាំគ្នា បែកបាក់គ្នា បណ្ដាលឲ្យសាបសូន្យជាតិវង្សត្រកូលរបស់ខ្លួនឡើយ ។

## សប្បុរិសធម៌ ៧ យ៉ាង

ស- សប្បុរិសធម៌ គឺអ្វីខ្លះ ?

ឆ- សប្បុរិសធម៌ គឺធម៌របស់សប្បុរស គឺធម៌របស់បុគ្គលមានចិត្តប្រកបដោយកុសលធម៌ ។

ស- សប្បុរិសធម៌មានប៉ុន្មាន? គឺអ្វីខ្លះ? ចូររាប់ !

ឆ- សប្បុរិសធម៌នេះ ៧ យ៉ាងគឺ:

១- **មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណ

២- **អត្ថញ្ញុតា** ភាពជាអ្នកស្គាល់ផលប្រយោជន៍

៣- **អត្តញ្ញុតា** ភាពជាអ្នកស្គាល់ខ្លួន



៤- **ធម្មញ្ញុតា** ភាពជាអ្នកស្គាល់ហេតុ

៥- **កាលញ្ញុតា** ភាពជាអ្នកស្គាល់កាលវេលា

៦- **បរិសញ្ញុតា** ភាពជាអ្នកស្គាល់បរិស័ទ

៧- **បុគ្គលបរោបរញ្ញុតា** ភាពជាអ្នកស្គាល់បុគ្គល

ស- សប្បុរិសធម៌នេះ មានន័យដូចម្ដេច? ចូររៀបរាប់ !

ឆ- មានន័យយ៉ាងនេះគឺ:

— ការស្គាល់ប្រមាណ គឺស្គាល់តិចស្គាល់ច្រើន, ស្គាល់ខ្លាំងស្គាល់ខ្សោយ ដូចជាស្គាល់ពេលវេលា, វេលានេះគួរធ្វើ វេលានោះមិនគួរធ្វើ, វេលានេះគួរសើចលេង, វេលានោះមិនគួរសើចលេង, បរិភោគឲ្យស្គាល់ប្រមាណគឺមិនឲ្យឆ្អែតពេក ឬ បន្ទូរពេក ។

— ការស្គាល់ផល ដូចជាស្គាល់ថា ទុក្ខសច្ចជាផលនៃសមុទយសច្ច, និរោធសច្ចជាផលនៃមគ្គសច្ច ជាដើម ពុំនោះស្គាល់ផលដែលកើតអំពីការលួចប្លន់, អំពីការឈ្លោះទាស់ទែងគ្នា ។

— ការស្គាល់ខ្លួន គឺស្គាល់ថា អាត្មាអញ ជាតិត្រកូលយសបរិវារ ចំណេះចេះដឹង និងគុណធម៌ក្ដីទាបប៉ុណ្ណេះហើយប្រព្រឹត្តខ្លួនឲ្យសមតាមឋានៈចំណេះវិជ្ជានោះ មិនឆ្មើងឆ្មៃ ឬលើកខ្លួនជាធំជាអ្នកមានស្ដុកស្ដម្ភហួសហេតុ ខុសពីសមត្ថភាពខ្លួនឡើយ ។

— ការស្គាល់ហេតុ គឺស្គាល់ថា អ្វីទៅដែលបណ្ដាលជាទុក្ខទោម-

នស្ស, ហេតុដែលបណ្ដាលឲ្យសាបសូន្យទ្រព្យសម្បត្តិ, ហេតុបណ្ដាលឲ្យលង់ទៅ ខ្វះវិជ្ជា ហើយចំបាត់ហេតុដោយការលះបង់ ដើម្បីឲ្យបានសម្រេចតាមបំណង ។

– ការស្គាល់កាលវេលា គឺស្គាល់កាលដែលត្រូវដើរឲ្យទាន់ដើម្បីបានជាសុខសាន្ត ។

– ការស្គាល់បរិស័ទ គឺស្គាល់បរិស័ទក្នុងទីប្រជុំជននិងកិរិយាត្រូវប្រព្រឹត្តក្នុងប្រជុំជននោះ ដូចជាការសំដែងធម៌ឲ្យស្របតាមសមត្ថភាពពុទ្ធបរិស័ទ, ត្រូវសំដែងធម៌ខ្ពស់ទាបតាមទីកន្លែង ដើម្បីឲ្យពុទ្ធបរិស័ទអាចត្រងត្រាប់ស្ដាប់បាន ។

– ការស្គាល់បុគ្គល គឺស្គាល់ថាបុគ្គលនេះល្អគួរសេពគប់រកជាមិត្តទុកជាគំរូ, បុគ្គលនោះជាមនុស្សទ្រុស្តសីលប្រព្រឹត្តតែអំពើបាប មិនគួរសេពគប់រកយកមិត្តសំឡាញ់ឡើយ ។

ការស្គាល់យល់ទាំងអស់នេះ លោកថាជាអ្នកប្រកបដោយធម៌ដ៏ប្រពៃ ដែលឈ្មោះថាសប្បុរសនោះ បានប្រាកដគឺអ្នកមានសន្ដានចិត្តល្អបរិសុទ្ធ ។

## ពោជ្ឈង្គ ៧ យ៉ាង

**ស**– ពោជ្ឈង្គ ប្រែដូចម្ដេច ?

**ឆ** – ប្រែថា អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹង



**ស**– ចុះពោជ្ឈង្គ នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** – អង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹងនេះមាន ៧ យ៉ាងគឺ :

១ – សតិ សេចក្ដីរលឹក

២ – ធម្មវិចយៈ ការពិចារណាធម៌

៣ – វីរិយៈ សេចក្ដីព្យាយាម

៤ – បីតិ ការឆ្អែតចិត្ត

៥ – បស្សទ្ធិ សេចក្ដីស្ងប់ចិត្តនឹងអារម្មណ៍

៦ – សមាធិ ការតាំងចិត្តខ្ជាប់ខ្ជួន

៧ – ឧបេក្ខា ចិត្តព្រងើយកន្តើយ

បើគេហៅតាមប្រភេទថា សតិពោជ្ឈង្គៈ ធម្មវិចយពោជ្ឈង្គៈ រហូតដល់ឧបេក្ខាសម្ពោជ្ឈង្គៈ ។

**ស**– តើពោជ្ឈង្គៈទាំង ៧ នេះមានន័យដូចម្ដេចខ្លះ ? ចូរពន្យល់ !

**ឆ** – មានន័យដូចនេះគឺ:

បុគ្គលដែលប្រកបដោយធម៌ ៧ ប្រការនេះត្រឹមត្រូវហើយ ធម៌នេះនឹងទំនុកបំរុងដល់គ្នានឹងគ្នា ឲ្យសម្រេចនូវគុណប្រយោជន៍ដ៏ធំក្រៃលែង ដូចជាមានសតិបរិបូណ៌ ហើយអាចនឹងតាំងមុខបំពេញព្យាយាម បើកាយចិត្តទោរទន់គំថយកម្លាំងដោយបីតិ បើកំរើកលើសហួសប្រមាណទៅ ក៏ត្រូវកាត់សន្ធុះដោយបស្សទ្ធិ ឲ្យគង់នៅតែល្មមល្អប្រសើរ មិនបាច់ស្លួយ

ឡើង ឬសន្តតិចុះជាចំណែកសមាធិត្រូវសំឡឹងមើលដោយឧបេក្ខា គឺឲ្យជាកណ្តាលមិនទោមនស្ស ឬសោមនស្សហួសហេតុធ្វើឲ្យខូចប្រយោជន៍ផ្សេងៗ ឡើយ ។

បុគ្គលណាបានកាន់ខ្ជាប់នូវអង្គនៃបញ្ញាឈ្មោះថា ជាអ្នកធ្វើខ្លួនឲ្យមានសមត្ថភាព សមរម្យជាមនុស្សមានប្រាជ្ញាស្មារតី គួរឲ្យអ្នកដទៃគោរពកោតខ្លាច ។

## អរិយធន ៧ យ៉ាង

**ស**– អរិយធន ប្រែថាដូចម្តេច ?

**ឆ**– អរិយធន ប្រែថា ទ្រព្យរបស់អរិយបុគ្គល ឬ ទ្រព្យដ៏ប្រសើរ

**ស**– តើអរិយធននេះ មានប៉ុន្មាន ? គឺអ្វីខ្លះ ? ចូរពប់!

**ឆ**– មាន ៧ យ៉ាងគឺ:

១– **សទ្ធាធនំ** ទ្រព្យគឺៈ សទ្ធា

២– **សីលធនំ** ទ្រព្យគឺសីល

៣– **ហិរិធនំ** ទ្រព្យគឺហិរិ

៤– **ឱត្តប្បធនំ** ទ្រព្យគឺសេចក្តីខ្លាចបាប

៥– **សុតធនំ** ទ្រព្យគឺការបានឮ - ស្តាប់ច្រើន

៦– **ចាគធនំ** ទ្រព្យគឺការលះបង់

៧– **បញ្ញាធនំ** ទ្រព្យគឺបញ្ញា



**ស**– ទ្រព្យខាងដើមមិនចាំបាច់លើកយកមកសាកសួរតទៅទៀតទេ យើងគ្រាន់តែលើកយកទ្រព្យទី ៧ ខាងចុងមកសួរថា តើ បញ្ញាធនំ នេះ ដូចម្តេចដែរ ? ចូរបង្ហាញន័យ ?

**ឆ**– បញ្ញាធនំ មានន័យថា ការចេះដឹងមានច្រើនយ៉ាងបើរួមឲ្យខ្លីមកមាន ២ គឺ លោកិយបញ្ញា បញ្ញារបស់បុថុជ្ជន ជាជនបញ្ញា ដែលយើងគេកល់គ្នាប្រើប្រាស់រៀងរាល់ថ្ងៃ សម្រាប់ពិចារណារកខុសត្រូវ វៀរចាកបាបកម្មផ្សេងៗ ដើម្បីឈមទៅរកការឈ្លាសវៃប៉ិនប្រសប់ ខ្ពស់មាត់មុខទ្រព្យសម្បត្តិ លៀងជីពជនក្នុងបច្ចុប្បន្នកាល ។ លោកុត្តរបញ្ញា ជាបញ្ញារបស់ព្រះអរិយបុគ្គល ជាបញ្ញាគិតតែសាងបារមីធម៌, បំពេនសមាធិ ជាផ្លូវសួគ៌ ផ្លូវនិព្វាន ដើម្បីរំដោះសត្វលោកឲ្យរួចចាកវដ្ដ-សង្សារ រលាស់ខ្លួនចេញពីកិលេសមានកាមកិលេសជាដើម ។

**ស**– តើ អ្វីដែលជាផ្លូវធ្វើឲ្យកើតបញ្ញា ? គឺអ្វីខ្លះ ?

**ឆ**– ផ្លូវដែលឲ្យកើតបញ្ញានោះមាន ៣ គឺ:

១ **សុត** : ការស្តាប់, ឮច្រើនហើយចងចាំទុក

២– **ចិន្ត** :ការ គិត, ការត្រិះរិះពាក្យពេចន៍ ឬហេតុផលដែលបានស្គាល់ - ឮរួចមកហើយឲ្យបែក, យល់ដោយខ្លួនឯង ។

៣– **ភាវនា** ការអប់រំ គឺអប់រំចិត្ត កុំឲ្យរវើរវាយចាកគំនិតដែលខ្លួនកំពុងត្រិះរិះ, ឈ្វេចឈ្វៃឲ្យបានច្បាស់លាស់ ។

---

# អដ្ឋកៈពួកធម៌ ៨

## លោកធម៌ ៨ យ៉ាង

ស – លោកធម៌ គឺធម៌របស់អ្នកណា ?

ឆ – លោកធម៌ គឺធម៌របស់សត្វលោក ឬ ធម៌សង្កត់នូវសត្វលោក ។

ស – លោកធម៌ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ – ធម៌នេះមាន ៨ គឺ

១ – **លាភ** ការបាន-មាន

២ – **អលាភ** ការមិនបាន-មាន

៣ – **យស** យស

៤ – **អយស** មិនមានយស

៥ – **និន្ទា** ការឈ្នានីស

៦ – **បសំស** : ការសរសើរ

៧ – **សុខ** : សេចក្តីសុខ

៨ – **ទុក្ខ** : សេចក្តីទោមនស្ស

ស – លោកធម៌នេះ បើបម្រួញ ឲ្យខ្លីមកទៀតបានប៉ុន្មាន ? គឺអ្វីខ្លះ ? ចូរបង្ហាញ !

ឆ – បើបម្រួញឲ្យខ្លីមក ២ យ៉ាងគឺ :



១ **ឥដ្ឋារម្មណ៍** អារម្មណ៍ទីគាប់ចិត្ត

២ – **អនិដ្ឋារម្មណ៍** អារម្មណ៍មិនគាប់ចិត្ត-គាប់អធ្យាស្រ័យ

ស – ចុះអ្វីខ្លះដែលចាត់ជាឥដ្ឋារម្មណ៍ ?

ឆ – លាភ, យស, បសំស; សុខ: ចាត់ចូលក្នុងឥដ្ឋារម្មណ៍ ព្រោះជាទីប្រាថ្នាចង់បាននៃសត្វលោក ។

ស – អលាភ, អយស, និន្ទា, ទុក្ខ ចាត់ចូលក្នុងអនិដ្ឋារម្មណ៍ ព្រោះមិនជាទីប្រាថ្នាចង់បាន នៃសត្វលោក ។

បុញ្ញកិរិយាវត្ថុ លោករាប់បញ្ចូល លាភ, យស, ការសរសើរ, សេចក្តីសុខ ចុះហេតុអ្វី ក៏លោករាប់ធម៌នេះចូលក្នុងលោកធម៌ដែរ? ចូរបង្ហាញមកមើល ?

ឆ – បានជារាប់បញ្ចូលក្នុងលោកធម៌ដែរនោះ ព្រោះសត្វលោក កាលណាមានលាភ យស ជាដើម ចិត្តនោះក៏ប៉ោងឡើងជាខុសប្រក្រតី កាលបើខាតលាភចិត្តក៏ចុះថយទៅ សមដូចពាក្យថា: លាភេន ឧន្នតោ អលាភេន ឱនតោ កាលបើមានលាភ ចិត្តនោះក៏កើតកើនហ៊ឹកហា មើលងាយគេឯង ដោយអាងខ្លួនមានបុណ្យសក្តិ ទ្រព្យសម្បត្តិសម្បូណ៌ហូរហៀរ សូម្បីញាតិមិត្តរបស់ខ្លួនក៏មើលងាយដែរ, ផ្ទុយទៅវិញកាលបើខូចបុណ្យសក្តិយសបរិវារ ចិត្តនោះក៏សុបសៅ អៀនខ្មាស់ខូចចិត្ត ។ ម្យ៉ាងទៀតចិត្តនោះ កាលបើមានគេត្មះតិះដៀល រមែងទឹង ទោមនស្ស,

បើគេពោលពាក្យសរសើរក៏ដោរ, កាលបើសេចក្ដីសុខកើតឡើង ក៏កុំថាសេចក្ដីទុក្ខអស់ហើយ មិនការពារទុក្ខក្រែងកើតមានដល់ខ្លួនទៀត, កាលបើមានទុក្ខក៏កើតសោកសៅ ទឹកស្ដាយស្រណោះ ។

**ស**– កាលបើលោកធម៌ទាំង ៨ នេះកើតឡើង ហើយត្រូវពិចារណាដូចម្ដេចដែរ ?

**ឆ**– កាលបើកើតឡើងត្រូវពិចារណាថា : របស់នេះកើតមានដល់អាត្មាអញ តែជារបស់មិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា, ត្រូវធ្វើកុំឲ្យញាប់ញ័រ រំភើបចំពោះវត្ថុនោះមកគ្របសង្កត់ចិត្តយើងបាន, កុំត្រេកត្រអាល ឬកុំតោមនស្ស ដោយបញ្ចេញអាការៈផ្សេងៗឡើយ ។

## មគ្គមានអង្គ ៨ យ៉ាង

**ស**– ពាក្យថា មគ្គ ប្រែដូចម្ដេច ?

**ឆ**– មគ្គ ប្រែថា ផ្លូវ ,

**ស**– តើផ្លូវនោះ គឺផ្លូវដែលដើររាល់ថ្ងៃ ឬ ដូចម្ដេច ?

**ឆ**– មិនមែនផ្លូវដែលយើងដើររៀងរាល់ថ្ងៃនេះទេ ប៉ុន្តែគឺផ្លូវដែលបុគ្គលធ្វើដំណើរដោយវិថីចិត្ត ក្នុងការប្រតិបត្តិធម៌ ដើម្បីដល់ទីបំផុតនៃសេចក្ដីទុក្ខគឺ ព្រះនិព្វាន ។

**ស**– តើ មគ្គ ប្រែដូចម្ដេចបានទៀត ?

**ឆ**– មគ្គ នេះប្រែបានទៀត គឺប្រែថាសភាវៈសម្លាប់នូវកិលេសទាំង



ឡាយ សមដូចវិគ្រោះថា កិលេសេ មារេតីតិ » មគ្គោ (សភាវោ) សភាវៈណាសម្លាប់នូវកិលេសទាំងឡាយសភាវៈនោះ ឈ្មោះថាមគ្គ បានដល់មគ្គ ៤ គឺ សោតាបត្តិមគ្គ ១, សកទាគាមិមគ្គ ១, អនាគាមិមគ្គ ១, អរហត្តមគ្គ ១ ។

**ស**– តើអង្គរបស់មគ្គមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ**– អង្គរបស់មគ្គមាន ៨ ដែលហៅថា អដ្ឋង្គិកមគ្គនោះគឺ

**១– សម្មាទិដ្ឋិ** បញ្ញាឃើញប្រពៃគឺឃើញអរិយសច្ច ៤ មានទុក្ខសច្ចជាដើម ។

**២– សម្មាសង្កប្បៈ** ការត្រិះរិះប្រពៃ គឺត្រិះរិះដើម្បីចេញចាកកាម១, មិនព្យាបាទ១, មិនបៀតបៀន១ ។

**៣– សម្មាវាចា** វាចាប្រពៃគឺវៀរចាកវចីទុច្ចរិត ៤ គឺនិយាយកុហក ១, និយាយញុះញង់ ១, និយាយទ្រគោះ ១, និយាយឡេះឡោះ ១ ។

**៤– សម្មាកម្មន្ត** ការងារប្រពៃដោយ វៀរចាកទុច្ចរិត ៣ គឺ កាយទុច្ចរិត ១, វចីទុច្ចរិត ១, មនោទុច្ចរិត ១ ។

**៥– សម្មាអាជីវៈ** ការចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតដោយផ្លូវខុសមានបាណាតិបាតជាដើម ។

**៦– សម្មាវាយាម** ការព្យាយាមប្រពៃ គឺព្យាយាមក្នុងទី ៤ ស្ថាន

មានព្យាយាមរាំងបាបមិនឲ្យកើតឡើង ១, ព្យាយាមលះបាបអកុសលដែលកើតមានហើយ ១, ព្យាយាមរក្សាកុសលដែលខ្លួនបានសន្សំរួចមកហើយ ១, ព្យាយាមធ្វើកុសល ដែលមិនទាន់កើតឲ្យកើតឡើង ១ ។

**៧– សម្មាសតិ** ដំកល់ស្មារតីប្រពៃគឺរលឹកឃើញនូវសតិប្បដ្ឋាន៤ ។

**៨– សម្មាសមាធិ** ការតាំងចិត្តប្រពៃ គឺចំរើនឈាន ៤ មានបឋមជ្ឈានជាដើម ។

**ស–** អដ្ឋង្គិកមគ្គនេះ បើចាត់ចូលក្នុងកម្ម ៣ គឺ កាយកម្ម ១, វចីកម្ម ១, មនោកម្ម ១, តើអង្គណាចូលទៅក្នុងកម្មណា ?

**ឆ–** បើសង្គ្រោះចូលក្នុងកម្មនោះ, ចាត់ដូច្នេះ :

– សម្មាកម្មន្តៈ, សម្មាអាជីវៈ ជា កាយកម្ម ;

– សម្មាវាចា ជាវចីកម្ម ;

– សម្មាទិដ្ឋិ, សម្មាសង្កប្បៈ, សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ ជា មនោកម្ម ;

**ស–** ចុះបើចាត់ចូលក្នុងវិជ្ជា និង ចរណៈ តើចាត់ដូចម្តេចខ្លះ ?

**ឆ–** បើចាត់ជាវិជ្ជា និងចរណៈ ចាត់ដូចនេះ :

– សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ចាត់ជាវិជ្ជា ;

– សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ, សម្មាវាយាម, សម្មាសតិ, សម្មាសមាធិ ចាត់ចូលក្នុងចរណៈ ។



**ស–** ចុះបើចាត់ចូល ក្នុងខន្ធ ៣ គឺ សីលក្ខន្ធ, សមាធិក្ខន្ធ បញ្ញាខន្ធ តើចាត់ដូចម្តេចខ្លះ ?

**ឆ–** ចាត់ដូចនេះ :

– សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ ចាត់ជាសីលក្ខន្ធ

– សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ ចាត់ជាសមាធិក្ខន្ធ

– សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ចាត់ជាបញ្ញាខន្ធ ។

បើចាត់ចូលក្នុងសិក្ខា មានសីលសិក្ខាជាដើមក៏ដូចគ្នា នឹងខន្ធដែរ ។

## លក្ខណៈវិនិច្ឆ័យធម៌វិន័យ ៨ យ៉ាង

**ស–** ដូចម្តេចដែលហៅថាការវិនិច្ឆ័យធម៌វិន័យ ?

**ឆ–** ការការកាត់ធម៌វិន័យឲ្យបានត្រឹមត្រូវតាមបន្ទាត់ ហៅថា វិនិច្ឆ័យ ។

**ស–** ហេតុដូចម្តេចបានជាចាំឲ្យមានការការកាត់ដូច្នេះ ?

**ឆ–** បានជាវិនិច្ឆ័យឲ្យត្រឹមត្រូវ ព្រោះធម្មតាធម៌វិន័យបុគ្គលតែងប្រព្រឹត្តល្អៀងឃ្លៀងឃ្លាត ដួនកាលប្រព្រឹត្តតាមធម៌មិនពិតក្លែងក្លាយ ដែលធ្វើឲ្យខូចសេចក្តីពិតនៃធម៌វិន័យ ។

**ស–** ចុះការដឹងពិត ឬ មិនពិតនោះ អាស្រ័យដោយអ្វី ?

**ឆ–** ពិត ឬ មិនពិតនោះអាស្រ័យដោយលក្ខណវិនិច្ឆ័យ ។

**សួ** — តើលក្ខណៈវិនិច្ឆ័យធម៌វិន័យនេះមានប៉ុន្មានដែរ ? គឺអ្វីខ្លះ ? ចូររាប់មកមើល !

**ឆ** — លក្ខណៈវិនិច្ឆ័យធម៌វិន័យនេះមាន ៨ យ៉ាងគឺ :

១ — ធម៌ណាប្រព្រឹត្តទៅដើម្បីតម្រេក

២ — ធម៌ណាប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខ

៣ — ធម៌ណាប្រព្រឹត្តទៅដើម្បីសន្សំកងកិលេស

៤ — ធម៌ណាប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាធំ

៥ — ធម៌ណាប្រព្រឹត្តទៅដើម្បីមិនសន្តោសដោយរបស់ដែលមាន គឺចង់បានមិនចេះចប់

៦ — ធម៌ណាប្រព្រឹត្តទៅដើម្បីច្រឡូកច្រឡំដោយពួកគណៈ

៧ — ធម៌ណាប្រព្រឹត្តទៅដើម្បីការខ្ជិលច្រអូស

៨ — ធម៌ណាប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមក្រ

បញ្ជាក់ថាធម៌ទាំងនេះមិនមែនជាធម៌, មិនមែនជាវិន័យ, មិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាឡើយ ។

**សួ** — តើធម៌ដែលផ្ទុយពីនេះដូចម្តេចខ្លះ ?

**ឆ** — ធម៌ដែលផ្ទុយពីនេះគឺ

១ — ធម៌ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក

២ — ធម៌ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ

៣ — ធម៌ប្រព្រឹត្តទៅដើម្បីប្រាសចាកកិលេស



៤ — ធម៌ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច

៥ — ធម៌ប្រព្រឹត្តទៅដើម្បីត្រេកអរចំពោះរបស់ដែលមាន

៦ — ធម៌ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ

៧ — ធម៌ប្រព្រឹត្តទៅដើម្បីតាំងសេចក្តីព្យាយាម

៨ — ធម៌ប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមងាយ

ធម៌ទាំងនេះជាធម៌វិន័យពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

ព្រះឱវាទជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធមានច្រើនប្រការណាស់ តែបើរួបរួមឲ្យខ្លីមកមានតែ ២ ប្រការ គឺធម៌និងវិន័យ ។ ព្រះពុទ្ធសាសនាគង់យូរណាស់ហើយរមែងមានធម៌វិន័យពីសាសនាផ្សេង ៗ ចូលមកជ្រៀតជ្រែកក្នុងពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។ ការដែលព្រះអង្គសំដែងលក្ខណៈទុកនោះក៏ដោយសារព្រះអង្គមានពុទ្ធបំណងចង់ឲ្យធម៌វិន័យព្រះអង្គបរិសុទ្ធស្អាតដែលផ្តល់សេចក្តីសុខ ដល់អ្នកប្រតិបត្តិពិត ៗ, មិនឲ្យប្រតិបត្តិខុសចិត្តអធ្យាស្រ័យ ។

## នវកៈពួកធម៌ ៩

### មលៈ ៩ យ៉ាង

**ស** - មលៈ គឺអ្វី ?

**ឆ** - មលៈ គឺសេចក្ដីសៅហ្មងនៃចិត្ត

**ស** - តើមលៈនេះមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់ !

**ឆ** - មលៈនេះមាន ៩ យ៉ាងគឺ ៖

**១ - ក្រោធ** ៖ កំហឹង

**២ - មក្ខ** ៖ លុបគុណគឺមើលគុណគេ

**៣ - ឥស្សា** ប្រណែនឈ្នានីស

**៤ - មច្ឆរិយៈ** សេចក្ដីកំណាញ់ស្វិតស្វាញ

**៥ - មាយា** លាក់បាំងទោសខ្លួន

**៦ - សាឋេយ្យៈ** អួតអាង

**៧ - មុសា** ការពោលពាក្យកុហក

**៨ - បាបិច្ឆៈ** ការប្រាថ្នាដ៏លាមក

**៩ - ទិដ្ឋិ** យល់ខុស

**ស** - តើមន្ទិលទាំង ៩ នេះមានន័យយ៉ាងណាខ្លះ ? ចូរពន្យល់ន័យឲ្យល្មមស្ដាប់ !

**ឆ** - មានន័យយ៉ាងនេះ ៖



- សេចក្ដីក្រោធ គឺការធ្វើចិត្តឲ្យឆៅឆារ រើសពាស់ក្នុងកាលមានអារម្មណ៍អាក្រក់មកប៉ះពាល់ ។ សេចក្ដីក្រោធខុសគ្នាពីទោសៈប្រទូសរ៉ាយ , ទោសៈនេះសំដៅយកចិត្តគាបប្រាសចាកមេត្តាករុណាមានកើតសម្ពន្ធនពីសេចក្ដីក្រោធ ។ សេចក្ដីក្រោធនេះ លោកចាត់ទុកដូចសាស្ត្រាវុធក្នុងលោកដូចបាលីថា កោធោ សត្ថមលំ លោកេ ។

- ការលុបគុណ គឺការលែងស្គាល់ខុសត្រូវបានដល់ការភ្លេចគុណ ឬ បដិសេធគុណរបស់បុគ្គលដទៃដែលមានឧបការៈដល់ខ្លួន ។ មនុស្សយ៉ាងនេះ លោកហៅថាមនុស្សចិត្តខ្មៅ ចូលក្នុងលក្ខណៈរបស់បុគ្គលអកតញ្ញូ អកតវេទី , មិនដឹងគុណ , មិនតបស្នងគុណ ។ មនុស្សប្រភេទនេះ លោកប្រាប់ឲ្យជៀសឆ្ងាយ ដូចបាលីថា មនុស្សផេគ្គុំ នាសិតេ **យស្មិំ នត្ថិ កតញ្ញុតា** ។

- ឫស្យា ការអន្ទះអន្ទែងសោយសេល ឈ្នានីស , ខ្វាចក្រែងបុគ្គលដទៃមានជាងខ្លួន , មានយសបរិវារលើសខ្លួន មានសេចក្ដីសុខច្រើនជាង ។ កាលបើយល់ឃើញដូច្នេះ ក៏បណ្ដាលចិត្តឲ្យប្រទូសរ៉ាយ , បំផ្លាញប្រយោជន៍ផ្សេង ៗ របស់គេ ។ បុគ្គលបែបនេះលោកឲ្យឈ្មោះ អរតិលោកនាសកា ចិត្តឫស្យាជាចិត្តបំផ្លាញសេចក្ដីសុខនៃសត្វលោក ។

- កំណាញ់បានដល់ការមិនលះបង់ចាកទាន គឺលាក់លៀមទុករហូតដល់មិនហ៊ានបរិភោគខ្លួនឯង ។

លោកពោលថា មច្ឆេរំ ទទតោមលំ សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ។

– ឧបាយកល គឺការធ្វើអាការៈឲ្យប្លែកខុសពីប្រក្រតីដូចជាមនុស្សមិនឈឺធ្វើជាឈឺ, មនុស្សមានកំហុសលាក់បាំងកំហុស ។

មនុស្សបែបនេះតែងធ្វើកាយវាចាឲ្យគេវង្វេងដោយសារខ្លួន តែការធ្វើនេះបានចំពោះតែមនុស្សល្ងង់ខ្លៅប៉ុណ្ណោះ បើមនុស្សឆ្លាតគេចេះដឹងខ្លួនពុំអាចប្រព្រឹត្តទៅលើគេបានឡើយ គឺគេផ្ចាញ់ផ្ចាល់ធ្វើឲ្យក្តៅក្រហាយវិញពុំខាន ។

– អំនួត គឺការពោលពាក្យខុសពីសភាវៈដែលមានបានដល់ការពោលអួតគុណវិសេសដែលខ្លួនមិនមាន ដូចជាចំណេះវិជ្ជាខ្លួនមានឬចេះបន្តិចបន្តួច ពោលប្រាប់ថាចេះច្រើនអាចដោះស្រាយបញ្ហាបានដើម្បីឲ្យគេចូលចិត្តខ្លួន, បានលាភសក្ការៈមកដល់ខ្លួន ។ អាស្រ័យហេតុនេះលោកតែងហាមថា អប្បត្តោ នោ ច ឧល្លបេ របស់មិនទាន់បាន, មិនទាន់មកដល់ កុំគប្បីពោលអួតព្រោះការពោលដូច្នេះតែងមានទោសអំពីសំណាក់អ្នកតាមដានៗ

– ការពោលពាក្យមិនពិត គឺពោលពាក្យមិនឲ្យអ្នកដទៃជឿទុកចិត្តបាន ។ ការពោលពាក្យកុហករមែងទម្លាយនូវជំនឿរបស់អ្នកដទៃឲ្យវិនាសនិងបង្កើតជាមន្ទិលដល់ខ្លួនមិនចេះចប់ ។



ក្បួរប្រាជ្ញាអាក្រក់ បានដល់សេចក្តីប្រាជ្ញាប្រាសចាកធម៌ដូចប្រាជ្ញាលាភផលដែលប្រកបដោយទុច្ចរិតខុសចាកគន្លងធម៌ ។ សេចក្តីប្រាជ្ញារបៀបនេះបើមានចំពោះអ្នកណារមែងធ្វើចិត្តអ្នកនោះឲ្យកករល្អក់លោកចាត់ជាមន្ទិល ។

– ការយល់ខុស បើពោលឲ្យចំគឺ មិច្ឆាទិដ្ឋិ ។ ការឃើញខុសចាកគតិរបស់ព្រះពុទ្ធសាសនាដូចជាឃើញថាគ្មានបុណ្យ, គ្មានបាប, គ្មាននរក, គ្មានសួគ៌ ហួតដល់យល់ថា ឪពុក-ម្តាយ គ្មានគុណជាដើម ។ កាលបើយល់ឃើញបែបនេះ ដរាបណាសេចក្តីក្តៅក្រហាយក៏កើតមានដែរ ព្រោះការនិយាយស្តី, កិច្ចការនានាចេះតែមិនស្តាប់បង្គាប់, មិនស្របគ្នា ។ ចិត្តដូច្នេះលោកចាត់ជាមន្ទិលដែលបុគ្គលមិនគប្បីសេពគប់ ។

សារុបសេចក្តីមកមន្ទិលទាំងអស់នេះ សុទ្ធតែធ្វើចិត្តបុគ្គលឲ្យកករល្អក់, ឲ្យប្រព្រឹត្តតែអំពើទុច្ចរិត ដែលជាហេតុមួយធ្វើឲ្យសត្វមានការទាស់ទែងខ្វែងគំនិតគ្នា ពុំអាចរួមរស់នៅជាសុខក្នុងទីមួយ, សង្គមមួយ, ប្រទេសមួយជាមួយគ្នាបាន គឺប្រកបដោយការហែកហួរ ក្តៅគ្នា ដោយប្រការផ្សេងៗ ។

ហេតុនេះ សត្វគប្បីវៀរចាកមន្ទិលនេះឲ្យស្រឡះ ដើម្បីរស់នូវសុខជាមួយគ្នា ចេះគោរពរាប់អានគ្នា តាមសមត្ថភាពរបស់ខ្លួន ។

# ទសកៈពួកធម៌ ១០

## អកុសលកម្មបថ ១០ យ៉ាង

ស – អកុសលកម្មបថ មានសេចក្តីយ៉ាងណា ?

ឆ – អកុសលកម្មបថ ប្រែថា ផ្លូវនៃអំពើអកុសល ឬ ផ្លូវដែលបណ្តាលឲ្យប្រព្រឹត្តអំពើអាក្រក់ ។

ស - ចុះបើប្រែថាផ្លូវនៃអំពើអាក្រក់ដូច្នេះ មិនប្រហែល ឬដូចគ្នានឹងទុច្ចរិតហើយឬអ្វី ? ចូរពន្យល់ !

ឆ – មិនដូចគ្នាទេ គឺមានន័យផ្សេងគ្នា ដូច្នេះ :

– អកុសលកម្មបថនេះបំណងយកតែផលអាក្រក់ដែលកើតពីការប្រព្រឹត្ត ពោលគឺទៅកាន់ទុគ្គតិតែម្យ៉ាង ។

– ឯទុច្ចរិតបានដល់ការប្រព្រឹត្តអាក្រក់ គឺហេតុដែលបណ្តាលឬហុចផលអាក្រក់ ។

ដូច្នេះឃើញថាទាំង ២ នេះផ្សេងគ្នា ដោយបំណងនៃលក្ខណៈដូចគ្នាដែល ។

ស – អកុសលកម្មបថនេះ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ – មាន ១០ យ៉ាងគឺ :

១ – បាណាតិបាត ការសម្លាប់សត្វ

២ – អទិន្នាទាន ការលួចប្លន់ទ្រព្យអ្នកដទៃ

៣ – កាមេសុ មិច្ឆារៈ ការប្រព្រឹត្តខុសក្នុងកាម

៤ – មុសាវាទ ការពោលពាក្យមិនពិត

៥ – បិសុណាវាចា និយាយពាក្យញុះញង់

៦ – ផរុសវាចា និយាយចាក់ដោត

៧ – សម្ផប្បលាបៈ និយាយពាក្យគ្មានខ្លឹមសារ

៨ – អភិជ្ឈា លោភចង់បានហួសហេតុ

៩ – ព្យាបាទ ប្រទូសរ៉ាយ, បៀតបៀនគេ

១០ – មិច្ឆាទិដ្ឋិ ឃើញខុសចាកគន្លងធម៌

ស – អកុសលកម្មបថ ១០ នេះ បើសង្គ្រោះចូលក្នុងកម្ម តើដូចម្តេចខ្លះ ?

ឆ – បើចាត់ចូលក្នុងកម្មចាត់ដូចនេះ :

– បាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារៈ ៣ នេះ ចាត់ជាកាយកម្ម គឺអំពើប្រព្រឹត្តតាមផ្លូវកាយ ។

– មុសាវាទ, បិសុណាវាចា, ផរុសវាចា, សម្ផប្បលាបៈ ៤ នេះ ចាត់ជាវចីកម្ម ព្រោះប្រព្រឹត្តដោយការពោលនិយាយ ។

– អភិជ្ឈា, ព្យាបាទ មិច្ឆាទិដ្ឋិ ៣ នេះចាត់ជាមនោកម្មព្រោះប្រព្រឹត្តតាមផ្លូវចិត្ត ។

## កុសលកម្មបថ ១០ យ៉ាង

ស– ដូចម្តេចហៅថា កុសលកម្មបថ ?

ឆ – ការប្រព្រឹត្តតាមផ្លូវល្អ, ផ្លូវត្រូវវៀរចាកទុច្ចរិតឈ្មោះថា កុសលកម្មបថ ។

ស– តើកុសលកម្មបថនោះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ – កុសលកម្មបថនេះមាន ១០ គឺ :

១ – បាណាតិបាតា វេរមណី វៀរចាកការសម្លាប់សត្វ ។

២ – អទិន្នាទានា វេរមណី វៀរចាកការលួចឆក់ទ្រព្យគេ។

៣ – កាមេសុ មិច្ឆាចារា វេរមណី វៀរចាកការប្រព្រឹត្តខុសក្នុងកាម;

៤ – មុសាវាទា វេរមណី វៀរចាកការពោលពាក្យកុហក ;

៥ – បិសុណាវាចាយ វាចាយ វេរមណី វៀរចាកការនិយាយពាក្យញុះញង់ ។

៦ – ផរុសាយ វាចាយ វេរមណី វៀរចាកការនិយាយពាក្យចាក់ដោត ។

៧ – សម្ផប្បលាបា វេរមណី វៀរចាកនិយាយពាក្យរោយឥតប្រយោជន៍;

៨ – អនភិជ្ឈា មិនលោភចង់បានរបស់គេ



៩ – អព្យាបាទ មិនប្រទូស្តរ៉ាយ

១០– សម្មាទិដ្ឋិ ឃើញត្រូវតាមគន្លងធម៌

កម្ម ១០ យ៉ាងនេះជាផ្លូវគួរដើរ គួរប្រតិបត្តិ, អ្នកសិក្សាគប្បីដឹង គប្បីជ្រាបដើម្បីជាកិច្ចធ្វើចាកវដ្តសង្សារ ។

កម្មបថនេះបើបាត់ជាកម្មក៏មានប្រៀបប្រហាក់ប្រហែលគ្នានឹង អកុសលកម្មបថ ១០ ខាងដើមដែរ ។

ស– កម្ម : ប្រែដូចម្តេច ?

ឆ – កម្ម : ប្រែថាអំពើដែលបុគ្គលធ្វើ-គួរធ្វើ

ស– កុសលកម្មបថ គឺអំពើល្អ ឈប់សម្លាប់សត្វ ឈប់លួចទ្រព្យគេជាដើមដែលបុគ្គលគួរប្រព្រឹត្តប្រតិបត្តិ ចុះអកុសលកម្មបថនោះម្តេចក៏ឈ្មោះថាកម្មដែរ ? ចូរប្រាប់ហេតុផល ?

ឆ – កុសលកម្មបថ ក៏ជាអំពើដែលបុគ្គលគួរធ្វើពិតមែនតែឈប់សម្លាប់សត្វ ប៉ុន្តែធ្វើដោយចេតនាដែលវៀរ បើឈប់ទេៗ ហើយមិនវៀរ ក៏មិនឈ្មោះថាកុសលកម្មបថបានដូចបាលីថា កាយទុច្ចរិត បហាយកាយសុចរិតភាវេតិ ន័យថា លះកាយទុច្ចរិត ចំរើនកាយសុចរិត ទើបឈ្មោះថា កុសលកម្មបថបាន ។

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង

ស– ពាក្យបុញ្ញកិរិយាវត្ថុ ប្រែដូចម្តេច ?

ឆ – បុញ្ញកិរិយាវត្ថុ ប្រែថាវត្ថុ ឬ ហេតុដែលបណ្ដាលឲ្យបានបុណ្យកុសលផ្សេងៗ ។

ស – ចុះបុញ្ញកិរិយាវត្ថុនេះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ – មាន ១០ យ៉ាងគឺ :

១ – **ទានមយ:** បុណ្យសម្រេចដោយការឲ្យទាន

២ – **សីលមយ:** បុណ្យសម្រេចដោយការរក្សាសីល

៣ – **ភាវនាមយ:** បុណ្យសម្រេចដោយការចំរើន

៤ – **អបចាយនមយ:** បុណ្យសម្រេចដោយការប្រព្រឹត្តិបន្ទន់ខ្លួនចំពោះលោកដែលជាធំ:

៥ – **វេយ្យាវច្ចមយ:** បុណ្យសម្រេចដោយការខ្វល់ខ្វាយក្នុងកិច្ចដែលត្រូវ, ។

៦ – **បត្តិទានមយ:** បុណ្យសម្រេចដោយការឲ្យចំណែកបុណ្យ,

៧ – **បត្តានុមោទនាមយ:** បុណ្យសម្រេចដោយការអនុមោទនាចំណែកបុណ្យ,

៨ – **ធម្មស្សវនមយ:** បុណ្យសម្រេចដោយការស្ដាប់ធម៌

៩ – **ធម្មទេសនាមយ** បុណ្យសម្រេចដោយការសំដែងធម៌,

១០ – **ទិដ្ឋុជុកម្ម** ធ្វើការឃើញឲ្យត្រឹមត្រង់

ស – តើបុញ្ញកិរិយាវត្ថុ ១០ នេះ បើបំប្រួញមកមានប៉ុន្មានយ៉ាង ?



គឺអ្វីខ្លះ ?

ឆ – បើបំប្រួញឲ្យខ្លីមកមាន ៣ យ៉ាងគឺ:

១ – **ទានមយ**

២ – **សីលមយ**

៣ – **ភាវនាមយ**

ស – ចុះ បុញ្ញកិរិយាវត្ថុ ៧ នោះ តើសង្គ្រោះចូលទៅណាខ្លះ ? ចូរបង្ហាញ!

ឆ – នៅសល់ ៧ នោះគេសង្គ្រោះដូច្នេះ :

– បត្តិទានមយ: , បត្តានុមោទនាមយ: ២ នេះសង្គ្រោះចូលក្នុងទានមយ: ,

– អបចាយនមយ: , វេយ្យាវច្ចមយ ២ នេះចូលក្នុងសីលមយ: ,

ស – ចុះបើគេចែកដោយពិស្ដារ តើត្រូវជាបុញ្ញកិរិយាវត្ថុប៉ុន្មាន ?

ឆ – បើចែកដោយពិស្ដារត្រូវជាបុញ្ញកិរិយាវត្ថុ ៨០ ។

ស – តើ ៨០ នោះគេចែកដូចម្ដេច ?

ឆ – គេចែកដោយយកមហាកុសល ៨ មកគុណនឹងបុញ្ញកិរិយាវត្ថុ ១០ នេះត្រូវជា ៨០ ។

## ធម៌ដែលបព្វជិតគួរពិចារណា ១០ យ៉ាង

ស – បព្វជិតកាលបើបានស្ថិតក្នុងព្រះពុទ្ធោវាទ ត្រូវតែពិចារណា

រឿយ ៗ នូវធម៌, តើធម៌អ្វីខ្លះ ដែលបព្វជិតគួរយកមកពិចារណាមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ– បព្វជិតគួរពិចារណានូវធម៌ ១០ យ៉ាងគឺ:

**១– វេវណ្ណិយម្ហិ អជ្ឈុបគតោ** អាត្មាអញមានភេទផ្សេង ៗ ចាកគ្រហស្ថហើយ អាការៈណារបស់សមណៈ អាត្មាអញត្រូវធ្វើតាមអាការកិរិយានោះ ។

**២– បរប្បដិពទ្ធា មេ ជីវិកា** ការចិញ្ចឹមជីវិតរបស់អាត្មាអញអាស្រ័យដោយអ្នកដទៃ អាត្មាអញគួរធ្វើខ្លួនឲ្យគេចិញ្ចឹមងាយ ។

**៣– អញ្ញោ មេ អាកប្បោ ករណីយោ** អាការកិរិយាក៏បា ដទៃ ៗ ដែលអាត្មាអញ នឹងត្រូវធ្វើឲ្យល្អប្រពៃឡើងជាងនេះ

**៤– កិច្ចិ នុខោ មេ អត្តា សីលតោ ន ឧបវទតិ** ខ្លួនអាត្មាអញតិះដៀលខ្លួនរបស់អាត្មាអញ ដោយសីលបានឬទេ ?

**៥– កិច្ចិ នុខោ មំ អនុវិច្ចវិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ** ពួកសព្រហ្មចារី អ្នកដឹងទាំងឡាយ ពិចារណាហើយ មិនតិះដៀលអាត្មាអញព្រោះសីល ( មិនបរិបូណ៌ ) បានដែរឬទេ ?

**៦– សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ** អាត្មាអញនឹងត្រូវព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ពេញចិត្តទាំងអស់ ។



**៧- កម្មស្ស កោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួនធ្វើល្អ បានល្អ ធ្វើអាក្រក់បានអាក្រក់ ,

**៨– កថម្ភូតស្ស មេ រត្តិន្ទិវា វិតិបតន្តិ** ថ្ងៃនិងយប់កន្លងទៅៗ ឥឡូវនេះអាត្មាអញបានធ្វើអ្វីខ្លះ ?

**៩ – កិច្ចិនុខោហំ សុញ្ញាគារេ អភិរមាមិ** អាត្មាអញត្រេកអរក្នុងទីស្ងាត់ដែរឬទេ ?

**១០– អត្ថិ នុខោ មេ ឧត្តរិមនុស្សធម្មោ** គុណវិសេសរបស់អាត្មាអញនៅមានឬទេ ? បើពួកសព្រហ្មចារីមកសួរក្នុងបច្ឆិមកាលតើអាត្មាអញនឹងមិនអៀនខ្មាសទេឬ ?

ស– ធម៌ ១០ នេះ បើបព្វជិតយកមកពិចារណាតើមានប្រយោជន៍ដូចម្តេចខ្លះ ?

ឆ – មានប្រយោជន៍គឺ ដើម្បីនឹងឲ្យរំពឹងដល់ភេទ អាជីវបរិយា មារយាទ ស្ថាន និងគុណវិសេស, កាលបើបានរំពឹងដូចនេះ បានជាឧបាយសម្រាប់ដាស់តឿនចិត្តឲ្យប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ប្រកបសេចក្តីព្យាយាមជាគ្រឿងអប់រំចិត្តឲ្យស្ងប់រម្ងាប់ ឲ្យខំខ្វល់ខ្វាយតែខាងបណ្តុះវិជ្ជាប្រាជ្ញា រួមសេចក្តីទៅជាប្រយោជន៍ឲ្យបានសម្រេចក្នុងលោកិយនេះនិងបរលោក ។

ស– តើអាចពិចារណាបានតែបព្វជិតទេឬក៏គ្រហស្ថអាចពិចារណា

បានដែរ ?

ឆ -. គ្រហស្ថអាចពិចារណាបានខ្លះដែរ គឺបានត្រឹមតែធម៌ទី ៤ ដល់ទី ៩ ហើយអាចពិចារណាបានរឿយ ៗ ។

## កថាវត្ថុ ១០ យ៉ាង

ស- កថាវត្ថុ ប្រែដូចម្តេច ?

ឆ- កថាវត្ថុ ប្រែថាពាក្យជាហេតុពោលពាក្យគួរនិយាយគួរពោល ។

ស- ពាក្យគួរពោលមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ - មាន ១០ ប្រការគឺ:

១ - អប្បិច្ឆកថា ពាក្យពោលដឹកនាំឲ្យមានសេចក្តីប្រាថ្នាតិច,

២ - សន្តុដ្ឋិកថា ពាក្យពោលដឹកនាំឲ្យមានចិត្តប្រណីត្រេកអរ ដោយបច្ច័យតាមមាន-បាន ។

៣ - បវិវេកកថា ពាក្យពោលដឹកនាំឲ្យស្ងប់ចិត្តស្ងប់កាយ

៤ - អសង្គកថា ពាក្យពោលដឹកនាំមិនឲ្យប្រចូកប្រចល់ ,

៥ - វីរិយារម្ភកថា ពាក្យពោលដឹកនាំឲ្យប្រារព្ធព្យាយាម

៦ - សីលកថា ពាក្យពោលដឹកនាំឲ្យតាំងនៅក្នុងសីល

៧ - សមាធិកថា ពាក្យដឹកនាំឲ្យធ្វើចិត្តឲ្យនឹងន ,

៨ - បញ្ញាកថា ពាក្យពោលដឹកនាំឲ្យកើតបញ្ញា

៩ - វិមុត្តិកថា ពាក្យពោលដឹកនាំឲ្យធ្វើចិត្តឲ្យផុតចាកកិលេស



១០- វិមុត្តិញាណទស្សនកថា ពាក្យពោលដឹកនាំឲ្យកើតការឃើញសភាវៈដែលចិត្តផុតចាកកិលេស ។

កាលបើយើងពិចារណានូវកថាវត្ថុនេះហើយក៏នឹងឃើញ បានសុទ្ធតែផលយ៉ាងវិសេសវិសាលឲ្យកើតប្រយោជន៍ចំពោះខ្លួន ពោលគឺបានប្រទះតែសុខសន្តិភាព គ្មានអ្វីមកយាយីបៀតបៀនទៀតឡើយ ។

## អនុស្សតិ ១០ យ៉ាង

ស - អនុស្សតិ ប្រែដូចម្តេច ?

ឆ - ប្រែថា ការរលឹកឃើញនូវអារម្មណ៍

ស - តើអនុស្សតិនេះប៉ុន្មានប្រការ ? គឺអ្វីខ្លះ ? ចូរពាច់ !

ឆ - មាន ១០ ប្រការគឺ :

១ - ពុទ្ធានុស្សតិ រលឹកគុណព្រះពុទ្ធ

២ - ធម្មានុស្សតិ រលឹកគុណព្រះធម៌

៣ - សង្ឃានុស្សតិ រលឹកគុណព្រះសង្ឃ

៤ - សីលានុស្សតិ រឭកសីល

៥ - ចាគានុស្សតិ រឭកដល់ទានដែលខ្លួនបានបរិចាគ

៦ - ទេវតានុស្សតិ រលឹកដល់គុណធម៌ គឺទេវតា

៧ - មរណានុស្សតិ រលឹកឃើញសេចក្តីស្លាប់

៨ - កាយគតានុស្សតិ រឭកទៅក្នុងរាងកាយឲ្យឃើញថាមិន

ល្អស្អោកគ្រោកគួរខ្ពើម ,

**៩ – អានាបានុស្សតិ** តាំងស្មារតីកំណត់ខ្យល់ដកដង្ហើមចេញចូល ។

**១០– ឧបសមានុស្សតិ** រឭកដល់គុណព្រះនិព្វាន

**ស** – តើអនុស្សតិទាំង ១០ នេះមានន័យយ៉ាងណាដែរ? ចូរបង្ហាញ ។

**ឆ** – មានន័យយ៉ាងនេះថា: ការរលឹកដល់គុណអរហំ ជាដើមហៅថារលឹកគុណព្រះពុទ្ធជាម្ចាស់ , រលឹកថា ស្វាក្ខាតោ ជាដើមហៅថារលឹកគុណព្រះធម៌ , រលឹកថា សុបដិបន្នោ ឈ្មោះថារលឹកគុណព្រះសង្ឃ , រលឹកសីលដែលខ្លួនរក្សា គឺរលឹកថាខ្លួនបានរក្សាបរិសុទ្ធត្រឹមត្រូវឬខុសឆ្គង ហើយកែប្រែឡើងវិញដោយការរឭកដាស់តឿនញយៗ ឈ្មោះថារលឹកសីល , រឭកដល់ធម៌ដែលខ្លួនបានធ្វើហើយឧទ្ទិសចំពោះទេវតា ឈ្មោះថា ទេវតានុស្សតិ , រលឹកដល់ការដេកស្លាប់ស្តូកស្តឹងនៃសត្វលោក មិនចេះចប់ហៅថា មរណានុស្សតិ , ការភ្ញាក់ស្មារតីនឹកឃើញថាខ្លួនមិនស្អាត, មិនទៀង ប្រកបដោយការស្អុយ ស្អុះគួរខ្ពើម ហៅថា កាយគតានុស្សតិ, ការតាំងចិត្តឲ្យនឹងនរ , ដកដង្ហើមចេញចូលឲ្យវែង ឲ្យស្មើ ហៅថា អានាបានុស្សតិ , ការរលឹកឃើញព្រះនិព្វានជាទីរលត់នូវកិលេស សេចក្តីបង់ប្រាថ្នាផ្សេងៗ , ជាបរមសុខ ឈ្មោះឧបសមានុស្សតិ ។

អនុស្សតិទាំង ១០ នេះជាកុសលយ៉ាងខ្ពស់ សូម្បីអ្នកដែលបានបំពេញហើយមិនទាន់បានសម្រេចមគ្គផលក៏ឈ្មោះថា មានឧបនិស្ស័យ



ជាប់នឹងខ្លួនទៅក្នុងភពខាងមុខ បានឈ្មោះបំពេញកុសលដោយចំណែកសមថភាវនា ។

## នាថករណធម៌ ១០ យ៉ាង

**ស** – នាថករណធម៌ ប្រែថាដូចម្តេច ?

**ឆ** – ប្រែថា ធម៌ធ្វើនូវទីពឹងពំនាក់អាស្រ័យ

**ស** – តើនាថករណធម៌នេះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** – មាន ១០ យ៉ាងគឺ:

**១ – សីល** រក្សាកាយវាចាឲ្យរៀបរយ

**២ – ពាហុសច្ចៈ** ភាពជាអ្នកបានរៀនសូត្រច្រើន ,

**៣ – កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អប្រសើរ

**៤ – សោវចស្សតា** ភាពជាអ្នកប្រដៅងាយ,

**៥ – កឹករណីយេសុ ទក្ខតា** ភាពជាអ្នកខ្នះខ្នែងក្នុងកិច្ចធុរៈរបស់អ្នកដទៃ

**៦ – ធម្មកាមតា** ភាពជាអ្នកប្រាថ្នាក្នុងកុសលធម៌

**៧ – វីរិយៈ** ភាពជាអ្នកព្យាយាមត្រឹមត្រូវតាមធម៌

**៨ – សន្តោសៈ** ការត្រេកអរចំពោះរបស់តាមមានបាន , មិនរើសអើង ,

**៩ – សតិ** ការតាំងស្មារតីឲ្យមាំមួន

## ១០- បញ្ហា ដឹងគុណគន់សង្ខារទាំងពួង

ធម៌ទាំង ១០ ប្រការដូចពោលរៀបរាប់មកនេះ បើបុគ្គលណាបាន បំពេញបរិបូណ៌ ហើយរមែងហុច ផលប្រយោជន៍គឺជាទីពឹងពំនាក់នៃបុគ្គល នោះ តាមសមគួរដល់ការប្រតិបត្តិ ។

**ស** – សីលក្នុងទីនេះ បានដល់សីលប្រភេទណា ?

**ឆ** – បានដល់សីលទូទៅ សំរាប់គ្រហស្ថ និង បព្វជិតកាន់ប្រព្រឹត្ត ដើម្បីឲ្យមានរបៀបរៀបរយល្អ មានសណ្ដាប់ធ្នាប់សមរម្យ ជាពុទ្ធសា-សនិកជន ។

**ស** – ចុះ ពាហុសច្ច នោះបានដល់ការរៀនសូត្រប្រភេទណាដែរ ? ព្រោះអ្វី ?

**ឆ** – ពាហុសច្ច មិនសំដៅយកចំណេះណាមួយតែមួយមុខ ។ ទេ គឺបានដល់ចំណេះចេះដឹងនូវវិជ្ជាផ្សេង ៗ ដែលជាវិជ្ជាផ្លូវលោក ឬ ផ្លូវធម៌ ឬ ជាវិជ្ជាជីវៈសំរាប់ចិញ្ចឹមជីវិត ក្នុងបច្ចុប្បន្ននេះ ។ ការចេះនូវវិជ្ជាច្រើន មានគុណប្រយោជន៍ ច្រើនត្រង់ការយកនូវវិជ្ជានោះមកអនុវត្តផង . យក វិជ្ជាផ្សេង ៗ មកត្រិះរិះពិចារណា ប្រៀបផ្ទឹមគ្នាផងនេះឯង ។ កាលណា គ្រហស្ថ ឬបព្វជិត បានចេះវិជ្ជាច្រើន ហើយចេះប្រៀបធៀបពិចារណាបែប នេះហើយ ទោះគេគោរពប្រព្រឹត្តប្រតិបត្តក្តី ការជ្រើសរើសផ្លូវសំរាប់ដើរ ក្តី ការប្រកបរបរចិញ្ចឹមជីវិតក្តី គឺពិតជាបានផលប្រសើរ ដើរតាមផ្លូវត្រូវ



ល្អជាមិនខាន ។

**ស** – ចុះមិត្តល្អ អាចឲ្យផលយ៉ាងណាដែរ ?

**ឆ** – មិត្តល្អ មិនគ្រាន់តែនាំឲ្យយើងប្រព្រឹត្តដោយកាយវាចា ចិត្ត ប៉ុណ្ណោះទេ តែអាចធ្វើឲ្យយើងមានទំនុកទុកចិត្តទៅលើកិច្ចការផង ឲ្យ យើងធ្វើការងារត្រូវទៅតាមច្បាប់ទម្លាប់សំរាប់រដ្ឋ ឬ ត្រូវតាមផ្លូវធម៌ថែម ទៀត ។

**ស** – ពាក្យថា សន្ដោស និង អប្បិច្ឆតា មានន័យដូចគ្នា ឬផ្សេង គ្នា ចូរពន្យល់ !

**ឆ** – សន្ដោស គឺការត្រេកអរចំពោះវត្ថុដែលខ្លួនមានហើយមិន ចង់បានរបស់ដែលខ្លួនគ្មាន ដែលផ្ទុយគ្នាពីលោភៈ ។ អប្បិច្ឆតា គឺការ ប្រាថ្នាតិច បានដល់ការបន្ថយសេចក្តីប្រាថ្នា ឲ្យចុះមកយ៉ាងតិចបំផុត ដែលផ្ទុយគ្នាពីពាក្យថា ឥច្ឆតា ភាពជាអ្នកប្រាថ្នាធំ ។ បើនិយាយឲ្យ ងាយស្ដាប់ថា ដូចបុគ្គលដែលមានប្រពន្ធហើយ ក៏ប្រាថ្នាតែលើប្រពន្ធ របស់ខ្លួនមួយប៉ុណ្ណោះមិនចង់បានប្រពន្ធ ឬ កូនអ្នកដទៃយកមកបន្ថែមទៀត ទេ គឺមានបានតែចំពោះរបស់ដែលខ្លួនមានបានរួចហើយប៉ុណ្ណោះ ឯ របស់ដែលគ្មាន ឥតចង់បានឡើយ ចំណែកខាងអប្បិច្ឆតា ភាពជាអ្នក ប្រាថ្នាតិចបំផុត គឺសូម្បីរបស់ខ្លះដែលខ្លួនមានហើយក៏ដោយ ក៏លះបង់ បន្ថែមទៅទៀតឲ្យនៅសល់តែរបស់ណាដែលចាំបាច់បំផុតសំរាប់ ប្រើប្រាស់

ជីវិតឲ្យរស់ ដើម្បីប្រព្រឹត្តសេចក្ដីល្អតែប៉ុណ្ណោះ ។

**ស** — សតិ និង បញ្ញា ជាគូគ្នា តើដូចគ្នា ឬ ផ្សេងគ្នា ? ចូរពន្យល់ !

**ឆ** — មិនដូចគ្នាទេ ។ សតិ បានដល់ស្មារតីចងចាំប្រុងប្រយ័ត្នជានិច្ច មិនឲ្យភ្លេចភ្លាំងភ្លាយ ឬមិនធ្វេសប្រហែសក្នុងកិច្ចការផ្សេង ៗ ចំណែកខាងបញ្ញា គឺការដឹង — ស្គាល់ - យល់ ដោយសារការត្រិះរិះពិចារណា ហើយចេះធ្វើការប្រៀបធៀប និង វិនិច្ឆ័យចំពោះហេតុការណ៍ផ្សេង ៗ ។ បញ្ញាមានច្រើនថ្នាក់ តាមលំដាប់លំដោយនៃនិស្ស័យមនុស្ស ។ សតិកើតឡើង ឯបញ្ញាក៏កើតបន្ទាប់គ្នា ។ កត្តាទាំងពីរនេះត្រូវទាក់ទងគ្នាជានិច្ច ។ បញ្ញា ជាសភាវៈ ជាគតិដែលលេចចេញបន្តិច ១ ពីស្មារតីនេះឯង. ។

## បរិវសានកថា

ការចោទឆ្លើយរួចមកហើយក្នុងធម្មវិភាគ សូមបន្ទុកបច់តែប៉ុណ្ណោះ សូមផលានិសង្ស ដែលកើតពីការតែងនិងសិក្សាព្រះធម្មវិន័យរបស់ព្រះសក្យមុនីសម្មាសម្ពុទ្ធនេះ ផ្សព្វផ្សាយចំពោះមនុស្សជាសម្មាទិដ្ឋិទាំងអស់ក្នុងសកលលោក ។

សូមព្រះពុទ្ធសាសនាបានរុងរឿងជាអតិបរមា ។

តម្កល់ទុកតាមលេខ ៧៩៨
ចុះថ្ងៃទី ២០ — ៥ — ៧២
បោះពុម្ពលើកទី ១ ចំនួន ២.៥០០ ក្បាល
រោងពុម្ពសាមគ្គី